switchasia

Funded by
the European Union

# ការដកស្រង់មេរៀន បទពិសោធន៍នៅអាស៊ីក្នុង ការអនុវត្តកិច្ចលទ្ធកម្ម សាធារណៈប្រកបដោយ និរន្តរភាព/បៃតង

## ប្រទេសចិន ឡាវ ម៉ាឡេស៊ី ថៃ វៀតណាម















## ការថ្លែងអំណរគុណ

របាយការណ៍ស្តីពី "ការដកស្រង់បទពិសោធន៍នៃបណ្តាប្រទេសនៅអាស៊ីក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព រួមមាន៖ ប្រទេសចិន ឡាវ ម៉ាឡេស៊ី ថៃ និងវៀតណាម" ត្រូវបានធ្វើឡើងដោយ EU-SWITCH-Asia Policy Support Component (PSC) ដោយមានលោកស្រីបណ្ឌិត Lunchakorn Prathumratana និងលោក Sanjay Kumar ជាអ្នកសម្របសម្រួល និងរៀបចំ ក្រោមការត្រួតពិនិត្យទូទៅរបស់លោកស្រី Elodie Maria-Sube និងលោកស្រីបណ្ឌិត Zinaida Fadeeva ប្រធានក្រុមរបស់ EU-SWITCH-Asia Policy Support Component។

Funded by
the European Union

The SWITCH-Asia Programme

© 2024 SWITCH-Asia

ការបដិសេធទទួលខុសត្រូវ

ព័ត៌មាន និងមាតិកានៅក្នុងឯកសារនេះ ជាការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមអ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។

# មាតិកា

១. សេចក្តីផ្តើម ........ 8
២. ប្រទេសចិន ........ 9
៣. ប្រទេសឡាវ ........ 19
៤. ប្រទេសម៉ាឡេស៊ី ........ 24
៥. ប្រទេសថៃ ........ 30
៦. វៀតណាម ........ 37
៧. សេចក្តីសន្និដ្ឋាន ........ 43

# តារាង

**តារាងទី១៖** ច្បាប់ និងបទប្បញ្ញត្តិរបស់ចិនពាក់ព័ន្ធលទ្ធកម្មសាធារណៈបៃតង (GPP) ........ 11
**តារាងទី២៖** លក្ខណៈសណ្ឋានសំខាន់ៗនៃបញ្ជីលទ្ធកម្មទាំងពីរ៖ បញ្ជីការទិញសាធារណៈនូវផលិតផលបិទស្លាកមេត្រីបរិស្ថាននិងបញ្ជីលទ្ធកម្មផលិតផលបិទស្លាកមេត្រីបរិស្ថាន ........ 15
**តារាងទី៣៖** សង្ខេបស្លាកអេកូ (ecolabel) ដែលបានទទួលយកសម្រាប់ចុះបញ្ជីលទ្ធកម្មសាធារណៈបៃតងថៃ ........ 34

# គំនូសតាង

**គំនូសតាងទី១៖** ក្របខ័ណ្ឌស្ថាប័នរបស់លទ្ធកម្មសាធារណៈបៃតង នៅប្រទេសចិន ........ 12
**គំនូសតាងទី២៖** ក្របខ័ណ្ឌស្ថាប័នពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងលទ្ធកម្មសាធារណៈបៃតង នៅប្រទេសឡាវ .. 22
**គំនូសតាងទី៣៖** ក្របខ័ណ្ឌស្ថាប័នបច្ចុប្បន្ននៃលទ្ធកម្មរដ្ឋាភិបាលបៃតងនៅប្រទេសម៉ាឡេស៊ី ........ 26
**គំនូសតាងទី៤៖** ក្របខ័ណ្ឌស្ថាប័នរបស់លទ្ធកម្មសាធារណៈបៃតងនៅប្រទេសថៃ ........ 32
**គំនូសតាងទី៥៖** ទីភ្នាក់ងាររដ្ឋាភិបាល និងការទទួលខុសត្រូវរៀងៗខ្លួន ក្នុងការអនុវត្តលទ្ធកម្មសាធារណៈបៃតង នៅវៀតណាម ........ 40

# ពាក្យបំព្រួញ និងអក្សរកាត់

| | |
|---|---|
| **10YFP** | ក្របខ័ណ្ឌកម្មវិធីរយៈពេល ១០ឆ្នាំ ស្តីពីការប្រើប្រាស់ និងបែបផែនផលិតកម្មប្រកបដោយនិរន្តរភាព |
| **ACT** | អង្គភាពផ្តល់វិញ្ញាបនបត្របញ្ជាក់កសិកម្មសរីរាង្គនៃព្រះរាជាណាចក្រថៃ |
| **$CO_2e$** | សមមូលកាបូនឌីអុកស៊ីត ($CO_2e$) ជាឯកតាសម្រាប់វាស់ឥទ្ធិពលកម្តៅ របស់ឧស្ម័នផ្ទះកញ្ចក់ |
| **CEC** | មជ្ឈមណ្ឌលឯកភាពចិនផ្តល់វិញ្ញាបនបត្របរិស្ថាន |
| **CGD** | នាយកដ្ឋានអគ្គនិយ័តករ |
| **CP** | កាតាឡុករួមសម្រាប់ការជាវ |
| **CPS** | មជ្ឈមណ្ឌលសេវាកម្មលទ្ធកម្ម |
| **CQC** | មជ្ឈមណ្ឌលផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពនៃប្រទេសចិន |
| **DCCE** | នាយកដ្ឋានការប្រែប្រួលអាកាសធាតុ និងបរិស្ថាន |
| **DIP** | នាយកដ្ឋានផលិតកម្មឧស្សាហកម្ម |
| **DIW** | នាយកដ្ឋានការងារឧស្សាហកម្ម |
| **e-GP** | ប្រព័ន្ធលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិក |
| **ECL** | បញ្ជីលទ្ធកម្មផលិតផលសន្សំសំចៃថាមពល |
| **ECPs** | ផលិតផលសន្សំសំចៃថាមពល |
| **EDC** | មជ្ឈមណ្ឌលអភិវឌ្ឍន៍បរិស្ថាន |
| **ELP** | ផលិតផលមានស្លាកមេត្រីបរិស្ថាន |
| **EU** | សហភាពអឺរ៉ុប |
| **FSC** | ក្រុមប្រឹក្សាគ្រប់គ្រងព្រៃឈើ |
| **GAPP** | រដ្ឋបាលទូទៅផ្នែកសារព័ត៌មាន និងការបោះពុម្ពផ្សាយ |
| **GGNSC** | គណៈកម្មាធិការជាតិជំរុញកំណើនបៃតង |
| **GGP** | ប្រព័ន្ធលទ្ធកម្មបៃតងរបស់រដ្ឋាភិបាល (សូមមើល លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព/SPP) |
| **GHG** | ឧស្ម័នផ្ទះកញ្ចក់ |
| **GIZ** | ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ |
| **GoL** | រដ្ឋាភិបាលឡាវ |
| **GPL** | ច្បាប់លទ្ធកម្មឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាល |

| | |
|---|---|
| **GPP** | លទ្ធកម្មសាធារណៈបៃតង |
| **ICT** | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ |
| **IFOAM** | សហព័ន្ធអន្តរជាតិនៃចលនាកសិកម្មសរីរាង្គ |
| **IGPN** | បណ្តាញការជាវបៃតងកម្រិតអន្តរជាតិ |
| **IISD** | វិទ្យាស្ថានអន្តរជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព |
| **KEITI** | ឧស្សាហកម្ម និងបច្ចេកវិទ្យាបរិស្ថានកូរ៉េ |
| **KeTTHA** | ក្រសួងថាមពល បច្ចេកវិទ្យាបៃតង និងទឹក (នៃប្រទេសម៉ាឡេស៊ី) |
| **Kg $CO_2e$** | សមមូលកាបូនឌីអុកស៊ីត (CO2e) ជាឯកតាសម្រាប់វាស់ឥទ្ធិពលកម្តៅ របស់ឧស្ម័នផ្ទះកញ្ចក់ |
| **KPIs** | សូចនាករសមិទ្ធកម្មសំខាន់ៗ |
| **Lao PDR** | សាធារណរដ្ឋប្រជាមានិត ប្រជាធិបតេយ្យឡាវ (ហៅកាត់ថា ឡាវ) |
| **MEM** | ក្រសួងថាមពល និងរ៉ែ |
| **MEP** | ក្រសួងការពារបរិស្ថាន |
| **MFA** | ក្រសួងការបរទេស |
| **MGTC** | សាជីវកម្មម៉ាឡេស៊ីសម្រាប់បច្ចេកវិទ្យាបៃតង និងការប្រែប្រួលអាកាសធាតុ |
| **MOF** | ក្រសួងហិរញ្ញវត្ថុ |
| **MOFCOM** | ក្រសួងពាណិជ្ជកម្ម |
| **MOI** | ក្រសួងឧស្សាហកម្ម |
| **MOIC** | ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម |
| **MOIT** | ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម |
| **MONRE** | ក្រសួងធនធានធម្មជាតិ និងបរិស្ថាន |
| **MPI** | ក្រសួងផែនការ និងវិនិយោគ |
| **MPWT** | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| **MyHIJAU** | កម្មវិធីលទ្ធកម្មទូទៅ ក្រោមឱវាទក្រសួងថាមពល បច្ចេកវិទ្យាបៃតង និងទឹក ម៉ាឡេស៊ី (KeTTHA) |
| **NDRC** | គណៈកម្មការអភិវឌ្ឍន៍ និងកំណែទម្រង់ជាតិ |
| **NGO** | អង្គការមិនមែនរដ្ឋាភិបាល |
| **NPC** | សមាជជាតិរបស់ប្រជាជន |
| **NSEDP** | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជាតិ |

| | |
|---|---|
| **PCD** | នាយកដ្ឋានត្រួតពិនិត្យការបំពុល |
| **PDCM** | នាយកដ្ឋានត្រួតពិនិត្យ និងតាមនដានការបំពុល |
| **PEFC** | កម្មវិធីសម្រាប់អនុម័តវិញ្ញាបនបត្រព្រៃឈើ |
| **PPA** | ទីភ្នាក់ងារលទ្ធកម្មសាធារណៈ |
| **PPCs** | ភ្នាក់ងាមជ្ឈមណ្ឌលលទ្ធកម្មសាធារណៈ |
| **PSC** | អង្គភាពគាំទ្រគោលនយោបាយរបស់ EU SWITCH-Asia |
| **SBD** | នាយកដ្ឋានថវិការដ្ឋ |
| **SCP** | ការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព (សមាសភាគមួយនៃកម្មវិធីរបស់ SWITCH-Asia) |
| **SDG** | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ |
| **SMEs** | សហគ្រាសធុនតូច និងមធ្យម |
| **SOE** | សហគ្រាសរដ្ឋ |
| **SPP, S/GPP** | លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព ឬ លទ្ធកម្មសាធារណៈបៃតង |
| **SuPP-Urb** | លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព នៃបណ្តារដ្ឋបាលទីក្រុងនៅប្រទេសចិន |
| **TBL** | ច្បាប់ស្តីពីការបើកដេញថ្លៃ និងសំណើដេញថ្លៃ ឆ្នាំ១៩៩៩ |
| **TCO** | 'TCO Certified' ជាស្ថាប័ននាំមុខគេលើពិភពលោកក្នុងការចេញវិញ្ញាបនបត្របញ្ជាក់និរន្តរភាព សម្រាប់ផលិតផល IT ដែលបង្កើតឡើងដោយសហព័ន្ធនិយោជិតអាជីពប្រទេសស៊ុយអែត (Swedish Confederation of Professional Employees) |
| **TEI** | វិទ្យាស្ថានបរិស្ថាននៃប្រទេសថៃ |
| **TGL** | ស្លាកបៃតងនៃប្រទេសថៃ |
| **TISI** | វិទ្យាស្ថានស្តង់ដាឧស្សាហកម្មនៃប្រទេសថៃ |
| **UNDP** | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| **UNEP** | កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ |

# ១. សេចក្តីផ្តើម

លទ្ធកម្មសាធារណៈបៃតង (GPP) ជាឧបករណ៍ដ៏មានឥទ្ធិពលមួយ សម្រាប់បណ្តាប្រទេសដែលដាក់គោលដៅសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងដោះស្រាយបញ្ហាបរិស្ថានរបស់ខ្លួន។ ការរៀបចំបង្កើតគោលនយោបាយ គឺជាទិដ្ឋភាពសំខាន់មួយ ដោយសារវាផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តលទ្ធកម្មសាធារណៈបៃតង។ ការរៀបចំគោលនយោបាយបានល្អគឺអាស្រ័យ ផែនទីចង្អុលផ្លូវច្បាស់លាស់ ដោយបានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះចីរភាព, ការកំណត់ចំណុចផ្តោត និងការកំណត់វិសាលភាពនៃលទ្ធកម្មបៃតង។ ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិរឹងមាំ រឹតតែមានសារៈសំខាន់ ដើម្បីធានាបាននូវអនុលោមភាព និងគណនេយ្យភាព។ ការរៀបចំតាក់តែងច្បាប់ និងបទប្បញ្ញត្តិទាំងឡាយគួរតែសម្របតាមស្តង់ដាអន្តរជាតិ, លើកកម្ពស់សង្គតិភាព និងភាពស៊ីចង្វាក់ប្រទាក់ក្រឡាគ្នានៅក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈបៃតង។ ការធ្វើបែបនេះមិនត្រឹមតែកាត់បន្ថយហានិភ័យផ្នែកច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានផ្តល់សញ្ញាច្បាស់លាស់មួយទៅកាន់តួអង្គទីផ្សារ សំដៅលើកទឹកចិត្តពួកគេឱ្យទទួលយកទម្លាប់នៃការអនុវត្តល្អៗទាក់ទិនទៅនឹងនិរន្តរភាព មកប្រតិបត្តិនៅក្នុងសកម្មភាពធុរកិច្ចរបស់ខ្លួន។

ការរៀបចំបង្កើតយន្តការទទួលខុសត្រូវនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ គឺជាកិច្ចការមួយសំខាន់សម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈបៃតងឱ្យមានប្រសិទ្ធភាព ព្រោះវាកំណត់នូវការទទួលខុសត្រូវ និងធានាឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពក្នុងចំណោមអាជ្ញាធរពាក់ព័ន្ធ។ គោលការណ៍ណែនាំ និងលក្ខណៈវិនិច្ឆ័យសម្រាប់ប្រព័ន្ធលទ្ធកម្មសាធារណៈបៃតងជួយសម្រួលដំណើរការលទ្ធកម្មបន្ថែមទៀត ដោយផ្តល់នូវការយល់ដឹងជាក់ស្តែង និងកម្រិតគោល (benchmarks) សម្រាប់ធ្វើការសម្រេចចិត្តបញ្ជាទិញមាននិរន្តរភាព។ កម្មវិធីពង្រឹងសមត្ថភាព និងបណ្តុះបណ្តាល មានសារៈសំខាន់ក្នុងការបំពាក់មន្រ្តីលទ្ធកម្មនូវជំនាញវិជ្ជាជីវៈ និងចំណេះដឹងចាំបាច់ ដើម្បីគ្រប់គ្រងដំណើរការលទ្ធកម្មបៃតងដែលមានលក្ខណៈស្មុគ្រស្មាញច្រើន។ យុទ្ធនាការបង្កើនការយល់ដឹង ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតទំនាក់ទំនងល្អរវាង រវាងតួអង្គពាក់ព័ន្ធនានា សំដៅលើកកម្ពស់ការយល់ដឹងរួមគ្នាអំពីអត្ថប្រយោជន៍របស់លទ្ធកម្មសាធារណៈបៃតង។ យន្តការតាមដាន និងវាយតម្លៃ គឺពិតជាមិនអាចខ្វះបានសម្រាប់តាមដានវឌ្ឍនភាព, រកមើលឱ្យឃើញនូវបញ្ហាដែលចាំបាច់ត្រូវកែលម្អ និងបង្ហាញពីឥទ្ធិពលនៃការអនុវត្តគំនិតផ្តួចផ្តើមទាំងឡាយទាក់ទិនទៅនឹងកិច្ចលទ្ធកម្មសាធារណៈបៃតង។ កិច្ចសហការ និងភាពជាដៃគូ ជួយពង្រីកវិសាលភាព និងប្រសិទ្ធភាពរបស់លទ្ធកម្មសាធារណៈបៃតងពីព្រោះថា ការធ្វើការពាក់ព័ន្ធជាមួយតួអង្គផ្សេងៗ រួមមាន៖ អាជីវកម្ម, អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នសិក្សាស្រាវជ្រាវ នឹងបង្កើតបានអភិក្រមរួមមួយ សំដៅសម្រេចគោលដៅរួម និងធានានូវផលជះជាវិជ្ជមាននៃប្រព័ន្ធលទ្ធកម្មប្រកបដោយនិរន្តរភាព។ ជាចុងក្រោយ ការចងក្រងឯកសារ និងការចែករំលែកមេរៀនដកពិសោធន៍ នឹងរួមចំណែកដល់ការកែលម្អជាបន្តបន្ទាប់ ជួយបណ្តាប្រទេសក្នុងកែលម្អយុទ្ធសាស្ត្ររបស់ខ្លួន និងក្សាំខ្លួនតាមបញ្ហាប្រឈមដែលកើតចេញពីការវិវឌ្ឍប្រែប្រួលឥតឈប់ឈររបស់និរន្តរភាព។

របាយការណ៍នេះ ជាស្នាដៃរបស់ក្រុមអ្នកជំនាញគាំទ្រគោលនយោបាយរបស់ EU SWITCH-Asia ដែលជាគម្រោងប្រឹក្សាបច្ចេកទេស ស្តីពីលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព/បៃតង។ គោលបំណងនៃរបាយការណ៍នេះ គឺផ្តល់ទិដ្ឋភាពរួមមួយជុំវិញបទពិសោធន៍និងការអនុវត្តល្អៗស្តីពីលទ្ធកម្មសាធារណៈបៃតងនៅតាមបណ្តាប្រទេសចំនួនប្រាំនៅអាស៊ី រួមមាន៖ ចិន ឡាវ ម៉ាឡេស៊ី ថៃ និងវៀតណាម។ យើងសង្ឃឹមថា របាយការណ៍នេះអាចក្លាយជាធនធានមានប្រយោជន៍មួយ សម្រាប់អ្នករៀបចំតាក់តែងគោលនយោបាយ តួអង្គពាក់ព័ន្ធ និងអ្នកអនុវត្តផ្ទាល់ សម្រាប់យកទៅសិក្សារៀនសូត្រ និងដកស្រង់បទពិសោធន៍អំពីមាគ៌ាជាអន្តរជាតិ ដែលប្រទេសទាំងនេះបានប្រើប្រាស់ នៅក្នុងការតម្រង់ទិសប្រព័ន្ធលទ្ធកម្មសាធារណៈឱ្យស្របតាមគោលការណ៍និរន្តរភាព។

# ២. ប្រទេសចិន



## គោលនយោបាយ

គំនិតផ្តួចផ្តើមស្តីពីលទ្ធកម្មសាធារណៈបៃតង (GPP) នៅក្នុងប្រទេសចិន ចាប់ផ្តើមនៅឆ្នាំ២០០២ ជាមួយនឹងការអនុម័តច្បាប់លទ្ធកម្មរបស់រដ្ឋាភិបាល និងច្បាប់លើកកម្ពស់ផលិតកម្មស្អាត នៃសាធារណៈរដ្ឋប្រជាមានិតចិន។

## ភក្ខាជោគជ័យធំៗ

ក្របខ័ណ្ឌបទប្បញ្ញត្តិ ដែលបង្កើតឡើងដោយក្រសួងការពារបរិស្ថាន និងក្រសួងហិរញ្ញវត្ថុ ផ្តល់ការណែនាំច្បាស់លាស់សម្រាប់ការធ្វើលទ្ធកម្មផលិតផលបៃតង ដែលមានក្នុងបញ្ជីប្រភេទផលិតផល ដែលមានស្លាកសញ្ញាសន្សំសំចៃថាមពល និងមានមេត្រីបរិស្ថាន។

## មហិច្ឆតា

ពង្រីកវិសាលភាពបញ្ជីផលិតផលលទ្ធកម្មរបស់រដ្ឋាភិបាល ដើម្បីបញ្ចូលផលិតផល និងសេវាកម្មដែលមានឥទ្ធិពលខ្លាំងជាងមុន។

## ការផ្តោត

សម្ភារសំណង់, ផលិតផល ICT, ផលិតផលធ្វើពីឈើ, ឧបករណ៍សន្សំសំចៃទឹក, យានយន្តអគ្គិសនី, សម្ភារការិយាល័យ។

## ២.១. សេចក្តីផ្តើម

ដំណើរវិវឌ្ឍនៃលទ្ធកម្មសាធារណៈបៃតងនៅប្រទេសចិន បានចាប់ផ្តើមតាំងពីទសវត្សរ៍ឆ្នាំ១៩៩០ រហូតដល់បច្ចុប្បន្ន ដោយបានបង្ហាញ ពីការប្តេជ្ញាចិត្តចំពោះការទម្លាប់អនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាព។ ការសិក្សាដកស្រង់បទពិសោធន៍នេះ ពិនិត្យមើលលើកិច្ចខិតខំរួមគ្នារបស់គណៈកម្មការអភិវឌ្ឍន៍ និងកំណែទម្រង់ជាតិ (NDRC) ក្រសួងហិរញ្ញវត្ថុ និងក្រសួងការពារបរិស្ថាន ក្នុងការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព (SPP)[1]។ នៅក្នុងការរៀបចំស្ថាប័ន គេមានការសម្របសម្រួលអន្តរក្រសួង ដោយក្នុងនោះ គណៈកម្មការអភិវឌ្ឍន៍ និងកំណែទម្រង់ជាតិ ជាអ្នកដើរតួនាំមុខ ជាមួយការគាំទ្រសំខាន់ពីក្រសួងការបរទេស ហើយក្រសួងការពារបរិស្ថានដើរតួជាអ្នកគ្រប់គ្រងផលិតផលស្លាកមេត្រីបរិស្ថាន (ELP)។ នៅកម្រិតមូលដ្ឋាន មជ្ឈមណ្ឌលលទ្ធកម្មសាធារណៈ (PPCs) ដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តកិច្ចលទ្ធកម្មបៃតង។ ក្របខ័ណ្ឌដ៏ស្មុគស្មាញនេះ ឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់ប្រទេសចិន ក្នុងការប្រេបាច់បញ្ចូលនិរន្តរភាពទៅក្នុងប្រព័ន្ធលទ្ធកម្ម ដោយសង្កត់ធ្ងន់លើកិច្ចសហការ និងយុទ្ធសាស្រ្តទូលំទូលាយសម្រាប់ពង្រឹងលទ្ធកម្មសាធារណៈបៃតងប្រកបដោយភាពប្រាកដនិយម។

## ២.២. ការបង្កើតគោលនយោបាយ

ប្រព័ន្ធលទ្ធកម្មសាធារណៈរបស់ប្រទេសចិន បានចាប់ផ្តើមនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០។ ដំណើរការនៃការបង្កើតគោលនយោបាយលទ្ធកម្មសាធារណៈបៃតងនៅប្រទេសចិន អាចបែងចែកជាបីដំណាក់កាលដូចខាងក្រោម៖[2]

---

1 លទ្ធកម្មសាធារណៈបៃតង (GPP) និងលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព (SPP) ជាពាក្យសព្ទ ដែលត្រូវបានគេប្រើឆ្លាស់គ្នា ជាញឹកញាប់។ ពាក្យសព្ទ 'GPP' ត្រូវបានដាក់ឱ្យប្រើមុនពាក្យសព្ទ 'SPP'។ លក្ខណៈវិនិច្ឆ័យរបស់ GPP ច្រើនតែផ្តោតលើទិដ្ឋភាពបរិស្ថានរបស់ផលិតផលដែលត្រូវបានធ្វើលទ្ធកម្ម។ ចំណែកលក្ខណៈវិនិច្ឆ័យរបស់ SPP វិញ វាមានលក្ខណៈគ្រប់ជ្រុងជ្រោយជាង ដោយរួមមានទាំងសូចនាករបរិស្ថាន, សង្គម និងសេដ្ឋកិច្ច ទៀតផង។ យ៉ាងណាក៏ដោយ ពាក្យសព្ទ GPP និង SPP មានគោលដៅដូចគ្នា គឺលើកកម្ពស់ទម្លាប់អនុវត្តមានការទទួលខុសត្រូវក្នុងការជាវផលិតផល។

2 Qiao and Wang (2011). China Green Public Procurement Programme: Issues and Challenges in its Implementation. Available at https://www.ippa.org/IPPC4/Proceedings/07GreenProcurement/Paper7-6.pdf Accessed on 25.11.2023

**ដំណាក់កាលរៀបចំ (១៩៩៣–២០០៣)៖** ដំណាក់កាលនេះផ្តើមដោយការធ្វើសេចក្តីព្រាងច្បាប់លទ្ធកម្ម ក្នុងឆ្នាំ១៩៩៣ បន្ទាប់មកទៀតគឺមានកម្មវិធីសាកល្បង នៅទីក្រុងសៀងហៃ និងស៊ិនជិន។ ការបង្កើតឡើងនូវប្រព័ន្ធដាក់ដេញថ្លៃសម្រាប់លទ្ធកម្មសាធារណៈ, អង្គភាពលទ្ធកម្មនៃរដ្ឋបាលមូលដ្ឋាន និង ការអនុម័តច្បាប់លទ្ធកម្ម និងច្បាប់លើកកម្ពស់ផលិតកម្មស្អាតនៃសាធារណៈរដ្ឋប្រជាមានិតចិន ក្នុងឆ្នាំ២០០២ សុទ្ធតែជាសមិទ្ធផលសំខាន់ៗ នៅក្នុងដំណាក់កាលនៃការរៀបចំក្របខ័ណ្ឌគោលនយោបាយ និងច្បាប់។

**ដំណាក់កាលទី២ (២០០៤–២០០៧)៖** ក្នុងដំណាក់កាលនេះ ច្បាប់មួយចំនួនសំដៅលើកកម្ពស់លទ្ធកម្មសាធារណៈបៃតងត្រូវបានអនុម័តដើម្បីឆ្លើយតបទៅទស្សនាទានថ្មីៗនៃការអភិវឌ្ឍតាមបែបវិទ្យាសាស្ត្រ ដែលសង្កត់ធ្ងន់លើការអភិវឌ្ឍដែលតម្រង់ទិស "បម្រើផលប្រយោជន៍ប្រជាជន" និង "ការអភិវឌ្ឍមានលក្ខណៈទូលំទូលាយគ្រប់ជ្រុងជ្រោយ មានការសម្របសម្រួល និងប្រកបដោយនិរន្តរភាព"។ កម្រងច្បាប់ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្ត រួមមាន៖ *សេចក្តីជូនដំណឹងស្តីពីសកម្មភាពសន្សំធនធានដោយលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារដ្ឋ, ឯកសារជំនួយស្មារតីអំពីការអនុវត្តកិច្ចលទ្ធកម្មរដ្ឋាភិបាលសម្រាប់ផលិតផលមានប្រសិទ្ធភាពថាមពល, សេចក្តីសម្រេចស្តីពី ការអនុវត្តគោលគំនិតអភិវឌ្ឍន៍វិទ្យាសាស្ត្រដោយការពង្រឹងការការពារបរិស្ថានឆ្នាំ២០០៥, ឯកសារជំនួយស្មារតីស្តីពីការអនុវត្តលទ្ធកម្មរដ្ឋាភិបាលសម្រាប់ផលិតផលបិទស្លាកមេត្រីបរិស្ថានឆ្នាំ២០០៦។*

**ដំណាក់កាលអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយ (២០០៧ – បច្ចុប្បន្ន)៖** ដំណាក់កាលនេះត្រូវបានសម្គាល់ដោយកិច្ចខិតខំរបស់ប្រទេសចិន ក្នុងការបំពេញលក្ខខណ្ឌតម្រូវនៃកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក ស្តីពីលទ្ធកម្មរបស់រដ្ឋាភិបាល។ ច្បាប់ផ្សេងៗត្រូវបានអនុម័តដើម្បីជំរុញ និងលើកកម្ពស់លទ្ធកម្មសាធារណៈបៃតង រួមមាន៖ *ច្បាប់ជាតិស្តីពីការការពារបរិស្ថាន, ច្បាប់ស្តីពីការលើកកម្ពស់សេដ្ឋកិច្ចចក្រា, សេចក្តីជូនដំណឹងស្តីពីការបង្កើតប្រព័ន្ធលទ្ធកម្មរបស់រដ្ឋាភិបាលជាកាតព្វកិច្ចសម្រាប់ផលិតផលសន្សំសំចៃថាមពល និងសេចក្តីជូនដំណឹងស្តីពីបញ្ជីសាធារណៈស្តីពីការជាវផលិតផលដែលមានការកែសម្រួលស្លាកមេត្រីបរិស្ថាន។*

ដំណាក់កាលទាំងនេះឆ្លុះបញ្ចាំងពីការវិវត្តបន្តិចម្តងៗ និងការពង្រឹងគោលនយោបាយលទ្ធកម្មសាធារណៈបៃតង នៅប្រទេសចិន ដែលបង្ហាញពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការការពារបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការអនុវត្តកិច្ចលទ្ធកម្ម។

## ២.៣. ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ

នៅប្រទេសចិន ក្របខ័ណ្ឌច្បាប់ស្តីពីលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព (SPP) ត្រូវបានបង្កើតឡើងតាមរយៈកិច្ចខិតខំរួមគ្នា ក្រោមការដឹកនាំសម្របសម្រួលដោយ**គណៈកម្មាធិការអភិវឌ្ឍន៍ និងកំណែទម្រង់ជាតិ (NDRC) ក្រសួងហិរញ្ញវត្ថុ (MoF) និងក្រសួងការពារបរិស្ថាន (MEP)។ មជ្ឈមណ្ឌលលទ្ធកម្មសាធារណៈ** ដើរតួនាទីយ៉ាងសំខាន់ក្នុងការបកស្រាយ និងអនុវត្តគោលការណ៍ណែនាំលទ្ធកម្ម ដែលខ្លួនបានដាក់ចេញ និងគ្រប់គ្រងដំណើរការលទ្ធកម្មជាក់ស្តែងសម្រាប់គ្រប់អង្គភាពរដ្ឋបាលផ្សេងៗ។

មូលដ្ឋានគ្រឹះផ្នែកច្បាប់សម្រាប់លទ្ធកម្មសាធារណៈ និងលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព រួមមានច្បាប់ស្តីពី**ការប្រកាសដេញថ្លៃប្រកួតប្រជែង ឆ្នាំ១៩៩៩, ច្បាប់ស្តីពីការលើកកម្ពស់ផលិតកម្មស្អាត ឆ្នាំ២០០២ និងច្បាប់ស្តីពីលទ្ធកម្មរបស់រដ្ឋាភិបាល ឆ្នាំ២០០៣**។ ច្បាប់ស្តីពីលទ្ធកម្មរបស់រដ្ឋាភិបាល ដែលត្រូវបានធ្វើការកែសម្រួលក្នុងឆ្នាំ២០១៥ ផ្តោតលើការធ្វើនិយ័តលើការបញ្ជាទិញដោយបណ្តាទីភ្នាក់ងាររបស់រដ្ឋាភិបាលថ្នាក់មជ្ឈិម។ ច្បាប់នេះលើកទឹកចិត្តដល់ការប្រើប្រាស់លទ្ធកម្មសាធារណៈ ដើម្បីលើកកម្ពស់ផលិតផល និងសេវាកម្មមាន មេត្រីបរិស្ថាន។ ដូចគ្នានេះដែរ ច្បាប់ស្តីពីផលិតកម្មស្អាត ឆ្នាំ២០០២ ក៏សង្កត់ធ្ងន់លើការធ្វើលទ្ធកម្មផលិតផលពេញនិយមដែលមានមេត្រីបរិស្ថាន និងប្រសិទ្ធផលធនធាន។

**ច្បាប់ស្តីពីការលើកកម្ពស់សេដ្ឋកិច្ចចក្រារបស់ប្រទេសចិនឆ្នាំ២០០៩** ពង្រឹងបន្ថែមដល់ការប្តេជ្ញាចិត្តក្នុងការធ្វើលទ្ធកម្មផលិតផលដែលមានអត្ថប្រយោជន៍សម្រាប់សេដ្ឋកិច្ចកែច្នៃ, ប្រសិទ្ធភាពថាមពល, ការអភិរក្សទឹក និងមេត្រីភាពបរិស្ថាន។ គោលការណែនាំអំពីការអនុវត្ត និងបញ្ជីលទ្ធកម្មសាធារណៈសម្រាប់ផលិតផលសន្សំថាមពល និងស្លាកមេត្រីបរិស្ថាន ត្រូវបានដាក់ចេញឱ្យអនុវត្តសម្រាប់គ្រប់ភ្នាក់ងារសាធារណៈ ។

ច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសចិនពាក់ព័ន្ធទៅនឹងលទ្ធកម្មសាធារណៈបៃតង មានចែងលំអិតនៅក្នុង តារាងទី១។

**តារាងទី១៖** ច្បាប់ និងបទប្បញ្ញត្តិរបស់ចិនពាក់ព័ន្ធលទ្ធកម្មសាធារណៈបៃតង (GPP)[3]

| ឆ្នាំ | ច្បាប់/បទប្បញ្ញត្តិ | ស្ថាប័នចេញច្បាប់ | សារៈសំខាន់ពាក់ព័ន្ធ |
|---|---|---|---|
| ១៩៩៩ | ច្បាប់ស្តីពីការប្រកាសដេញថ្លៃ ប្រកួតប្រជែង | បទប្បញ្ញត្តិលទ្ធកម្មសម្រាប់ សហគ្រាសចំណុះឱ្យរដ្ឋ | បង្កើតប្រព័ន្ធដេញថ្លៃ សម្រាប់លទ្ធកម្មសាធារណៈ |
| ២០០២ | ច្បាប់ស្តីពីការលើកកម្ពស់ផលិតកម្មស្អាត Promotion of Cleaner Production Law | ចេញដោយ គណៈកម្មាធិការអចិន្ត្រៃយ៍ នៃសមាជជាតិរបស់ ប្រជាជនចិន | មាត្រា ១៦ ចែងថា រដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ត្រូវផ្តល់ អាទិភាពដល់ការទិញផលិតផលដែលអំណោយផល ដល់ការអភិរក្សថាមពល និងទឹក ការប្រើប្រាស់ឡើងវិញ នូវកាកសំណល់ ការការពារបរិស្ថាន និងការអភិរក្ស ធនធាន។ |
| ២០០៣ | ច្បាប់លទ្ធកម្មរបស់រដ្ឋាភិបាល Government Procurement Law (GPL) | រៀបចំធ្វើដោយ ក្រសួងហិរញ្ញវត្ថុ ហើយ អនុវត្តដោយ សមាជជាតិ របស់ប្រជាជនចិន | មាត្រា៩ តម្រូវឱ្យប្រើលទ្ធកម្មរបស់រដ្ឋាភិបាល សម្រាប់ ការពារបរិស្ថាន។ លទ្ធកម្មរបស់រដ្ឋាភិបាលគួរតែត្រូវបាន ប្រើប្រាស់ដើម្បីលើកកម្ពស់ផលិតផលដែលមានមេត្រី បរិស្ថាន និងដើម្បីទទួលបានទំនិញដែលត្រូវតាមស្តង់ ដាការពារបរិស្ថាន។ |
| ២០០៤ | លិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងសម្រាប់ការអនុវត្តលទ្ធកម្ម របស់រដ្ឋាភិបាលសម្រាប់ផលិតផល មានប្រសិទ្ធភាពថាមពល (ECPs) | ចេញដោយ ក្រសួងហិរញ្ញវត្ថុ និង គណៈកម្មការអភិវឌ្ឍន៍ និងកំណែទម្រង់ជាតិ (NDRC) | ផ្តល់អាទិភាពចំពោះផលិតផលពេញនិយមដែលសន្សំ ថាមពលសម្រាប់លទ្ធកម្មរបស់ក្រសួង-ស្ថាប័ននៃ រដ្ឋាភិបាល |
| ២០០៦ | លិខិតបទដ្ឋានគតិយុត្តក្រសួង ស្តីពីលទ្ធកម្មរដ្ឋាភិបាលសម្រាប់ ផលិតផលដែលមានស្លាកមេត្រី បរិស្ថាន(ELPs) | ចេញដោយ ក្រសួងហិរញ្ញវត្ថុ និង ក្រសួងការពារបរិស្ថាន | ផ្តល់អាទិភាព ចំពោះផលិតផលពេញនិយមដែលមាន បិទស្លាកមេត្រីបរិស្ថាន សម្រាប់អនុវត្តកិច្ចលទ្ធកម្មរបស់ រដ្ឋាភិបាល |
| ២០០៧ | លិខិតបទដ្ឋានគតិយុត្តស្តីពី លទ្ធកម្ម របស់រដ្ឋាភិបាលសម្រាប់ ផលិតផលសន្សំសំចៃថាមពល | លិខិតបទដ្ឋានគតិយុត្ត ចេញដោយក្រុមប្រឹក្សារដ្ឋ | ជាកាតព្វកិច្ចសម្រាប់ភ្នាក់ងាររដ្ឋាភិបាលក្នុងការទិញ ផលិតផល សន្សំសំចៃថាមពល ដូចជាម៉ាស៊ីនត្រជាក់ អំពូលហ្លួរ៉េសិន ទូទស្សន៍ ម៉ាស៊ីនកម្តៅអគ្គិសនី កុំព្យូទ័រ ម៉ាស៊ីនព្រីន ម៉ូនីទ័រ បង្គន់នោម និងក្បាលរ៉ូប៊ីនេទឹក |
| ២០០៧ | ច្បាប់វិសោធនកម្មស្តីពីការអភិរក្ស ថាមពល Revision of Energy Conservation Law | ច្បាប់ចេញដោយក្រុម ប្រឹក្សារដ្ឋ | ស្ថាប័នសាធារណៈមានកាតព្វកិច្ចផ្តល់ អាទិភាពនៅក្នុង ការអនុវត្តកិច្ចលទ្ធកម្មរបស់ពួកគេចំពោះផលិតផល និង ឧបករណ៍ដែលមាននៅក្នុងបញ្ជីលទ្ធកម្មរបស់រដ្ឋាភិបាល ស្តីពីផលិតផលសន្សំសំចៃថាមពល (ECPs) និងគ្រឿង បរិក្ខារផ្សេងៗ។ |
| ២០០៩ | ច្បាប់ស្តីពីការលើកកម្ពស់ សេដ្ឋកិច្ចចក្រា Circular Economy Promotion Law | ច្បាប់ចេញដោយក្រុម ប្រឹក្សារដ្ឋ | ភាពអនុគ្រោះផ្នែកលទ្ធកម្មត្រូវបានផ្តល់ឱ្យចំពោះ ផលិតផលដែលសន្សំសំចៃថាមពល/ទឹក មិនធ្វើឱ្យ ប៉ះពាល់ដល់បរិស្ថាន និងជាផលិតផលកកើតឡើងវិញ។ |

3 UNEP (2017) ការវិភាគប្រៀបធៀបនៃកម្មវិធីលទ្ធកម្មសាធារណៈបៃតង និងកម្មវិធីស្លាកមេត្រីបរិស្ថាន នៅប្រទេសចិន ជប៉ុន ថៃ និងសាធារណរដ្ឋកូរ៉េ៖ មេរៀន ដកពិសោធ និងកត្តាជោគជ័យទូទៅ។.

| ឆ្នាំ | ច្បាប់/បទប្បញ្ញត្តិ | ស្ថាប័នចេញច្បាប់ | សារៈសំខាន់ពាក់ព័ន្ធ |
|---|---|---|---|
| ២០១១ | លិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តច្បាប់ស្តីពីការប្រកាសដេញថ្លៃប្រកួតប្រជែង Regulations for the Implementation of the Tendering and Bidding Law | ច្បាប់ចេញដោយក្រុមប្រឹក្សារដ្ឋ | ផ្តល់សិទ្ធអំណាចដល់ក្រសួងហិរញ្ញវត្ថុក្នុងការត្រួតពិនិត្យទាក់ទងនឹងការគ្រប់គ្រងថវិកា និងគោលនយោបាយរួមនៅក្នុងជួររដ្ឋាភិបាល និងលទ្ធកម្មក្នុងវិស័យសំណង់ |

## ២.៤. ការរៀបចំស្ថាប័ន

ការរៀបចំស្ថាប័នសម្រាប់លទ្ធកម្មសាធារណៈបៃតងនៅប្រទេសចិន មានការពាក់ព័ន្ធជាមួយទីភ្នាក់ងារ និងក្រសួងជាច្រើន។ ទីភ្នាក់ងារ និងក្រសួងជាច្រើនបានចូលរួមក្នុងដំណើរការគ្រប់គ្រងលទ្ធកម្មបៃតង ក្នុងនោះមានៈ ក្រសួងការពារបរិស្ថាន ក្រសួងហិរញ្ញវត្ថុ គណៈកម្មាធិការអភិវឌ្ឍន៍ និងកំណែទម្រង់ជាតិ រួមទាំងអង្គភាព/មជ្ឈមណ្ឌលលទ្ធកម្មផ្សេងៗនៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានទៀតផង។

នៅថ្នាក់ជាតិ គណៈកម្មាធិការអភិវឌ្ឍន៍ និងកំណែទម្រង់ជាតិ និងក្រសួងការពារបរិស្ថាន មានតួនាទីស្នូលក្នុងការដឹកនាំសម្របសម្រួល និងគ្រប់គ្រងដំណើរការការអនុវត្ត SPP ដោយមានក្រសួងពាណិជ្ជកម្ម និង ក្រសួងហិរញ្ញវត្ថុ ផ្តល់ការគាំទ្រក្នុងការសម្របសម្រួលតួអង្គទីផ្សារ និងហិរញ្ញប្បទានផ្សេងៗ។ ដូច្នេះ ទីភ្នាក់ងារទាំងនេះមានការទទួលខុសត្រូវខ្ពស់ ក្នុងការរៀបចំសេចក្តីណែនាំផ្លូវច្បាប់, ច្បាប់, និងគោលការណ៍ណែនាំនានា សម្រាប់ការបង្កើតប្រព័ន្ធលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាពកម្រិតយុទ្ធសាស្ត្រនៅក្នុងប្រទេសចិន។ ផ្នែកខាងក្រោមរៀបរាប់លម្អិតអំពីតួនាទីរបស់តួអង្គ និងស្ថាប័នសំខាន់ៗ។ ការរៀបចំស្ថាប័នសម្រាប់ដឹកនាំសម្របសម្រួលលទ្ធកម្មសាធារណៈបៃតង នៅប្រទេសចិនក៏មានបង្ហាញជូនក្នុងគំនូសតាងទី១ ។




**គំនូសតាងទី១៖** ក្របខ័ណ្ឌស្ថាប័នរបស់លទ្ធកម្មសាធារណៈបៃតង នៅប្រទេសចិន

## ២.៥. គណៈកម្មាធិការអភិវឌ្ឍន៍ និងកំណែទម្រង់ជាតិ (NDRC)

ចាប់តាំងពីឆ្នាំ២០០៥ គណៈកម្មាធិការអភិវឌ្ឍន៍ និងកំណែទម្រង់ជាតិ បានក្លាយជាស្ថាប័នដឹកនាំសម្របសម្រួលអន្តរក្រសួងមួយ ដែលត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សារដ្ឋ។ យន្តការសម្របសម្រួលអន្តរក្រសួងនេះ សម្រាប់អនុវត្តនិតិវិធី និងដំណើរការដេញថ្លៃ មានភារកិច្ចដូចខាងក្រោម៖

- ធ្វើការវាយតម្លៃវិធានដេញថ្លៃបច្ចុប្បន្ន និងស្វែងរកដំណោះស្រាយ ដើម្បីគ្រប់គ្រងសកម្មភាពដេញថ្លៃដែលពាក់ព័ន្ធជាមួយនាយកដ្ឋាននានាក្នុងរដ្ឋាភិបាល,
- គ្រប់គ្រងវិវាទរវាងនាយកដ្ឋាននៅក្នុងរដ្ឋាភិបាល ពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យលើដំណើរការដេញថ្លៃ,
- ចែករំលែកព័ត៌មានទូលំទូលាយ
- ធ្វើការសម្របសម្រួលជុំវិញការប្រកាសដាក់ឱ្យប្រើប្រាស់នូវលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលនឹងត្រូវអនុវត្តដោយនាយកដ្ឋានពាក់ព័ន្ធនៃក្រសួង-ស្ថាប័ន,
- ធ្វើការប្រាស្រ័យទាក់ទងអំពីការពង្រឹងការអនុវត្តវិធាននៃការដេញថ្លៃ,
- ធ្វើការស្ទង់ និងស្រាវជ្រាវរួមគ្នា,
- ត្រួតមើលពីលើសកម្មភាពដេញថ្លៃរបស់រដ្ឋាភិបាល និងសហគ្រាសចំណុះរដ្ឋទាំងអស់ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីការដេញថ្លៃ,
- គ្រប់គ្រង និងធ្វើការបោះពុម្ពផ្សាយបញ្ជីឈ្មោះផលិតផលសន្សំសំចៃថាមពល ដោយសហការជាមួយក្រសួងហិរញ្ញវត្ថុ។

### ២.៥.១. ក្រសួងហិរញ្ញវត្ថុ

- ភាគច្រើនដើរតួនាទីជាអ្នកជួយគាំទ្រនៅតាមកម្រិតផ្សេងនៃដំណើរការលទ្ធកម្មសាធារណៈបៃតង នៅប្រទេសចិន។
- ជាអ្នករៀបចំកាតាឡុកជារួមមួយ (Centralized Purchasing/CP) សម្រាប់កម្មវិធីលទ្ធកម្មសាធារណៈបៃតង។
- គ្រប់គ្រងរួមគ្នាបញ្ជីផលិតផលសន្សំថាមពល (ECL) និងបញ្ជីផលិតផលបិទស្លាកមេត្រីបរិស្ថាន (ELP) ជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ និងកំណែទម្រង់ជាតិ និងក្រសួងការពារបរិស្ថាន។
- បង្កើតមជ្ឈមណ្ឌលលទ្ធកម្មកណ្តាលនានា ដោយសម្របសម្រួលជាមួយក្រសួងពាណិជ្ជកម្ម។
- ផ្តល់ការគាំទ្រក្នុងការសម្របសម្រួលទីផ្សារ និងហិរញ្ញប្បទានសម្រាប់កម្មវិធីលទ្ធកម្មសាធារណៈបៃតង។
- គ្រប់គ្រងប្រព័ន្ធលទ្ធកម្មមជ្ឈការរបស់រដ្ឋាភិបាល ដោយបង្កើតកាតាឡុកជារួមមួយ (Centralized Purchasing Catalogue) ដែល អនុម័តដោយក្រុមប្រឹក្សារដ្ឋ និងរដ្ឋាភិបាលខេត្ត។
- មើលការខុសត្រូវទូទៅ និងជួយនាយកដ្ឋានរដ្ឋាភិបាលនានា ក្នុងការបង្កើតមជ្ឈមណ្ឌលលទ្ធកម្មកណ្តាលរបស់ពួកគេ។
- បែងចែកធុរកិច្ចលទ្ធកម្មទៅតាមមជ្ឈមណ្ឌលលទ្ធកម្មផ្សេងៗ។
- សហការគ្នាជាមួយនាយកដ្ឋានហិរញ្ញវត្ថុរបស់រដ្ឋាភិបាលមូលដ្ឋាន ក្នុងការដោះស្រាយបណ្តឹងតវ៉ារបស់អ្នកផ្គត់ផ្គង់ទំនិញ។
- ដើរតួជាអាជ្ញាធរត្រួតពិនិត្យដោយមានចក្ខុវិស័យពេញលេញក្នុងការតម្រង់ទិសនីតិវិធីរួមសម្រាប់លទ្ធកម្មសាធារណៈ និងខ្សែចង្វាក់បញ្ហាកិច្ចលទ្ធកម្ម។
- ដើរតួជាអ្នកចរចារបស់ប្រទេសចិន លើកិច្ចព្រមព្រៀងពាណិជ្ជកម្មលទ្ធកម្មរបស់រដ្ឋាភិបាល សម្រាប់ការចូលជាសមាជិកនៃកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក។
- ដើរតួនាទីយ៉ាងសំខាន់នៅក្នុងគោលនយោបាយរបស់ចិន ស្តីពីការប្រើប្រាស់ប្រកបដោយនិរន្តរភាព តាមរយៈការផ្សព្វផ្សាយជាទៀងទាត់នូវសេចក្តីជូនដំណឹង និងវិធានស្តីពីការអនុវត្តសម្រាប់ផលិតផលជាក់លាក់ ចាប់តាំងពីឆ្នាំ២០១០ មក។

### ២.៥.២. ក្រសួងបរិស្ថាន

- ក្រសួងការពារបរិស្ថានផ្តួចផ្តើមរៀបចំ និងអនុវត្តលទ្ធកម្មផ្តោតលើផលិតផលបិទស្លាកមេត្រីបរិស្ថានក្នុងប្រទេសចិន។ ក្រសួងនេះក៏សហការជាមួយក្រសួងហិរញ្ញវត្ថុផងដែរ ក្នុងការគ្រប់គ្រង និងបោះពុម្ពផ្សាយបញ្ជីផលិតផលបិទស្លាកមេត្រីបរិស្ថាន។

### ២.៥.៣. មជ្ឈមណ្ឌលលទ្ធកម្មសាធារណៈ

បើនិយាយអំពីរចនាសម្ព័ន្ធស្ថាប័នវិញនោះ លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាពនៅប្រទេសចិន ត្រូវបានរៀបចំជាលក្ខណៈប្រមូលផ្តុំនៅថ្នាក់មូលដ្ឋាន។ មជ្ឈមណ្ឌលលទ្ធកម្មសាធារណៈនៅថ្នាក់មូលដ្ឋាន (PPCs) ទទួលខុសត្រូវផ្តាច់មុខ លើសកម្មភាពលទ្ធកម្មទាំងអស់ រួមទាំងការផ្តល់ព័ត៌មានលទ្ធកម្ម, ការសម្របសម្រួលការវាយតម្លៃលើសំណើដេញថ្លៃ និងការផ្តល់កិច្ចសន្យាជាដើម។ តាមរយៈរចនាសម្ព័ន្ធនេះ មជ្ឈមណ្ឌលលទ្ធកម្មសាធារណៈនៅថ្នាក់មូលដ្ឋានរួមជាមួយអង្គភាពរដ្ឋាភិបាល និងស្ថាប័នសាធារណៈផ្សេងទៀត ដើរតួនាទីជាប្រតិបត្តិករដ៏ចម្បងដែលចូលរួមក្នុងដំណើរការលទ្ធកម្មនៅទូទាំងប្រទេសចិន។[4]

ការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលលទ្ធកម្មសាធារណៈ មានដូចតទៅ៖

- ធ្វើលទ្ធកម្មតាមរយៈកាតាឡុកទិញរបស់ថ្នាក់មជ្ឈិម និងថ្នាក់មូលដ្ឋាន។
- ធ្វើការសម្របសម្រួល និងអនុវត្តលទ្ធកម្មបៃតង សម្រាប់ផលិតផលសន្សំថាមពល និងផលិតផលបិទស្លាកមេត្រីបរិស្ថាន ស្របតាមបញ្ជីលទ្ធកម្មចុងក្រោយគេ។
- ធ្វើការផ្ទៀងផ្ទាត់មើលថាតើ គំរូផលិតផលដែលអ្នកផ្គត់ផ្គង់លើកសំណើឡើង មាននៅក្នុងបញ្ជីកាតាឡុកដែរឬទេ។ អ្នកជំនាញវាយតម្លៃសំណើដាក់ដេញថ្លៃ ចាំបាច់ត្រូវផ្ទៀងផ្ទាត់មើលគំរូផលិតផលដែលបានកំណត់ និងផ្តល់ការណែនាំគោលនយោបាយរួមទៅឱ្យមជ្ឈមណ្ឌលលទ្ធកម្មសាធារណៈដើម្បីធ្វើប្រតិបត្តិការជាក់ស្តែង។
- គ្រប់គ្រងដំណើរការលទ្ធកម្មសម្រាប់អង្គភាពសេវាសាធារណៈ រួមទាំងរដ្ឋបាលក្រុង ស្ថាប័នសាធារណៈ សាកលវិទ្យាល័យ មន្ទីរពេទ្យ និងសហគ្រាសរដ្ឋ។
- ធ្វើប្រតិបត្តិការនៅតាមកម្រិតផ្សេងៗរបស់រដ្ឋាភិបាល ជាពិសេស ផ្តោតសំខាន់ទៅលើកម្រិតមូលដ្ឋាន (ក្រុង ស្រុក)។
- ដើរតួជាជំនួយការឱ្យការិយាល័យរដ្ឋបាលកម្រិតខ្ពស់ ដែលទទួលខុសត្រូវរួមលើដំណើរការលទ្ធកម្មសាធារណៈ។
- បង្កើតនីតិវិធីសម្រាប់ការគ្រប់គ្រងផ្ទៃក្នុង និងការប្រាស្រ័យទាក់ទងជាមួយអ្នកប្រើប្រាស់ និងអ្នកផ្គត់ផ្គង់។
- បំពេញមុខងារជាអន្តរការីលទ្ធកម្ម ដោយមិនទទួលថវិកាលទ្ធកម្មសាធារណៈបៃតង ផ្ទាល់ពីនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋានទេ។

### ២.៥.៤. មជ្ឈមណ្ឌលវិញ្ញាបនបត្រគុណភាពចិន (CQC)

មជ្ឈមណ្ឌលវិញ្ញាបនបត្របញ្ជាក់គុណភាពចិន មើលការខុសត្រូវរួមលើការអនុវត្តកម្មវិធីសន្សំថាមពល ហើយសហការជាមួយគណៈកម្មការអភិវឌ្ឍន៍ និងកំណែទម្រង់ជាតិ នៅក្នុងការរៀបចំបង្កើតបញ្ជីលទ្ធកម្មផលិតផលសន្សំថាមពល (ECL)។

### ២.៥.៥. មជ្ឈមណ្ឌលឯកភាពចិនផ្តល់វិញ្ញាបនបត្របរិស្ថាន (CEC)

មជ្ឈមណ្ឌលនេះ ជាអង្គភាពផ្តាច់មុខសម្រាប់ផ្តល់ស្លាកមេត្រីបរិស្ថាន ដែលសហការជាមួយក្រសួងការពារបរិស្ថានដើម្បីលើកកម្ពស់តួនាទីសំខាន់នៃស្តង់ដាបរិស្ថាន តាមរយៈការបង្កើតរបបវិញ្ញាបនបត្រ និងបញ្ជីផលិតផលបិទស្លាកមេត្រីបរិស្ថាន។

### ២.៥.៦. មជ្ឈមណ្ឌលអភិវឌ្ឍន៍បរិស្ថាន (EDC)

មជ្ឈមណ្ឌលអភិវឌ្ឍន៍បរិស្ថាន ស្ថិតក្រោមឱវាទក្រសួងការពារបរិស្ថាន គឺជាស្ថាប័នស្រាវជ្រាវដ៏សំខាន់មួយដែលទទួលខុសត្រូវក្នុងការបង្កើតស្តង់ដាស្លាកមេត្រីបរិស្ថានរបស់ប្រទេសចិន។ មជ្ឈមណ្ឌលនេះ ដើរតួនាទីជាស្ថាប័នត្រួតពិនិត្យមើលឡូហ្គោមេត្រីបរិស្ថានរបស់ប្រទេសចិន ដោយធានាឱ្យបាននូវការអនុលោម និងការប្រកាន់ខ្ជាប់តាមស្តង់ដាបរិស្ថាននៅទូទាំងប្រទេស។

## ២.៦. គោលការណ៍ណែនាំ និងលក្ខណៈវិនិច្ឆ័យ

នៅប្រទេសចិន អន្តរកម្មរវាងលទ្ធកម្មសាធារណៈបៃតង និងស្លាកសញ្ញាមេត្រីបរិស្ថាន ជាគន្លឹះក្នុងការលើកកម្ពស់ការអនុវត្តកិច្ច

4 Zhang et al. (2022). Managing Sustainable Public Procurement: A Nationwide Survey in China. Sustainability 14, 11955 https://doi.org/10.3390/su141911955

លទ្ធកម្មដែលគិតគូរពីបរិស្ថាន។ លទ្ធកម្មសាធារណៈបៃតងមានធាតុផ្សំសំខាន់ពីរ៖ បញ្ជីផលិតផលស្លាមេត្រីបរិស្ថាន និងបញ្ជីផលិតផលសន្សំថាមពល (ECL)។ បញ្ជីទាំងនេះកំណត់វិសាលភាពនៃលទ្ធកម្មបៃតងរបស់រដ្ឋាភិបាល ដោយរៀបរាប់លម្អិតអំពីផលិតផលដែលមេត្រីដល់បរិស្ថាន និងសន្សំថាមពល ព្រមទាំងបង្កើតនីតិវិធី វិធីសាស្ត្រ និងក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្ត។ រដ្ឋាភិបាលបានពង្រីកបន្តបញ្ជីទាំងពីរនេះ ដើម្បីបង្កើនវិសាលភាពរបស់លទ្ធកម្មសាធារណៈបៃតង ដោយសង្កត់ធ្ងន់លើការធ្វើសហកម្មរវាង លទ្ធកម្មសាធារណៈបៃតង និងស្លាកមេត្រីបរិស្ថាន។ ទំនាក់ទំនងនេះ ត្រូវបានគូសបញ្ជាក់កាន់តែច្បាស់ តាមរយៈការប្រើប្រាស់លក្ខណៈវិនិច្ឆ័យជាក់លាក់នៅក្នុងបញ្ជីទាំងនេះ ដើម្បីយកជាមូលដ្ឋានសម្រាប់ការសម្រេចចិត្តធ្វើលទ្ធកម្ម ដោយផ្តោតលើការការពារបរិស្ថាន និងការសន្សំថាមពល។

នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៦ ក្រសួងហិរញ្ញវត្ថុ និងអតីតរដ្ឋបាលការពារបរិស្ថានរបស់រដ្ឋ បានដាក់ចេញអនុសាសន៍ដែលចង្អុលអំពីការចាប់ផ្តើមនៃលទ្ធកម្មបៃតងរបស់រដ្ឋាភិបាលចិន (GGP)។ ឯកសារស្តីពីអនុសាសន៍ទាំងនោះកំណត់ដំណើរការលទ្ធកម្ម ចំណាត់ប្រភេទលទ្ធកម្ម និងលិខិតបទដ្ឋានគតិយុត្តដែលគាំទ្រដល់ការទទួលស្គាល់ផលិតផលមានស្លាកមេត្រីបរិស្ថាន។ "បញ្ជីផលិតផលមានស្លាកមេត្រីបរិស្ថាន" ត្រូវបានផ្សព្វផ្សាយតាមរយៈយន្តការជាក់លាក់ ជាពិសេស ក្រសួងហិរញ្ញវត្ថុ តាមរយៈគេហទំព័រ www.mof.gov.cn, ក្រសួងការពារបរិស្ថាន នៅអាសយដ្ឋានគេហទំព័រ www.mep.gov.cn, មជ្ឈមណ្ឌលលទ្ធកម្មរដ្ឋាភិបាលចិន តាមរយៈគេហទំព័រ www.ccgp.gov.cn, និងបណ្តាញលទ្ធកម្មបៃតងរបស់ប្រទេសចិន តាមរយៈគេហទំព័រ www.cgpn.org។ សាធារណៈជន និងអង្គភាពទិញមួយណាក៏ដោយ ក៏អាចទាញយកបញ្ជីទាំងនោះយកទៅប្រើការបានដែរ[5]។ លក្ខណៈសណ្ឋានសំខាន់ៗនៃបញ្ជីលទ្ធកម្មទាំងពីរ ត្រូវបានបង្ហាញជូននៅក្នុងតារាងទី២។

**តារាងទី២៖** លក្ខណៈសណ្ឋានសំខាន់ៗនៃបញ្ជីលទ្ធកម្មទាំងពីរ៖ បញ្ជីការទិញសាធារណៈនូវផលិតផលបិទស្លាកមេត្រីបរិស្ថាន និងបញ្ជីលទ្ធកម្មផលិតផលបិទស្លាកមេត្រីបរិស្ថាន

| ឈ្មោះ | បញ្ជីផលិតផលសន្សំថាមពល (ECL) | បញ្ជីផលិតផលបិទស្លាកសញ្ញាមេត្រីបរិស្ថាន (ELP) |
|---|---|---|
| ការផ្តល់វិញ្ញាបនបត្រ | វិញ្ញាបនបត្របញ្ជាក់ការសន្សំថាមពល | ស្លាកមេត្រីបរិស្ថានរបស់ចិន |
| អាជ្ញាធរផ្តល់វិញ្ញាបនបត្រ | មជ្ឈមណ្ឌលវិញ្ញាបនបត្របញ្ជាក់គុណភាពចិន (CQC) | មជ្ឈមណ្ឌលឯកភាពចិនផ្តល់វិញ្ញាបនបត្របរិស្ថាន (CEC) |
| បណ្តាក្រសួងគាំទ្រ | ក្រសួងហិរញ្ញវត្ថុ, គណៈកម្មការអភិវឌ្ឍន៍ និងកំណែទម្រង់ជាតិ អគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព, អធិការកិច្ច និង ចត្តាឡីស័ក (AQSIQ) | ក្រសួងហិរញ្ញវត្ថុ, ក្រសួងការពារបរិស្ថាន |
| ជាប់កំហិត ឬមានភាពអនុគ្រោះ | ផលិតផលមួយចំនួនត្រូវជាប់កំហិត | ផលិតផលទាំងអស់អនុវត្តគោលការណ៍ស្ម័គ្រចិត្ត |
| ឆ្នាំចាប់ផ្តើម | ២០០៤ | ២០០៦ |
| ចន្លោះអាប់ដេត | ពីរដងក្នុងមួយឆ្នាំ | ពីរដងក្នុងមួយឆ្នាំ |
| ចំនួនចំណាត់ថ្នាក់ប្រភេទផលិតផល នៅក្នុងកាតាឡុក (គិតត្រឹមឆ្នាំ២០១៩)[6] | ១៨ | ៥០ |

5 Available at https://www.oecd.org/governance/procurement/toolbox/search/china-best-practices-green-public-procurement-gpp-environmental-standards.pdf, Accessed on 01.11.2023

6 Available at https://certrip.org/china-adjusted-its-government-green-procurement-policy/ , Accessed on 13.11.2023

## ២.៧. កម្មវិធីកសាងសមត្ថភាព បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង

ជាទៀងទាត់ ក្រសួងហិរញ្ញវត្ថុតែងធ្វើការបណ្តុះបណ្តាលដល់អង្គភាពលទ្ធកម្មរបស់រដ្ឋាភិបាលមូលដ្ឋាន។ ដោយឡែក មជ្ឈមណ្ឌលលទ្ធកម្មថ្នាក់ខេត្ត ក៏មានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលរបស់ខ្លួន ទៅតាមការចាំបាច់ផងដែរ។

មជ្ឈមណ្ឌលអភិវឌ្ឍន៍បរិស្ថាន (EDC) ដែលនៅក្រោមឱវាទក្រសួងការពារបរិស្ថាន បានរៀបចំសន្និសីទផ្សេងៗ និងបង្កើត បណ្តាញទិញផលិតផលបៃតងរបស់ចិន (CGPN) ដើម្បីរួមចំណែកលើកកម្ពស់លទ្ធកម្មសាធារណៈបៃតង និងការប្រើប្រាស់ ប្រកបដោយនិរន្តរភាព។

ទាក់ទងនឹង "ការបោះពុម្ពផ្សាយអំពីផលិតផលបៃតង" ក្រសួងបរិស្ថាន និងអគ្គរដ្ឋបាលនៃសារព័ត៌មាន និងការបោះពុម្ពផ្សាយ (GAPP) បានចុះហត្ថលេខាជាមួយគ្នាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការលើការដាក់ "ស្លាកមេត្រីបរិស្ថានសម្គាល់ការបោះពុម្ព បៃតង"។ ការបោះពុម្ពបៃតង ទទួលរ៉ាប់រងការបោះពុម្ពសៀវភៅសិក្សាទាំងអស់សម្រាប់សាលាបឋមសិក្សា និងមធ្យមសិក្សា រហូតដល់ចុងឆ្នាំ២០១៣។ គិតមកដល់ពេលនេះ ការបោះពុម្ពបៃតងនេះមានក្រុមហ៊ុនបោះពុម្ពជាង ៩៩៣ ក្រុមហ៊ុនចូលរួម ហើយ តាមរយៈនេះ សៀវភៅសិក្សាចំនួន ៥០០លានក្បាលបានទទួលវិញ្ញាបនបត្រ "ស្លាកមេត្រីបរិស្ថានចិន" 'China Environmental Labelling' (UNEP, 2017)។

ចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១១ កិច្ចលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាពសម្រាប់គម្រោងនានានៅតាមរដ្ឋបាលទីក្រុងក្នុង ប្រទេសចិន (SuPP-Urb) ត្រូវបានដាក់ឱ្យអនុវត្តនៅទីក្រុងឡាន់ជូ, ជិនហាងដាវ និងទៀនជិន ដោយមានការគាំទ្រពីកម្មវិធី EU SWITCH-Asia។ ការវាយតម្លៃ បានបង្ហាញឱ្យឃើញនូវឥទ្ធិពលផ្ទាល់របស់គម្រោងក្នុងការកាត់បន្ថយការប្រើប្រាស់ថាមពល និង ទឹក, ការកាត់បន្ថយបំភាយឧស្ម័នកាបូនិក និងការសន្សំប្រេងឥន្ធនៈ និងទឹក។ ការផ្លាស់ប្តូរទម្លាប់អនុវត្តលទ្ធកម្មរបស់មជ្ឈមណ្ឌល លទ្ធកម្មសាធារណៈទាំងបីទីក្រុង (PPCs) បានធ្វើឱ្យការបំភាយកាបូនថយចុះចំនួន ១០៥ ៧៤៩តោន, កាត់បន្ថយកាកសំណល់ បានចំនួន ៣៤ ៤១៨តោន និងការសន្សំប្រេងបានចំនួន ១៤ ០០៨តោន និងទឹកបានចំនួន ៣៩ ២៦៩ម៣ ក្នុងរយៈពេលនៃ ការអនុវត្តគម្រោង (UNEP, 2017)។

## ២.៨. ការតាមដាន និងវាយតម្លៃ

ប្រទេសចិនមិនទាន់មានប្រព័ន្ធតាមដានពេញលេញនៅឡើយទេ (OECD, 2014)[7]។ យោងទៅលើរបាយការណ៍ឈ្មោះ 'Unlock G20's GPP Potential (2023)' ក្របខ័ណ្ឌត្រួតពិនិត្យលទ្ធកម្មសាធារណៈបៃតងរបស់ប្រទេសចិន កំពុងស្ថិតក្នុងការរៀបចំ បង្កើតនៅឡើយ។ ការវាយតម្លៃលើលទ្ធកម្មសាធារណៈបៃតង អាចធ្វើបានភាគច្រើនតាមរយៈឯកសារស្រាវជ្រាវ និងរបាយការណ៍ ស្ថិតិពីក្រសួងហិរញ្ញវត្ថុ[8] ទៅវិញទេ។

ការសិក្សារបស់ Gao et al. (2022)[9] ដោយវិភាគទៅលើឯកសារលទ្ធកម្មចំនួន ៤២ ៣៦៩ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ នៅប្រទេសចិន បានឱ្យដឹងថាក្នុងនោះ មានជាង ៨២% ជាការអនុវត្តលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព ដែលជានិន្នការ ឆ្ពោះទៅមុខ ។ ជាពិសេស លទ្ធកម្មដែលផ្តោតលើសហគ្រាសធុនតូច និងមធ្យម មានទំហំលើសលប់គេ គឺលើសជម្រើសមេត្រី បរិស្ថានទាំងឡាយដែលបានកំណត់ទៅទៀត។ ការសិក្សានេះបង្ហាញពីទំនាក់ទំនងរវាងកម្រិតធ្វើលទ្ធកម្មសាធារណៈប្រកបដោយ និរន្តរភាព និងវិធីសាស្ត្រផ្តល់រង្វាន់, តម្លៃដាក់ដេញថ្លៃ និងប្រភេទកិច្ចសន្យា។ តាមរយៈនេះ យើងឃើញថា លទ្ធកម្មសាធារណៈ ប្រកបដោយនិរន្តរភាពរបស់ប្រទេសចិនកំពុងបាញ់ឆ្ពោះទៅសង្កត់ធ្ងន់លើទិដ្ឋភាពសង្គម ដែលជំរុញឱ្យមានការពិភាក្សាអំពីផល ជះរបស់គោលនយោបាយ និងទិសដៅស្រាវជ្រាវសម្រាប់ពេលអនាគត។

តាមទិន្នន័យដែលក្រសួងហិរញ្ញវត្ថុបញ្ចេញនៅឆ្នាំ២០២១ (CEC, 2022)[10] ប្រទេសចិន ក្នុងឆ្នាំ២០២០ បានចំណាយថវិកាអស់ ៨១,៣៥ប៊ីលានយាន់ ទៅលើផលិតផលបិទស្លាកមេត្រីបរិស្ថាន ដែលស្មើនឹង ៨៥,៥% នៃការទិញសរុបរបស់ខ្លួន។ លទ្ធផល នៃការត្រួតពិនិត្យពីមជ្ឈមណ្ឌលវិញ្ញាបនបត្របរិស្ថានចិន (CEC) សម្រាប់លទ្ធកម្មសាធារណៈបៃតងក្នុងឆ្នាំ២០២២ បង្ហាញ

7 Available at https://www.oecd.org/governance/procurement/toolbox/search/china-best-practices-green-public-procurement-gpp-environmental-standards.pdf, Accessed on 14.11.2023.

8 Available at https://t20ind.org/research/unlocking-the-g20s-green-public-procurement-potential/, Accessed on 15.11.2023.

9 Gao et al. (2022). Implementation of sustainable public procurement in China: An assessment using quantitative text analysis in large-scale tender documents. Front. Environ. Sci. 10:947962. doi: 10.3389/fenvs.2022.947962

10 Available at https://wedocs.unep.org/bitstream/handle/20.500.11822/40135/GPPM_China.pdf?sequence=1, Accessed on 14.11.2023.

លទ្ធផលវិជ្ជមាន ដូចខាងក្រោម៖

- កុំព្យូទ័រយួរដៃ និងកុំព្យូទ័រដាក់លើតុ កាត់បន្ថយការបញ្ចេញឧស្ម័នកាបូន បានចំនួន ១,៧លានតោន ស្មើនឹងការស្រូបយកកាបូនប្រចាំឆ្នាំរបស់ព្រៃឈើចំនួន ១៩១ពាន់ហិកតា។
- គ្រឿងសង្ហារិមការិយាល័យបានកាត់បន្ថយ VOCs (សមាសធាតុសរីរាង្គងាយនឹងបង្កជាហេតុ) បានចំនួន ១៤៩ ០០០ តោន គឺត្រូវនឹង ៥% នៃការបំភាយ VOC ប្រចាំឆ្នាំរបស់ឧស្សាហកម្មគ្រឿងសង្ហារិមរបស់ប្រទេសចិន។
- ក្រដាសបានរួមចំណែកកាត់បន្ថយយ៉ាងច្រើននូវតម្រូវការអុកស៊ីសែនគីមី (COD), ផូស្វ័រសរុប (TP) និងអាម៉ូញាក់អាសូត ($NH_3$-N)។

## ២.៩. កិច្ចសហការ និងភាពជាដៃគូ

មជ្ឈមណ្ឌលឯកភាពចិនផ្តល់វិញ្ញាបនបត្របរិស្ថាន (CEC) បានអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាច្រើន ជាមួយអង្គការអន្តរជាតិ ដោយផ្តោតទៅលើការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋាភិបាលលើផលិតផលបិទស្លាកមេត្រីបរិស្ថាន ក្នុងនោះមានគម្រោង៖

- "ផែនការក្របខ័ណ្ឌផែនការ១០ឆ្នាំ សម្រាប់កិច្ចលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព (SPP 10 YFP)" ដែលជាផ្នែកមួយនៃគំនិតផ្តួចផ្តើមទូលំទូលាយនៃកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ (UNEP) ដែលមានអង្គការពិភពលោកចំនួន ១០០ ចូលពាក់ព័ន្ធ។ មជ្ឈមណ្ឌលអភិវឌ្ឍន៍បរិស្ថាន ដែលចាប់ផ្តើមនៅឆ្នាំ២០១៤ ដោយមានការយល់ព្រមពីក្រសួងការពារបរិស្ថាន និង មជ្ឈមណ្ឌលឯកភាពចិនផ្តល់វិញ្ញាបនបត្របរិស្ថាន (CEC) បានចូលរួមយ៉ាងសកម្មតាមរយៈការរួមចំណែកផ្នែកជំនាញឯកទេស, ករណីសិក្សា និងការផ្តល់មតិកែលម្អ។ គំនិតផ្តួចផ្តើមនេះបានលើកកម្ពស់ការអនុវត្តកិច្ចលទ្ធកម្ម និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពជាសកលទទួលបានជោគជ័យ។
- ការសិក្សាមួយស្តីពីគុណផលការងារក្នុងកិច្ចលទ្ធកម្មបៃតងរបស់រដ្ឋាភិបាលចិន ដោយសហការជាមួយវិទ្យាស្ថានអន្តរជាតិសម្រាប់ការអភិវឌ្ឍដោយចីរភាព (IISD) បានបោះពុម្ពផ្សាយរបាយការណ៍របស់ខ្លួនសម្រាប់ជាប្រយោជន៍ដល់សហគមន៍អន្តរជាតិ។
- សមាសធាតុលទ្ធកម្មសាធារណៈនៅក្នុង "ការសិក្សាអំពីលទ្ធភាពនៃប្រព័ន្ធរាយការណ៍និរន្តរភាពនៅប្រទេសចិន" (Study on the Feasibility of Sustainable Measurement Reporting System in China) គឺជាគម្រោងកិច្ចសហប្រតិបត្តិការមួយ ជាមួយ អង្គការសកលមួយឈ្មោះថា The Sustainability Consortium។
- នៅឆ្នាំ២០០៥ បណ្តាញការទិញផលិតផលបៃតងឈ្មោះថា International Green Purchasing Network (IGPN) បានកើតចេញជារូបរាង ជាមួយបេសកកម្មដែលមានគោលដៅជំរុញទម្លាប់អនុវត្តន៍ការទិញដោយគិតគូរពីបរិស្ថាន នៅទូទាំងសកលលោក។ បណ្តាញផ្តល់ជាវេទិកាសហការមួយសម្រាប់អ្នកពាក់ព័ន្ធច្រើនគ្នា រួមមានអង្គការអន្តរជាតិ ធុរកិច្ច ស្ថាប័នរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដែលទាំងអស់នេះដើរតួយ៉ាងសកម្មក្នុងការអនុវត្តការជាវដោយគិតគូរពីបរិស្ថាន។ ចាប់តាំងពីឆ្នាំ២០១៨ មក មជ្ឈមណ្ឌលឯកភាពចិនផ្តល់វិញ្ញាបនបត្របរិស្ថាន (CEC) បានទទួលធ្វើម្ចាស់ផ្ទះនៃលេខាធិការដ្ឋានរបស់បណ្តាញ IGPN។ ទង្វើនេះសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ប្រទេសចិនក្នុងការជំរុញការធ្វើលទ្ធកម្មសាធារណៈបៃតង និងចូលរួមយ៉ាងសកម្មក្នុងការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ នៅលើឆាកអន្តរជាតិ។
- ផ្តើមនៅឆ្នាំ២០២១ កម្មវិធីលទ្ធកម្មប្រកបដោយនិរន្តរភាពរបស់ចិន សហការជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) នៅរដ្ឋាភិបាលថ្នាក់ស្រុកឈីងពុ (Qingpu) និងមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការផ្លាស់ប្តូរសេដ្ឋកិច្ច និងបច្ចេកទេសនៃប្រទេសចិន មានគោលដៅដោះស្រាយបញ្ហាប្រឈមបរិស្ថាន និងលើកកម្ពស់ការអនុវត្តបៃតង។ កម្មវិធីនេះផ្តោតលើការជួយដល់ក្រុមហ៊ុនចិនខ្នាតតូច ដោយផ្តល់ធនធាន និងបង្កលក្ខណៈឱ្យមានការចូលរួមនៅក្នុងលទ្ធកម្មសាធារណៈជាសកល សំដៅជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ។[11]

11 Available at https://procurementmag.com/sustainable-sourcing/china-launches-un-backed-sustainable-procurement-programme, Accessed on 20.11.2023.

## ២.១០. កំណត់ចំណាំ

- ក្របខ័ណ្ឌបទប្បញ្ញត្តិដែលក្រសួងការពារបរិស្ថាន និងក្រសួងហិរញ្ញវត្ថុ បានបង្កើតឡើង ផ្តល់ការណែនាំច្បាស់លាស់សម្រាប់ការទិញផលិតផលបៃតង ដែលបានចុះបញ្ជីនៅក្នុងប្រភេទផលិតផលសន្សំថាមពល និងផលិតផលបិទស្លាកមេត្រីបរិស្ថាន (ELP)។
- កម្មវិធីស្លាកមេត្រីបរិស្ថាន ត្រូវបានធ្វើបច្ចុប្បន្នភាពទៀងទាត់ ដែលតាមរយៈនេះ វាបានជួយសម្រាលបន្ទុកក្នុងការបង្កើតស្តង់ដាគុណផលបៃតងរបស់អង្គភាពលទ្ធកម្មដោយឡែកៗពីគ្នា។
- វិញ្ញាបនបត្រសន្សំថាមពល និងការស្លាកមេត្រីបរិស្ថានរបស់ចិន ផ្តល់ការលើកទឹកចិត្តខ្លាំងដល់ផលិតករក្នុងការរចនា និងផលិតផលិតផលដែលមេត្រីបរិស្ថាន ដែលជំរុញការផ្លាស់ប្តូរទៅរកការអនុវត្តកិច្ចលទ្ធកម្មប្រកបដោយនិរន្តភាពនៅលើទីផ្សារប្រកបដោយដោយជោគជ័យ ។

# ៣. ប្រទេសឡាវ



### គោលនយោបាយ

ឡាវបានដាក់ចេញនូវផែនទីចង្អុលផ្លូវ និងផែនការសកម្មភាព សម្រាប់លទ្ធកម្មសាធារណៈបៃតង (GPP) នៅឆ្នាំ២០២៣។

### ភក្តាជោគជ័យធំៗ

- ការប្តេជ្ញាចិត្តផ្នែកនយោបាយ៖ លទ្ធកម្មសាធារណៈបៃតង ជាសកម្មភាពអាទិភាពមួយ នៅក្នុងផែនទីចង្អុលផ្លូវស្តីពីការប្រើប្រាស់ និងការផលិតប្រកបដោយនិរន្តរភាព នៃប្រទេសឡាវ ឆ្នាំ២០២២-២០២៥ និង ចក្ខុវិស័យឆ្នាំ២០៣០។
- ការរៀបចំស្ថាប័ន៖ ក្រសួងហិរញ្ញវត្ថុដឹកនាំកិច្ចការនេះ ដោយសម្របសម្រួលជាមួយក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម និង ក្រសួងធនធានធម្មជាតិ និងបរិស្ថាន។

### មហិច្ឆតា

ប្រទេសឡាវ មានគោលដៅបង្កើតស្លាកបៃតង (Green Label) និងដាក់ឱ្យដំណើរការកិច្ចលទ្ធកម្មសាធារណៈបៃតង នៅពេលខាងមុខ។

### ការផ្តោត

គ្រឿងអេឡិចត្រូនិក, គ្រឿងអគ្គិសនី, ផលិផលកសិកម្មសរីរាង្គ (ប្រហែលជាតាមរយៈស្លាកសញ្ញាដែលមានស្រាប់)។

## ៣.១. សេចក្តីផ្តើម

ស្របតាមផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជាតិលើកទី៩ និងយុទ្ធសាស្ត្រកំណើនបៃតងជាតិរបស់ខ្លួន រដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានប្តេជ្ញាធ្វើបរិវត្តន៍ប្រកបដោយចីរភាព។ ក្រសួងធនធានធម្មជាតិ និងបរិស្ថាន បានអនុម័តផែនទីបង្ហាញផ្លូវស្តីពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព ដោយផ្តល់អាទិភាពលើលទ្ធកម្មសាធារណៈបៃតង ក្រោមការដឹកនាំរបស់ក្រសួងហិរញ្ញវត្ថុ។ ផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពស្តីពីលទ្ធកម្មសាធារណៈបៃតងនៃប្រទេសឡាវ ដែលបានដាក់ចេញនៅឆ្នាំ២០២៣ ក្រោមការគាំទ្រពីអង្គការ GIZ នៃប្រទេសអាល្លឺម៉ង់ ឆ្លុះបញ្ចាំងពីវឌ្ឍនភាពដ៏សំខាន់នេះ។ មូលដ្ឋានច្បាប់ដូចជា ក្រិត្យលេខ 03/PM របស់នាយករដ្ឋមន្ត្រី និងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ សុទ្ធតែគាំទ្រដល់លទ្ធកម្មសាធារណៈបៃតង។ ខណៈដែលក្របខ័ណ្ឌតាមដាន និងវាយតម្លៃនៅកំពុងរៀបចំនៅឡើយ កិច្ចសហការជាមួយ Team Europe និង GIZ ជាការគាំទ្រប្រទេសឡាវក្នុងការបោះជំហានទៅរកសេដ្ឋកិច្ចបៃតងរបស់ខ្លួន។ ប្រទេសនេះសង្ឃឹមថានឹងបង្កើតស្លាកសញ្ញាមេត្រីបរិស្ថាន (Green Label) ដោយរៀនសូត្រពីបទពិសោធន៍សាកល និងជំរុញភាពជាដៃគូអន្តរជាតិ ក៏ដូចជារំលេចឡើងអំពីសារៈសំខាន់នៃអភិក្រមនិរន្តរភាពរួមផងដែរ។

## ៣.២. ការបង្កើតគោលនយោបាយ

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជាតិលើកទី៩ (២០២១-២០២៥) និងយុទ្ធសាស្ត្រកំណើនបៃតងជាតិដល់ឆ្នាំ២០៣០ បង្ហាញការប្តេជ្ញាចិត្តក្នុងការប្រែក្លាយវេទិកាអភិវឌ្ឍន៍របស់ឡាវ ទៅជាវេទិកាអភិវឌ្ឍន៍បៃតង និងប្រកបដោយចីរភាព។ បរិវត្តន៍នេះពាក់ព័ន្ធដល់ការរៀបចំផែនការតាមវិស័យ ជាពិសេស វិស័យធនធានធម្មជាតិ និងបរិស្ថានតែម្តង។ ក្របខ័ណ្ឌគ្រប់គ្រងកាកសំណល់ គឺជាធាតុផ្សំសំខាន់នៃវេទិកាប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព ស្របតាមចំណុចផ្តោតផ្នែកបរិស្ថានទី៣ នៃផែនការការងារ ៥ឆ្នាំ (២០២១-២០២៥) សម្រាប់ការអភិវឌ្ឍបៃតង និងប្រកបដោយចីរភាព នៅក្នុងវិស័យធនធានធម្មជាតិ និងបរិស្ថាន។

នៅខែឧសភា ឆ្នាំ២០២២ ក្រសួងធនធានធម្មជាតិ និងបរិស្ថាន បានអនុម័ត**ផែនទីចង្អុលផ្លូវនៃការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាពឡាវ ឆ្នាំ២០២២-២០២៥ ដែលជាចក្ខុវិស័យសម្រាប់ឆ្នាំ២០៣០**។ ការរៀបចំនេះទទួលបានការគាំទ្រពីផ្នែកតស៊ូមតិគោលនយោបាយនៃកម្មវិធីប្រចាំតំបន់របស់ EU SWITCH-Asia។ លទ្ធកម្មសាធារណៈបៃតង គឺជាសកម្មភាពអាទិភាពមួយនៃផែនទីបង្ហាញផ្លូវ។ គោលបំណងនៃលទ្ធកម្មសាធារណៈបៃតង គឺដើម្បីជំរុញភ្នាក់ងាររដ្ឋាភិបាលឱ្យក្លាយជាលទ្ធករចម្បងក្នុងការជាវផលិតផល និងសេវាកម្មដែលមេត្រីបរិស្ថាន ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃអង្គការសហប្រជាជាតិ ជាពិសេសគោលដៅ ១២.៧ ស្តីពីការលើកកម្ពស់លទ្ធកម្មប្រកបដោយនិរន្តរភាព។ គំនិតផ្តួចផ្តើមនេះនឹងធ្វើការពាក់ព័ន្ធជាមួយភាគីនៅកម្រិតផ្សេងៗ ចាប់ពីថ្នាក់កណ្តាល/មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន ដើម្បីវាយតម្លៃសេណារីយោលទ្ធកម្មដែលបានស្នើឡើង, បង្កើតផែនការសកម្មភាពសម្រាប់អនុវត្តលទ្ធកម្មបៃតង, រៀបចំបង្កើតគោលនយោបាយ, និងផ្សព្វផ្សាយគោលការណ៍ណែនាំ។ ក្រសួងហិរញ្ញវត្ថុ មានតួនាទីដឹកនាំកិច្ចការនេះ ដោយសម្របសម្រួលជាមួយក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម, ក្រសួងធនធានធម្មជាតិ និងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ចផ្សេងទៀត។

រដ្ឋាភិបាលឡាវសម្រេចបានវឌ្ឍនភាពធំៗ ទាក់ទងនឹងការរៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពីលទ្ធកម្មសាធារណៈបៃតង។ ដោយមានការគាំទ្រពីអង្គការ GIZ, រដ្ឋាភិបាលឡាវ នៅឆ្នាំ២០២៣ បានដាក់ចេញ**ផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពលទ្ធកម្មសាធារណៈបៃតងសម្រាប់ប្រទេសឡាវ និងយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងសម្រាប់ការលើកកម្ពស់ផលិតផល ក៏ដូចជាសេវាកម្មបៃតង ផងដែរ**។

## ៣.៣. ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ

*ក្រិត្យលេខ 03/PM (2004) របស់នាយករដ្ឋមន្ត្រី* បានចែងអំពីវិធានសម្រាប់លទ្ធកម្មរបស់រដ្ឋាភិបាល ធានាប្រសិទ្ធផល តម្លាភាព និងសមភាពក្នុងចំណោមតួអង្គក្នុងវិស័យសេដ្ឋកិច្ច។ *ច្បាប់ស្តីពីលទ្ធកម្មសាធារណៈលេខ 30/NA (2017, 2019)* ផ្តល់គោលការណ៍ណែនាំលម្អិតសម្រាប់ការធ្វើផែនការលទ្ធកម្ម, កម្រិតកំណត់អប្បបរមា, ក្របខ័ណ្ឌពេលវេលា នីតិវិធី និងការណែនាំជាច្រើនទៀត។ មាត្រា ៤ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ចែងថា រដ្ឋាភិបាលជំរុញលទ្ធកម្មសាធារណៈ ដោយការពារសិទ្ធិអ្នកប្រើប្រាស់ និងថែរក្សាបរិស្ថាន ដើម្បីធានានិរន្តរភាពបៃតង។ ជាការពិត ក្រិត្យ និងច្បាប់ស្តីពីលទ្ធកម្មសាធារណៈបានផ្តល់មូលដ្ឋានសម្រាប់ការចាប់ផ្តើមរៀបចំប្រព័ន្ធលទ្ធកម្មសាធារណៈបៃតង[12]។ ក្រោមជំនួយពីអង្គការ GIZ បច្ចុប្បន្នប្រទេសឡាវកំពុងរៀបចំធ្វើសេចក្តីព្រាងឯកសារទស្សនទាន សម្រាប់គាំទ្រដល់ការរៀបចំ និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈបៃតង។

ខណៈដែលលទ្ធកម្មសាធារណៈបៃតងមិនទាន់ត្រូវបានអនុវត្តនៅឡើយក្នុងប្រទេសឡាវ ការគាំទ្រដល់សកម្មភាពដូចជាគំនិតផ្តួចផ្តើមរបស់រដ្ឋសភាលេខ 10/PO (1999) និងផែនការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ២០១៦-២០២០ ជាដើម ក៏ជាកត្តាលើកទឹកចិត្តមួយដល់ផលិតកម្មបៃតង។ ច្បាប់ស្តីពីឧស្សាហកម្មកែច្នៃលេខ 01-99/NA ផ្តោតលើការពង្រីកឧស្សាហកម្មកែច្នៃដោយផ្សារភ្ជាប់ជាមួយកសិ-រុក្ខាប្រមាញ់ និងការលើកកម្ពស់ជីវភាពរស់នៅ ស្របគ្នាជាមួយនឹងគិតគូរពីផលប៉ះពាល់លើបរិស្ថានផងដែរ។

## ៣.៤. ការរៀបចំស្ថាប័ន

រដ្ឋាភិបាលឡាវបានបង្កើតគណៈកម្មាធិការ និងស្ថាប័ន ដើម្បីជំរុញសកម្មភាពអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងលក្ខណៈជាយុទ្ធសាស្ត្រ។ ការរៀបចំស្ថាប័នសម្រាប់ធានាសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងលទ្ធកម្មសាធារណៈបៃតង មានបង្ហាញជូននៅក្នុងគំនូសតាងទី២។

**គណៈកម្មាធិការជាតិដឹកនាំការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព** ដែលមាននាយករដ្ឋមន្ត្រីជាប្រធាន មានសមាជិកចំនួន ២៦រូប មកពីក្រសួង និងស្ថាប័នពាក់ព័ន្ធ។ គណៈកម្មាធិការនេះទទួលខុសត្រូវក្នុងការគ្រប់គ្រង ការសម្របសម្រួល និងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ (SDGs) តាមរយៈផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជាតិ (NSEDP) និងផែនការអភិវឌ្ឍន៍តាមវិស័យនៃក្រសួងនានា។ អាណត្តិកិច្ចរបស់គណៈកម្មាធិការនេះរួមមាន ការតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយផ្តោតលើការសម្រេចឱ្យបានតាមគោលដៅនៅត្រឹមឆ្នាំ២០៣០។

12 GIZ (2021). Analysis Study – National Green Public Procurement and Environmental Labels in Cambodia, Lao PDR, Myanmar, Vietnam, and Bhutan (https://www.thai-german-cooperation.info/wp-content/uploads/2021/05/2021_Analysis-Study-GPPEL-in-five-countries_SCP-Outreach_Final.pdf).

**លេខាធិការដ្ឋានជាតិសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព** ដែលត្រូវបានតែងតាំងដោយគណៈកម្មាធិការជាតិដឹកនាំការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ធ្វើប្រតិបត្តិការរបស់ខ្លួននៅក្នុងក្របខ័ណ្ឌនៃក្រសួងការបរទេស និងក្រសួងផែនការ និងវិនិយោគ។ លេខាធិការដ្ឋាននេះសហការជាមួយក្រសួងពាក់ព័ន្ធនានា ក្នុងការតាមដានវឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយលើកស្ទួយភាពជាដៃគូជាមួយទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីពន្លឿនវឌ្ឍនភាពនៃគោលបំណងសំខាន់ៗនៃរបៀបវារៈឆ្នាំ២០៣០។

**រដ្ឋាភិបាលឡាវក៏បានបង្កើតផងដែរនូវគណៈកម្មាធិការជាតិជំរុញកំណើនបៃតង** (GGNSC) ដែលមានអាណត្តិកិច្ចមើលការខុសត្រូវរួមលើការធ្វើផែនការកំណើនបៃតង, ការអនុវត្តកម្មវិធី គោលនយោបាយ និងគម្រោងផ្សេងៗ, និងការងារតាមដានវឌ្ឍនភាព។ គណៈកម្មាធិការនេះមានឧបនាយករដ្ឋមន្ត្រី/រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុជាប្រធាន និងក្រសួងផែនការ និងវិនិយោគជាអ្នកប្រតិបត្តិការផ្ទាល់។ សមាជិករបស់គណៈកម្មាធិការនេះ មានតំណាងមកពីក្រសួងធនធានធម្មជាតិ និងបរិស្ថាន, ក្រសួងការបរទេស, ក្រសួងថាមពល និងរ៉ែ, ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូន។

ដូចត្រូវបានគូសបញ្ជាក់ក្នុងផែនការសកម្មភាពជាតិសម្រាប់ការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាពរួចហើយ **ក្រសួងហិរញ្ញវត្ថុ** ដើរតួយ៉ាងសំខាន់ក្នុងការដឹកនាំលទ្ធកម្មសាធារណៈបៃតងនៅក្នុងប្រទេស។ ជាមួយមុខងារជាស្ថាប័នមានសិទ្ធិអាជ្ញា ក្រសួងនេះមានសិទ្ធិ និងអំណាចលើការរៀបចំគោលនយោបាយលទ្ធកម្មសាធារណៈ។ ដើម្បីដាក់គោលនយោបាយទាំងនេះឱ្យដំណើរការបាន ក្រសួងហិរញ្ញវត្ថុ បានចាត់តាំង**នាយកដ្ឋានថវិការដ្ឋ** ឱ្យអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ និងច្បាប់ពាក់ព័ន្ធនឹងប្រតិបត្តិការថវិការដ្ឋ និងលទ្ធកម្មដែលប្រើប្រភពមូលនិធិផ្សេងៗរបស់រដ្ឋ។ លើសពីនេះ នាយកដ្ឋានេះបានធ្វើការសិក្សាស្រាវជ្រាវជាបន្តបន្ទាប់ រៀបចំបង្កើត និងពង្រឹងច្បាប់ថ្នាក់ក្រោម ហើយព្រមពេលជាមួយគ្នានោះ ធ្វើការតាមដានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើការអនុវត្តសកម្មភាពលទ្ធកម្ម ឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់។

នាយកដ្ឋានត្រួតពិនិត្យនិងតាមដានការបំពុល (DPCM) - ក្រោមការដឹកនាំរបស់ក្រសួងធនធានធម្មជាតិ និងបរិស្ថាន - ដឹកនាំកិច្ចសហការក្នុងចំណោមស្ថាប័នថ្នាក់មជ្ឈិម និងថ្នាក់មូលដ្ឋាន ដើម្បីធ្វើការសិក្សាស្រាវជ្រាវ ចាត់ថ្នាក់គោលនយោបាយ និងអនុវត្តបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងការបំពុល។ ក្រៅពីនេះ នាយកដ្ឋានធ្វើការជាមួយផ្នែកពាក់ព័ន្ធដើម្បីបង្កើនទំនួលខុសត្រូវអាជីវកម្មលើការបំភាយជាតិពុល ការគ្រប់គ្រងបន្ទុកការបំពុល ហើយវាក៏ធ្វើការបណ្តុះបណ្តាលដើម្បីគាំទ្រដល់ការអនុវត្តឱ្យមានប្រសិទ្ធភាពផងដែរ។




**គំនូសតាងទី២៖** ក្របខ័ណ្ឌស្ថាប័នពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងលទ្ធកម្មសាធារណៈបៃតង នៅប្រទេសឡាវ

## ៣.៥. គោលការណ៍ណែនាំ និងលក្ខណៈវិនិច្ឆ័យ

ប្រទេសឡាវបានបង្កើត**ស្តង់ដាជាតិស្តីពីប្រសិទ្ធភាពថាមពល និងកម្មវិធីបិទស្លាកប្រសិទ្ធភាពថាមពល** ដែលយកលំនាំតាមស្តង់ដាគណៈកម្មការបច្ចេកទេសអគ្គិសនីអន្តរជាតិ (IEC)។ ស្តង់ដាទាំងនេះកំពុងត្រូវបានប្រើលើផលិតផលអគ្គិសនី និងគ្រឿងអេឡិចត្រូនិចចំនួន ៥០មុខ។ ស្តង់ដាជាតិសរីរាង្គរបស់ប្រទេសឡាវ គឺជាស្តង់ដាជាតិមួយផ្សេងទៀតដែលមានគោលបំណងលើកកម្ពស់កសិកម្មស្អាតក្នុងវិស័យកសិកម្ម និងព្រៃឈើ ដោយអនុលោមតាមច្បាប់ស្តីពីកសិកម្មនៅប្រទេសឡាវ។ ស្តង់ដានេះបានមកពីស្តង់ដាមូលដ្ឋាននៃសហព័ន្ធអន្តរជាតិរបស់ចលនាកសិកម្មសរីរាង្គ (IFOAM) និងស្តង់ដាសរីរាង្គនៃវិញ្ញាបនបត្រកសិកម្មសរីរាង្គនៃប្រទេសថៃ (ACT) (GIZ, 2021)[13]។

ផ្សារនៃប្រទេសឡាវមានប្រើស្លាកអេកូ (ecolabel) ដែលយកតាមស្ថាប័នវិញ្ញាបនបត្រអន្តរជាតិដូចជា **ក្រុមប្រឹក្សាគ្រប់គ្រងព្រៃឈើ (FSC)** និង**កម្មវិធីសម្រាប់ការអនុម័តនៃវិញ្ញាបនបត្រព្រៃឈើ (PEFC)** ជាដើម ដែលផ្តោតលើការគ្រប់គ្រងព្រៃឈើ។ លើសពីនេះ ស្លាកដែលទទួលបានការបញ្ជាក់ពីស្ថាប័ន TCO មានជាទូទៅនៅលើផលិតផលបច្ចេកវិទ្យាព័ត៌មាន (GIZ, 2021)[13]។

13 GIZ (2021). Analysis Study – National Green Public Procurement and Environmental Labels in Cambodia, Lao PDR, Myanmar, Vietnam, and Bhutan (https://www.thai-german-cooperation.info/wp-content/uploads/2021/05/2021_Analysis-Study-GPPEL-in-five-countries_SCP-Outreach_Final.pdf).

បច្ចុប្បន្ន ប្រទេសឡាវមិនទាន់មានកម្មវិធីជាតិសម្រាប់ស្លាកអេកូ (national ecolabelling programme) របស់ខ្លួននៅឡើយទេ។ យោងតាមផែនទីបង្ហាញផ្លូវស្តីពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព ប្រទេសនេះមានគោលបំណងបង្កើតស្លាកបៃតងរបស់ខ្លួន។ ដោយមានអង្គការ GIZ ជួយគាំទ្រក្នុងការផ្តល់នូវចំណេះជំនាញសំខាន់ៗ និងការកសាងសមត្ថភាពដើម្បីជួយឱ្យរដ្ឋាភិបាលអាចបង្កើត និងគ្រប់គ្រងគំនិតផ្តួចផ្តើម ផ្នែកស្លាកអេកូដោយឯករាជ្យ និងប្រកបដោយនិរន្តរភាព, រដ្ឋាភិបាលឡាវ កំពុងដំណើរការសិក្សាដកស្រង់បទពិសោធន៍ពីប្រទេសផ្សេងទៀតដូចជា ប្រទេសថៃ ជប៉ុន និងអាល្លឺម៉ង់។

## ៣.៦. កម្មវិធីកសាងសមត្ថភាព បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង

សិក្ខាសាលាបណ្តុះបណ្តាល និងវគ្គពង្រឹងសមត្ថភាពលើលទ្ធកម្មសាធារណៈបៃតង ត្រូវបានរៀបចំជាច្រើនលើកសម្រាប់ក្រសួង-ស្ថាប័ននៃរដ្ឋាភិបាលឡាវ តាមរយៈការគាំទ្រពីដៃគូអភិវឌ្ឍន៍អន្តរជាតិដូចជា អង្គការ GIZ និងធនាគារពិភពលោក ជាដើម។

## ៣.៧. ការតាមដាន និងវាយតម្លៃ

រហូតមកដល់ពេលនេះ ប្រទេសឡាវមិនទាន់មានក្របខ័ណ្ឌការងារសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃសម្រាប់លទ្ធកម្មសាធារណៈបៃតង នៅឡើយទេ។

## ៣.៨. កិច្ចសហការ និងភាពជាដៃគូ

ប្រទេសឡាវទទួលបានគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ពីសំណាក់ដៃគូអភិវឌ្ឍន៍អន្តរជាតិជាច្រើន ក្នុងការរៀបចំបង្កើតគោលនយោបាយ ឧទាហរណ៍ ដូចជាយុទ្ធសាស្ត្រកំណើនបៃតងជាតិ ដែលត្រូវបានបង្កើតឡើងដោយជំនួយពីធនាគារពិភពលោកក្នុងឆ្នាំ២០១៩។ ជាផ្នែកមួយនៃផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិលើកទី៩របស់ឡាវ សហភាពអឺរ៉ុប រួមជាមួយរដ្ឋាភិបាលនៃប្រទេសហ្វាំងឡង់ បារាំង អាល្លឺម៉ង់ ហុងគ្រី អៀរឡង់ លុចសំបួ និងស៊ុយអែត (ក្រុមប្រទេសជារដ្ឋសមាជិករបស់អឺរ៉ុប) បានសន្យាផ្តល់ជំនួយ ៥៥០លានអឺរ៉ូដល់ឡាវសម្រាប់ជំរុញសេដ្ឋកិច្ចបៃតង និងប្រកបដោយបរិយាបន្ន, ការអភិវឌ្ឍមូលធនមនុស្ស និងអភិបាលកិច្ចល្អ។ យុទ្ធសាស្ត្ររបស់ប្រទេសឡាវសម្រាប់ឆ្នាំ២០២១-២០២៥ ផ្តោតលើវិស័យចំនួនប្រាំមួយ ក្នុងនោះរួមមាន៖ កសិកម្ម, អប់រំ និងសុខាភិបាល ផងដែរ។ ផែនការសកម្មភាពជាតិសម្រាប់ការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព ត្រូវបានបង្កើតឡើងដោយមានជំនួយបច្ចេកទេសពីកម្មវិធី EU SWITCH-Asia ក្នុងកំឡុងឆ្នាំ២០២០-២០២១។[14]

ទាក់ទងទៅនឹងលទ្ធកម្មសាធារណៈបៃតង រដ្ឋាភិបាលឡាវសហការជាមួយគម្រោងថ្នាក់តំបន់របស់អង្គការ GIZ ឈ្មោះថា "Proliferation of Sustainable Consumption and Production (SCP) in Asia – the Next 5 (SCP Outreach)" ដើម្បីជាក់ឱ្យអនុវត្តគំនិតផ្តួចផ្តើមស្តីពីលទ្ធកម្មសាធារណៈបៃតង និងស្លាកសញ្ញាមេត្រីភាពបរិស្ថាន។ គម្រោងនេះបានផ្តល់ជំនួយបច្ចេកទេស ការកសាងសមត្ថភាព និងការចែករំលែកចំណេះដឹងផងដែរ។ បច្ចុប្បន្ន ផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពស្តីពីលទ្ធកម្មសាធារណៈបៃតង ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ២០២៣ បាន និងកំពុងដំណើរការ តាមរយៈ ការអនុវត្តសកម្មភាពនានាជាបន្តបន្ទាប់។

## ៣.៩. កំណត់ចំណាំ

- ប្រទេសឡាវបង្ហាញការប្តេជ្ញាចិត្តក្នុងការប្រែក្លាយវេទិកាអភិវឌ្ឍន៍របស់ខ្លួន ទៅជាវេទិកាបៃតង និងមាននិរន្តរភាព ដូចដែលបាន រំលេចនៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជាតិលើកទី៩ និងយុទ្ធសាស្ត្រកំណើនបៃតងជាតិដល់ឆ្នាំ២០៣០។
- កិច្ចប្រឹងប្រែងរួមគ្នារវាងរដ្ឋាភិបាលឡាវ និងដៃគូអភិវឌ្ឍន៍អន្តរជាតិ បាននាំឱ្យមានការរីកចម្រើនយ៉ាងឆាប់រហ័សនៅក្នុងការអនុវត្ត លទ្ធកម្មសាធារណៈបៃតង។ កិច្ចខិតខំរួមគ្នានេះបង្ហាញពីការប្តេជ្ញាចិត្តចំពោះការអនុវត្តប្រកបដោយនិរន្តរភាពស្របតាមគោលដៅបរិស្ថានពិភពលោក។ ការគាំទ្រពីដៃគូអន្តរជាតិ ដូចជាអង្គការ GIZ និងសហភាពអឺរ៉ុប បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើត និងជំរុញរបៀបវារៈស្តីពីលទ្ធកម្មសាធារណៈបៃតង នៅក្នុងប្រទេស ដោយឆ្លុះបញ្ចាំងឱ្យឃើញនូវអភិក្រមសហការគ្នាក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងប្រកបដោយបរិយាបន្ន។

14 Available at https://dicf.unepgrid.ch/lao-peoples-democratic-republic/green-economy, Accessed on 22.11.2023.

# ៤. ប្រទេសម៉ាឡេស៊ី



### គោលនយោបាយ

ម៉ាឡេស៊ីចាប់ផ្តើមអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង (GGP) នៅឆ្នាំ២០១៣។

### ភក្តាខោគជ័យធំៗ

- មានយន្តការសម្របសម្រួលអន្តរក្រសួងរឹងមាំ សម្រាប់អនុវត្ត GGP ក្នុងនោះរួមមាន៖ ក្រសួងហិរញ្ញវត្ថុ និង ក្រសួងថាមពល បច្ចេកវិទ្យាបៃតង និងទឹក។
- យន្តការហិរញ្ញវត្ថុ៖ ក្រសួងហិរញ្ញវត្ថុទទួលតម្លៃប៉ាន់ស្មានសម្រាប់អនុវត្តកិច្ចលទ្ធកម្មបៃតងមកធ្វើការបូកសរុប និងវិភាជន៍ថវិកា; កម្មវិធីលើកទឹកចិត្តសារពើពន្ធជំរុញលើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវ, រចនា/រៀបចំចងក្រង និងបង្កើតបច្ចេកវិទ្យាបៃតង។

### មហិច្ឆតា

អនុវត្តផែនការសកម្មភាពរយៈពេលវែងរបស់ម៉ាឡេស៊ីសម្រាប់ GGP នៅក្នុងវិស័យសំណង់ ដោយមានផែនការការងារលម្អិត។

### ការផ្តោត

លើសម្ភារសំណង់, បរិក្ខារ ICT, ប្រព័ន្ធម៉ាស៊ីនត្រជាក់, សេវាកម្មសម្អាត, សម្ភារការិយាល័យ។

## ៤.១. សេចក្តីផ្តើម

ម៉ាឡេស៊ី ស្ថិតក្នុងចំណោមប្រទេសមួយ ឈានមុខគេនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ក្នុងការប្រើប្រាស់ឥទ្ធិពលនៃការអនុវត្តកិច្ចលទ្ធកម្មដើម្បីធ្វើមានការផ្លាស់ប្តូរទីផ្សាររបស់ខ្លួន ដែលនាំឱ្យសម្រេចបានការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព។ ក្នុងឆ្នាំ២០១៣ ម៉ាឡេស៊ីបានចាប់ផ្តើមរៀបចំ និងអនុវត្តប្រព័ន្ធលទ្ធកម្មរដ្ឋាភិបាលបៃតង (GGP) ដែលត្រូវបានកំណត់និយមន័យថាជា

> *ការទិញផលិតផល សេវាកម្ម និងការងារសាងសង់ក្នុងវិស័យសាធារណៈ ដែលប្រើប្រាស់លក្ខណៈវិនិច្ឆ័យ និងស្តង់ដាបរិស្ថាន ដើម្បីអភិរក្សបរិស្ថាន និងធនធានធម្មជាតិ ដែលជួយសម្រាល និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដោយសារសកម្មភាពមនុស្ស[15]។*

ទោះបីជាតាមនិយមន័យនេះ ប្រទេសម៉ាឡេស៊ីផ្តល់អាទិភាពដល់សសរស្តម្ភសេដ្ឋកិច្ច និងបរិស្ថាននៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពតាមរយៈការប្រើប្រាស់លទ្ធកម្មសាធារណៈ គោលនយោបាយលទ្ធកម្មរដ្ឋាភិបាលបៃតងរបស់ខ្លួនក៏លើកកម្ពស់សហគ្រិន Bumiputra (មានន័យថា សកម្មភាពវិជ្ជមានសម្រាប់ជួយដល់ជនជាតិដើមម៉ាឡេ និងជនជាតិដើមភាគតិចផ្សេងទៀត) ផងដែរ ដើម្បីឈានទៅសម្រេចបាននូវគោលបំណងជាតិទូលំទូលាយ និងកំណើនប្រកបដោយសមធម៌។ ការប្តេជ្ញាចិត្តរបស់ម៉ាឡេស៊ីក្នុងការលើកកម្ពស់បច្ចេកវិទ្យាបៃតង និងផលិតផលអេកូ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងស្ថាប័នរបស់ខ្លួន ដែលខិតខំរួមគ្នាដើម្បីលើកកម្ពស់លទ្ធកម្មបៃតង។

15 Available at https://www.myhijau.my/green-procurement/ , Accessed on 23.11.2023.

## ៤.២. ការបង្កើតគោលនយោបាយ

ម៉ាឡេស៊ីមិនទាន់មានច្បាប់ស្តីពីគ្រប់គ្រងលទ្ធកម្មសាធារណៈនៅឡើយទេ។ ប្រព័ន្ធលទ្ធកម្មសាធារណៈជាតិនៃប្រទេសនេះ ត្រូវបានកំណត់ដោយសារាចរ និងបទប្បញ្ញត្តិជាច្រើន ដោយផ្អែកលើគោលការណ៍ជាមូលដ្ឋាន ដូចជា តម្លាភាព ការប្រកួតប្រជែង និងប្រសិទ្ធផល។ ផែនការអភិវឌ្ឍជាតិរបស់ប្រទេសម៉ាឡេស៊ីលើកទី១០ បានសង្កត់ធ្ងន់លើការអនុម័តតម្លៃសមស្រប គោលនយោបាយបទប្បញ្ញត្តិ និងយុទ្ធសាស្ត្រ សំដៅការពារធនធានធម្មជាតិសំដៅធានានិរន្តរភាពកំណើនសេដ្ឋកិច្ចរបស់ខ្លួន។ ផែនការនេះបានបង្ហាញពីតួនាទីនៃលទ្ធកម្មរបស់រដ្ឋាភិបាល ក្នុងការលើកកម្ពស់កំណើននៃឧស្សាហកម្មក្នុងស្រុក តាមរយៈការប្រើប្រាស់អតិបរមានូវសម្ភារ និងធនធានក្នុងស្រុក សំដៅសម្រេចឱ្យបាននូវគោលដៅសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍ។ ប្រព័ន្ធនេះក៏បានលើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគ្រិនជនជាតិដើមម៉ាឡេ Bumiputra ផងដែរ ដើម្បីទទួលបាននូវកំណើនប្រកបដោយសមធម៌។

យ៉ាងណាក៏ដោយ រហូតទាល់តែគោលគំនិតស្តីពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព (SCP) ត្រូវបានធ្វើសមាហរណកម្មស៊ីជម្រៅទៅក្នុងផែនការម៉ាឡេស៊ីទី១១ ឆ្នាំ២០១៦-២០២០ ដើម្បីលើកកម្ពស់ប្រសិទ្ធផលធនធាន ការពារបរិស្ថានធម្មជាតិ និងសម្រេចកំណើនបៃតង ទើបពេលនោះហើយដែលប្រព័ន្ធលទ្ធកម្មសាធារណៈបៃតង បានក្លាយជាមាគ៌ាមួយក្នុងចំណោមមាគ៌ាទាំង១០ ដើម្បីឈានទៅសម្រេចចក្ខុវិស័យដូចមាននៅក្នុងផែនការជាតិស្តីពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព (National SCP Blueprint) ឆ្នាំ២០១៦-២០៣០។ ដូច្នេះ គេអាចមើលឃើញថាកម្មវិធីលទ្ធកម្មរដ្ឋាភិបាលបៃតងរបស់ម៉ាឡេស៊ីត្រូវបានចាក់ឫសយ៉ាងជ្រៅនៅក្នុងផែនការជាតិស្តីពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាពជាតិរបស់ខ្លួន សម្រាប់ឈានទៅសម្រេចគោលបំណងគោលនយោបាយជាតិរយៈពេលវែង។

## ៤.៣. ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ

នៅក្នុងឆ្នាំ២០១៤ ក្រសួងហិរញ្ញវត្ថុបានចេញសារាចរស្តីពីលទ្ធកម្មរដ្ឋាភិបាលបៃតង ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីលទ្ធកម្មសាធារណៈបៃតង ក្នុងចំណោមក្រសួងដែលចូលរួម និងដាក់ឱ្យដំណើរការសាកល្បងលទ្ធកម្មរដ្ឋាភិបាលបៃតង នៅក្នុងក្រសួងទាំងនេះ។ ផែនការជាតិម៉ាឡេស៊ីលើកទី១១ ឆ្នាំ២០១៦–២០២០ បានដាក់កំហិតឱ្យក្រសួងពាក់ព័ន្ធ និងអង្គភាពចំណុះឱ្យក្រសួងទាំងនោះ ថាត្រូវតែអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង ហើយបានកំណត់គោលដៅថា យ៉ាងហោច ២០% នៃលទ្ធកម្មរបស់រដ្ឋទាំងអស់ គឺជាលទ្ធកម្មបៃតងនៅឆ្នាំ២០២០ ដោយប្រើប្រាស់បញ្ជីផលិតផល និងសេវាកម្មដែលមានស្លាកអេកូ (ecolabel) របស់ប្រទេសម៉ាឡេស៊ី[16] ស្រាប់។ ការដាក់កំហិតនេះមានគោលបំណងបង្កើតតម្រូវការផលិតផល និងសេវាកម្មបៃតង ដោយលើកទឹកចិត្តឱ្យបណ្តាឧស្សាហកម្មប្រឹងលើកកម្ពស់ស្តង់ដា និងគុណភាពនៃផលិតផល ដើម្បីបំពេញតាមលក្ខណៈវិនិច្ឆ័យបៃតងដែលមានបញ្ជាក់នៅក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីស្លាកអេកូ។ នៅឆ្នាំ២០១៦ ក្រសួងហិរញ្ញវត្ថុបានដាក់ចេញនូវផែនការសកម្មភាពលទ្ធកម្មរដ្ឋាភិបាលបៃតងរយៈពេលវែង ២០១៦-២០៣០ និងបានពង្រីកវិសាលភាពលទ្ធកម្មរដ្ឋាភិបាលបៃតង ឱ្យគ្របដណ្តប់ក្រសួងចំនួន១២ ព្រមទាំងអង្គភាពទទួលខុសត្រូវចំណុះក្រសួងទាំងនោះ ហើយចុងក្រោយសម្រេចបានរហូតដល់ទៅ ២៥ក្រសួង និងអង្គភាពចំណុះ នៅត្រឹមឆ្នាំ២០១៧។ ជាងនេះទៅទៀត គំនិតផ្តួចផ្តើមលទ្ធកម្មរដ្ឋាភិបាលបៃតងមួយចំនួនទាក់ទងនឹងសហគ្រាសធុនតូច និង មធ្យម, ការដាក់ស្លាកមេត្រីបរិស្ថាន, បញ្ជីផលិតផល និងសេវាកម្មបៃតង និងលទ្ធកម្មត្រូវបានធ្វើសមាហរណកម្មទៅក្នុងកម្មវិធីរួមទូលំទូលាយមួយឈ្មោះថា MyHIJAU ក្រោមទទួលខុសត្រូវរបស់ក្រសួងថាមពល បច្ចេកវិទ្យាបៃតង និងទឹក។

នាពេលបច្ចុប្បន្ននេះ មានតែក្រសួង-ស្ថាប័ននៃរដ្ឋាភិបាលសហព័ន្ធ (ថ្នាក់កណ្តាល) និងទីភ្នាក់ងាររបស់ខ្លួនប៉ុណ្ណោះដែលស្ថិតនៅក្រោមវិសាលភាពនៃសារាចរស្តីពីលទ្ធកម្មរដ្ឋាភិបាលបៃតង ដែលបានចេញដោយក្រសួងហិរញ្ញវត្ថុ។ ដោយឡែក រដ្ឋបាល ឬអាជ្ញាធរថ្នាក់ជាតិ និងមូលដ្ឋានមិនទាន់ជាប់កាតព្វកិច្ចអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតងនៅឡើយទេ។

ក្រៅពីនេះ ប្រទេសម៉ាឡេស៊ីក៏បានបង្កើតផែនការសកម្មភាពរយៈពេលវែងសម្រាប់លទ្ធកម្មរដ្ឋាភិបាលបៃតងនៅក្នុងវិស័យសំណង់ ដោយមានផែនការការងារលម្អិតផងដែរ។

16 Available at https://www.mgtc.gov.my/what-we-do/my-hijau/government-green-procurement/ Accessed on 27.11.2023

## ៤.៤. ការរៀបចំស្ថាប័ន

ទិដ្ឋភាពសំខាន់មួយនៅក្នុងភាពជោគជ័យរបស់ប្រទេសម៉ាឡេស៊ី ក្នុងការអនុវត្តលទ្ធកម្មបៃតង គឺការរៀបចំស្ថាប័ន ដែលបានកំណត់យ៉ាងល្អ (មើលគំនូសតាងទី៣)។ ម៉ាឡេស៊ីបានបង្កើតយន្តការសម្របសម្រួលអន្តរក្រសួងរឹងមាំមួយ សម្រាប់ការអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង។ នៅថ្នាក់កំពូល គណៈកម្មាធិការដឹកនាំលទ្ធកម្មរដ្ឋាភិបាលបៃតង (GPP Steering Committee) មានសមាសភាពមកពីក្រសួងហិរញ្ញវត្ថុ និងក្រសួងថាមពល បច្ចេកវិទ្យាបៃតង និងទឹក ដឹកនាំ និងទទួលខុសត្រូវរួមគ្នាក្នុងការពិនិត្យឡើងវិញ, តាមដាន និងវាយតម្លៃការអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង និងផ្តល់ទិសដៅយុទ្ធសាស្ត្រ។ គណៈកម្មការ/ក្រុមការងារលទ្ធកម្មរដ្ឋាភិបាលបៃតង (GPP Working Group/Committee) គឺជាសេនាធិការឱ្យគណៈកម្មាធិការដឹកនាំលទ្ធកម្មរដ្ឋាភិបាលបៃតង ផ្តល់ការគាំទ្រក្នុងការអនុវត្តភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ដូចជា ការកំណត់មុខផលិតផលបន្ថែមសម្រាប់អនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង និងការបង្កើតកម្មវិធីពង្រឹងសមត្ថភាព ដើម្បីបង្កើនប្រសិទ្ធផលនៃការអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង។ ក្រៅពីនេះ មានក្រុមការងារស្នូល (GPP Core Team) សម្រាប់លទ្ធកម្មរដ្ឋាភិបាលបៃតង ដែលមានសមាជិកមកពីគ្រប់ក្រសួងពាក់ព័ន្ធ ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់ដាក់ជូន GPP Working Group ពិនិត្យ និងអនុម័ត។ សមាជិកនៃក្រុមស្នូលលទ្ធកម្មរដ្ឋាភិបាលបៃតងមានទំនួលខុសត្រូវផ្សេងគ្នា។ ឧទាហរណ៍ ក្រសួងហិរញ្ញវត្ថុ ទទួលខុសត្រូវរៀបចំគោលនយោបាយសម្រាប់ការអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង។ សាជីវកម្មម៉ាឡេស៊ីសម្រាប់បច្ចេកវិទ្យាបៃតង និងការប្រែប្រួលអាកាសធាតុ (MGTC) ក្រោមក្រសួងថាមពល បច្ចេកវិទ្យាបៃតង និងទឹក ទទួលខុសត្រូវក្នុងការកំណត់អត្តសញ្ញាណផលិតផល និងសេវាកម្មបៃតង, រៀបចំការបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង និងផ្តល់ជំនួយបច្ចេកទេសដល់ក្រសួងពាក់ព័ន្ធ និងទីភ្នាក់ងាររបស់ខ្លួន សម្រាប់អនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង។ ដោយឡែក ស្ថាប័ន SIRIM QAS International ចំណុះឱ្យរដ្ឋាភិបាលម៉ាឡេស៊ី ទទួលខុសត្រូវក្នុងការបង្កើតលក្ខណៈវិនិច្ឆ័យស្លាកអេកូ ដើម្បីគាំទ្រដល់ការអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង។




**គំនូសតាងទី៣៖** ក្របខ័ណ្ឌស្ថាប័នបច្ចុប្បន្ននៃលទ្ធកម្មរដ្ឋាភិបាលបៃតងនៅប្រទេសម៉ាឡេស៊ី

គណៈកម្មាធិការលទ្ធកម្មរដ្ឋាភិបាលបៃតង (GPP Committee) ត្រូវបានបង្កើតនៅកម្រិតក្រសួង និងទីភ្នាក់ងារនីមួយៗ ដើម្បីជួយសម្របសម្រួលនៅតាមក្រសួង ក្នុងការរៀបចំផែនការលទ្ធកម្មបៃតង ដែលជាផ្នែកមួយនៃផែនការលទ្ធកម្មប្រចាំឆ្នាំរបស់សាមីក្រសួង។ ក្រៅពីព័ត៌មានលម្អិតផ្សេងទៀត គណៈកម្មាធិការនេះក៏នៅមានព័ត៌មានលម្អិតស្តីពីតម្លៃប៉ាន់ស្មាននៃលទ្ធកម្មបៃតងដែរ ដែលត្រូវដាក់ជូនក្រសួងហិរញ្ញវត្ថុសម្រាប់បូកសរុប និងវិភាជន៍ថែកថវិកា។ អភិក្រមបែបនេះ នឹងធានាដល់ការវិភាជន៍ថវិកាគ្រប់គ្រាន់ឱ្យទៅក្រសួងនានា សម្រាប់ទិញផលិតផល និងសេវាកម្ម ស្របតាមលក្ខណៈវិនិច្ឆ័យ។

ម៉ាឡេស៊ីក៏មានកម្មវិធីលើកទឹកចិត្តសារពើពន្ធចំនួនពីរផងដែរ ពោលគឺកម្មវិធីលើកទឹកចិត្តផ្នែកបច្ចេកវិទ្យាបៃតង និងគម្រោងហិរញ្ញប្បទានបច្ចេកវិទ្យាបៃតង ដើម្បីលើកទឹកចិត្តឧស្សាហកម្មសម្រាប់ធ្វើការស្រាវជ្រាវ, ការរចនា/រៀបចំចងក្រង និងការអភិវឌ្ឍបច្ចេកវិទ្យាបៃតងក្នុងគោលដៅលើកកម្ពស់ការវិនិយោគប្រកបដោយនិរន្តរភាព និងលទ្ធកម្មរដ្ឋាភិបាលបៃតង។

ការរៀបចំស្ថាប័នដូចរៀបរាប់ខាងលើនេះបង្ហាញឱ្យឃើញថា ប្រទេសម៉ាឡេស៊ីបានបង្កើតបណ្តាញប្រាស្រ័យទាក់ទងច្បាស់លាស់ក៏ដូចជារចនាសម្ព័ន្ធរាយការណ៍ ដើម្បីជួយសម្រួលប្រកបដោយប្រសិទ្ធផលក្នុងចំណោមភាគីពាក់ព័ន្ធ ធ្វើឱ្យប្រសើរឡើងបរិយាកាសសហការល្អ សម្រាប់អនុវត្តលទ្ធកម្មសាធារណៈបៃតងឱ្យកាន់តែមានប្រសិទ្ធភាព។

## ៤.៥. គោលការណ៍ណែនាំ និងលក្ខណៈវិនិច្ឆ័យ

ដូចដែលបានលើកឡើងនៅខាងលើ គណៈកម្មាធិការការងារលទ្ធកម្មរដ្ឋាភិបាលបៃតង ត្រូវបានបង្កើតឡើងដើម្បីរៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រទាក់ទងនឹងលទ្ធកម្មរដ្ឋាភិបាលបៃតង រៀបចំផែនការសកម្មភាពលទ្ធកម្មរដ្ឋាភិបាលបៃតង និងដើម្បីជួយសម្របសម្រួល និងវាយតម្លៃការអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង នៅតាមក្រសួង និងស្ថាប័ននានា។ គោលការណ៍ណែនាំសម្រាប់មន្ត្រីលទ្ធកម្មរបស់រដ្ឋាភិបាល ដែលបានបោះពុម្ពក្នុងឆ្នាំ២០១៤ ផ្តល់ព័ត៌មានមានប្រយោជន៍ អំពីរបៀបច្របាច់បញ្ចូលលក្ខណៈវិនិច្ឆ័យបរិស្ថាន នៅក្នុងដំណាក់កាលនីមួយៗនៃដំណើរការលទ្ធកម្ម។ នៅឆ្នាំ២០២០ គោលការណ៍ណែនាំដដែលនេះត្រូវបានបោះពុម្ពជាលើកទី៣ ដោយបានធ្វើបច្ចុប្បន្នភាព លក្ខណៈវិនិច្ឆ័យលទ្ធកម្មរដ្ឋាភិបាលបៃតង សម្រាប់ផលិតផល និងសេវាកម្មបៃតងចំនួន ៤០មុខ ដូចជា ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) ប្រព័ន្ធម៉ាស៊ីនត្រជាក់ និងសេវាកម្មសម្អាត[17]។ ក្នុងនោះ ឧបករណ៍ដ៏សំខាន់មួយទៀត ត្រូវបានបង្កើតឡើង សម្រាប់ធ្វើការគណនាការចំណាយថ្លៃដើមក្នុងមួយវដ្តរបស់ផលិតផល និងសេវាកម្ម (life-cycle cost)។

និយាយជារួមម៉ាឡេស៊ីបានអនុវត្តជាជំហានៗក្នុងការជ្រើសរើសផលិតផលនិងសេវាកម្មអាទិភាពសម្រាប់អនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការដឹកនាំលទ្ធកម្មរដ្ឋាភិបាលបៃតង។ នៅពេលជ្រើសរើសលក្ខណៈវិនិច្ឆ័យសម្រាប់ផលិតផល និងសេវាកម្មបៃតង គណៈកម្មាធិការដឹកនាំលទ្ធកម្មរដ្ឋាភិបាលបៃតង យកចិត្តទុកដាក់លើភាពពាក់ព័ន្ធផ្នែកសេដ្ឋកិច្ចឥទ្ធិពលដែលរំពឹងទុក អត្ថិភាពនៃស្លាកអេកូ និងស្តង់ដា និងការត្រៀមខ្លួនសម្រាប់ទីផ្សារ។ លក្ខណៈវិនិច្ឆ័យនៃលទ្ធកម្មរដ្ឋាភិបាលបៃតង ត្រូវបានតម្រឹមយ៉ាងល្អជាមួយកម្មវិធីស្លាកអេកូប្រភេទទី១ (Type 1 Eco-Labelling Schemes) អនុលោមតាមលក្ខខណ្ឌតម្រូវថ្នាក់ជាតិ និងអន្តរជាតិ។ ការធ្វើបច្ចុប្បន្នភាពជាទៀងទាត់ គឺដើម្បីធានាថា លក្ខណៈវិនិច្ឆ័យទាំងឡាយដែលបានបង្កើតឡើងឆ្លើយតបទៅតាមការវិវត្តនៃស្តង់ដាបរិស្ថាន និងការអនុវត្តគំនិតផ្តួចផ្តើមផ្សេងៗក្នុងការលើកកម្ពស់ទីផ្សារ ដែលអាចឱ្យមន្ត្រីលទ្ធកម្មធ្វើការសម្រេចចិត្តដោយមានការយល់ដឹងគ្រប់គ្រាន់ និងមានជំរើសល្អៗប្រកបដោយនិរន្តរភាព។

## ៤.៦. កម្មវិធីកសាងសមត្ថភាព បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង

ប្រទេសម៉ាឡេស៊ីបានអនុវត្តកម្មវិធីពង្រឹងសមត្ថភាព និងលើកកម្ពស់ការយល់ដឹងគ្រប់ជ្រុងជ្រោយមួយ ផ្តើមចេញពីការទទួលស្គាល់តម្រូវការ ចាំបាច់ក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ និងចំណេះជំនាញរបស់មន្ត្រីលទ្ធកម្មនៅគ្រប់កម្រិត។

សាជីវកម្មម៉ាឡេស៊ីសម្រាប់បច្ចេកវិទ្យាបៃតង និងការប្រែប្រួលអាកាសធាតុ ក្រោមកម្មវិធីលទ្ធកម្ម MyHIJAU បានរៀបចំសិក្ខាសាលាជាច្រើន, បោះពុម្ពកូនសៀវភៅស្តីពីលទ្ធកម្មរដ្ឋាភិបាលបៃតង ដើម្បីបង្កើតការយល់ដឹងក្នុងចំណោមអ្នកធ្វើលទ្ធកម្ម និងបានរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល ផងដែរ។ ការកសាងសមត្ថភាព និងឱកាសសិក្សាបែបនេះ ធ្វើឡើងជាទៀងរាល់ឆ្នាំនៅគ្រប់ក្រសួង។ សាជីវកម្មម៉ាឡេស៊ីសម្រាប់បច្ចេកវិទ្យាបៃតង និងការប្រែប្រួលអាកាសធាតុ ក៏បានធ្វើផងដែរនូវបទបង្ហាញខ្លីស្តីពីលទ្ធកម្មរដ្ឋាភិបាលបៃតង ជូនវិស័យឯកជន ដើម្បីជួយឱ្យពួកគេបានជ្រាប់អំពីតម្រូវការលទ្ធកម្មរដ្ឋាភិបាលបៃតង ក៏ដូចជាបង្កើន

17 Available at https://www.myhijau.my/wp-content/uploads/2021/01/GGP-Guidelines-3.0.pdf Accessed on 23.11.2023

ការយល់ដឹងរបស់ពួកគេអំពីដំណើរការនៃលទ្ធកម្មនេះដែរ។ សាជីវកម្មនេះក៏មាន បណ្ឌិត្យសភាពបៃតង មួយដែរ ដែលឧទ្ទិសសម្រាប់ការបណ្តុះបណ្តាលមនុស្សអំពីបច្ចេកវិទ្យាបៃតង[18]។

គំនិតផ្តួចផ្តើមទាំងអស់នេះបង្ហាញថា ប្រទេសម៉ាឡេស៊ីមានកម្មវិធីយល់ដឹងយ៉ាងទូលំទូលាយ ដែលផ្តោតលើភាគីពាក់ព័ន្ធទាំងខាងក្នុង និងខាងក្រៅរដ្ឋាភិបាល ក្នុងគោលដៅបង្កើតការយល់ដឹងរួមគ្នាអំពីអត្ថប្រយោជន៍នៃលទ្ធកម្មបៃតង និងជំរុញការប្តេជ្ញាចិត្តរួមគ្នាចំពោះនិរន្តរភាព។

## ៤.៧. ការតាមដាន និងវាយតម្លៃ

ប្រទេសម៉ាឡេស៊ីក៏បានបង្កើតក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃដ៏រឹងមាំមួយ សម្រាប់វាយតម្លៃផលជះ និងប្រសិទ្ធភាពនៃការអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង។ ក្រសួងហិរញ្ញវត្ថុបានដាក់ចេញទម្រង់របាយការណ៍មួយ សម្រាប់ឱ្យគ្រប់ក្រសួងត្រូវតែរាយការណ៍អំពីការអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង លើផលិតផល និងសេវាកម្មចំនួន ៤០មុខ។ ក្រសួងទាំងអស់ត្រូវរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង ទៅសាជីវកម្មសម្រាប់បច្ចេកវិទ្យាបៃតង និងការប្រែប្រួលអាកាសធាតុ (MGTC) ពីរដងក្នុងមួយឆ្នាំ។ ចន្ទាប់មក MGTC នេះត្រូវបូកសរុបរបាយការណ៍ទាំងនោះ និងវិភាគទិន្នន័យមកពីគ្រប់ក្រសួងពាក់ព័ន្ធ ដើម្បីបង្ហាញលទ្ធផលការងារជូនគណៈកម្មាធិការដឹកនាំលទ្ធកម្មរដ្ឋាភិបាលបៃតង។

លើសពីនេះ ក្រសួងហិរញ្ញវត្ថុ បានប្របាច់បញ្ចូល GGP ទៅក្នុងលទ្ធកម្មសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិករបស់រដ្ឋាភិបាល ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង។ ប្រព័ន្ធនេះវាស់វែងគុណតម្លៃ និងដំណើការលទ្ធកម្ម (GGP) ដែលគិតជាភាគរយនៃការអនុវត្តកិច្ចលទ្ធកម្មសរុបលើបញ្ជីផលិតផលដែលបានអនុម័តរួចហើយ។ យោងតាមឯកសារផែនការម៉ាឡេស៊ីទី១២ វឌ្ឍនភាពនៃការអនុវត្តកិច្ចលទ្ធកម្មរដ្ឋាភិបាលបៃតងនៅប្រទេសម៉ាឡេស៊ីនៅចុងឆ្នាំ២០២០ គឺមានកម្រិតដល់ទៅ ២០,៧% ធៀបនឹងគោលដៅ ២០%[19]។ ការវាស់វែងក៏បានធ្វើដែរទៅលើសក្តានុពលនៃកាត់បន្ថយការបំភាយឧស្ម័នកាបូនិកដោយសារការទិញផលិតផលបៃតង។

## ៤.៨. កិច្ចសហការ និងភាពជាដៃគូ

ដំណើរការលទ្ធកម្មបៃតងរបស់ប្រទេសម៉ាឡេស៊ី មានលក្ខណៈពិសេសលើកត្តាសហការយ៉ាងល្អ និងភាពជាដៃគូរវាងតួអង្គពាក់ព័ន្ធផ្សេងៗ រួមទាំងអង្គការក្រៅរដ្ឋាភិបាលផងដែរ។ បណ្តាញលទ្ធកម្មបៃតង (GPN) របស់ម៉ាឡេស៊ី បានដើរតួនាទីយ៉ាងសកម្មក្នុងការកៀរគរតួអង្គរដ្ឋាភិបាល និងតួអង្គឧស្សាហកម្ម ឱ្យចូលរួមវេទិការួមមួយ សម្រាប់បង្កើតការយល់ដឹងក្នុងចំណោមឧស្សាហកម្ម និងពង្រីកការអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតងនៅក្នុងប្រទេស។

## ៤.៩. កំណត់ចំណាំ

ទោះបីជាជួបបញ្ហាប្រឈមខ្លះក្នុងការអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតងក៏ដោយ ក៏ម៉ាឡេស៊ីបានក្លាយជាប្រទេសលេចធ្លោក្នុងចំណោមប្រទេស ក្នុងតំបន់ក្នុងការត្រួសត្រាយផ្លូវ និងជំរុញឱ្យមានប្រព័ន្ធលទ្ធកម្មបៃតងឈានមុខគេ។ ខាងក្រោមជាមេរៀនដកពិសោធន៍សំខាន់ៗ ពីការអនុវត្តលទ្ធកម្មរដ្ឋាភិបាលបៃតង របស់ម៉ាឡេស៊ី៖

- កម្មវិធីលទ្ធកម្មរដ្ឋាភិបាលបៃតង គឺជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍ម៉ាឡេស៊ី ដូចមានចែងក្នុងផែនការម៉ាឡេស៊ីទី១១។
- គន្លឹះនៃភាពជោគជ័យរបស់ម៉ាឡេស៊ីក្នុងការអនុវត្តលទ្ធកម្មបៃតង គឺកម្មវិធីលទ្ធកម្មរដ្ឋាភិបាលបៃតង ដែលជាកាតព្វកិច្ចខានមិនបាន។
- យន្តការស្ថាប័នរឹងមាំ គឺជាការចាំបាច់ដើម្បីធានាការសម្របសម្រួលអន្តរក្រសួង លើការអនុវត្តកិច្ចលទ្ធកម្មបៃតង។
- ការបង្កើតគោលការណ៍ណែនាំសម្រាប់មន្ត្រីលទ្ធកម្មរបស់រដ្ឋាភិបាល និងការពិនិត្យកែសម្រួលជាប្រចាំ បានដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយ លទ្ធកម្មរដ្ឋាភិបាលបៃទង នៅកម្រិតមូលដ្ឋាន។

18 Available at https://www.mgtc.gov.my/what-we-do/green-academy-old/green-academy/ Accessed on 23.11.2023

19 12th Malaysia Plan 2021–2025, Available at https://pulse.icdm.com.my/wp-content/uploads/2021/09/Twelfth-Plan- Document_compressed-1.pdf, Accessed on 27.11.2023

- ទិដ្ឋភាពសំខាន់មួយទៀត គឺកម្មវិធីកសាងសមត្ថភាពស្ថាប័នដ៏មានប្រសិទ្ធភាព ត្រូវបានអនុវត្តទូលំទូលាយក្នុងគោលបំណងពង្រឹង ចំណេះដឹង និងសមត្ថភាពវិជ្ជាជីវៈមន្ត្រីលទ្ធកម្ម ដើម្បីឱ្យគេមានលទ្ធភាពជម្នះរាល់ភាពស្មុគស្មាញនៃប្រព័ន្ធលទ្ធកម្មប្រកបដោយ និរន្តរភាព។
- កម្មវិធីលើកទឹកចិត្តផ្នែកសារពើពន្ធ (a fiscal incentive programme) បន្តគាំទ្រ និងបង្កលក្ខណៈអំណោយផលដល់ឧស្សាហកម្មក្នុងការចាប់យកទម្លាប់អនុវត្តបៃតង បានជួយក្នុងការដោះស្រាយឧបសគ្គរបស់រដ្ឋាភិបាល (Supply-side) ទាក់ទងនឹងផលិតផល និងសេវាកម្មបៃតង។

# ៥. ប្រទេសថៃ



## គោលនយោបាយ

រដ្ឋាភិបាលថៃ ដាក់ចេញជាលើកដំបូងនូវផែនការលើកកម្ពស់លទ្ធកម្មសាធារណៈបៃតង។

## សមិទ្ធផលធំៗ

- លទ្ធកម្មសាធារណៈបៃតងរបស់ប្រទេសថៃមានការពាក់ព័ន្ធយ៉ាងល្អរវាងតួអង្គចម្រុះ ក្នុងការរៀបចំគោលនយោបាយ និងការបង្កើតលក្ខណៈ វិនិច្ឆ័យ ដោយជំរុញកិច្ចខិតខំ រួមគ្នាសម្រាប់ពង្រឹងទម្លាប់អនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាព។
- ក្រសួងធនធានធម្មជាតិ និងបរិស្ថាន ដឹកនាំការអនុវត្តលទ្ធកម្មសាធារណៈបៃតង ដោយសហការជាមួយក្រសួងហិរញ្ញវត្ថុ ដើម្បីពន្លឿនដំណើរការដ៏យូរនៃការកែសម្រួលបទប្បញ្ញត្តិ។

## មហិច្ឆតា

ជំរុញទៅមុខនូវការអនុវត្តលទ្ធកម្មសាធារណៈបៃតងជាកាតព្វកិច្ច ក៏ដូចជាការតាមដាន និងរាយការណ៍អំពីការអនុវត្ត GPP ។

## ការផ្តោត

ការសាងសង់ និងសម្ភារសំណង់ សណ្ឋាគារ ផលិតផល ICT យានជំនិះ សេវាសម្អាត សម្ភារការិយាល័យ។

## ៥.១. សេចក្តីផ្តើម

ការប្តេជ្ញាចិត្តរបស់ប្រទេសថៃចំពោះលទ្ធកម្មសាធារណៈបៃតង (GPP) មានតាំងពីឆ្នាំ២០០៥ មកម្ល៉េះ នៅពេលដែលនាយកដ្ឋានត្រួតពិនិត្យការបំពុល (PCD) ចាប់ផ្តើមអនុវត្តលទ្ធកម្មសាធារណៈបៃតងក្នុងក្របខ័ណ្ឌនៃក្រសួងធនធានធម្មជាតិ និងបរិស្ថាន។ ការប្តេជ្ញាចិត្តនេះត្រូវបានពង្រឹងជាបន្តបន្ទាប់តាមរយៈផែនការជាតិនានា ហើយនៅពេលថ្មីៗនេះ ការអនុម័តផែនការលើកកម្ពស់លទ្ធកម្មសាធារណៈបៃតងលើកទី៤ (២០២២-២០២៧) បានបង្ហាញកាន់តែច្បាស់ពីការយកចិត្តទុកដាក់របស់ប្រទេសថៃ ក្នុងការពង្រឹង និងពង្រីកលទ្ធកម្មសាធារណៈបៃតង។ ខណៈដែលក្របខ័ណ្ឌច្បាប់សម្រាប់លទ្ធកម្មសាធារណៈបៃតងកំពុងស្ថិតក្រោមការរៀបចំនៅឡើយ រដ្ឋាភិបាលបានដាក់ចេញបទប្បញ្ញត្តិមួយចំនួនសំដៅលើកកម្ពស់លទ្ធកម្មដែលមានមេត្រីបរិស្ថាន។ ទីភ្នាក់ងារសំខាន់ៗរួមមាន នាយកដ្ឋានត្រួតពិនិត្យការបំពុល, ក្រសួងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម កំពុងសហការគ្នាជំរុញលទ្ធកម្មសាធារណៈបៃតង ដោយប្រើស្លាកអេកូ និងពង្រឹងភាពជាដៃគូអន្តរជាតិដើម្បីពន្លឿនការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព។ ក្របខ័ណ្ឌលទ្ធកម្មសាធារណៈបៃតងគ្រប់ជ្រុងជ្រោយរបស់ថៃ បានឆ្លើយតបទៅនឹងផែនការដែលមានការវិវត្តទៅមុខជានិច្ច និងកិច្ចសហការល្អ បានរំលេចឱ្យឃើញនូវអភិក្រមបុរេសកម្មមួយ ក្នុងការធ្វើសមាហរណកម្មទម្លាប់អនុវត្តន៍បៃតងទៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈ។

## ៥.២. ការបង្កើតគោលនយោបាយ

ចាប់តាំងពីឆ្នាំ២០០៥ មក រដ្ឋាភិបាលថៃបានជំរុញយ៉ាងសកម្មនូវលទ្ធកម្មសាធារណៈបៃតង។ នាយកដ្ឋានត្រួតពិនិត្យការបំពុលបាននាំមុខក្នុងការអភិវឌ្ឍលទ្ធកម្មសាធារណៈបៃតង និងបានផ្តួចផ្តើមការអនុវត្តសាកល្បងនៅក្នុងក្រសួងធនធានធម្មជាតិ និងបរិស្ថាន។

ក្នុងឆ្នាំ២០០៧ លទ្ធកម្មសាធារណៈបៃតងបានក្លាយជាផ្នែកនៃផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិលើកទី១០ (២០០៧-២០១១) និង ផែនការគ្រប់គ្រងគុណភាពបរិស្ថាន (២០០៧-២០១១) ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនូវការយល់ដឹងអំពីគោលនយោបាយលទ្ធកម្មសាធារណៈបៃតង។ ផែនការទី១០នេះ បានសង្កត់ធ្ងន់លើតួនាទីរបស់វិស័យសំខាន់ៗនៃរដ្ឋាភិបាលជាអ្នកដឹកនាំក្នុងការអនុវត្តកិច្ចលទ្ធកម្មបៃតង ដើម្បីជំរុញទីផ្សារសមស្របសម្រាប់ផលិតផល និងសេវាកម្មបរិស្ថាន។ លទ្ធកម្មសាធារណៈបៃតង ត្រូវបានបញ្ចូលជាបន្តបន្ទាប់ទៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិលើកទី១១ ទី១២ និងទី១៣ (២០២៣-២០២៧)។

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨ សេចក្តីសម្រេចចិត្តមួយរបស់គណៈរដ្ឋមន្ត្រី បានអនុម័ត**ផែនការស្តីពីការលើកកម្ពស់លទ្ធកម្មសាធារណៈ បៃតងលើកទី១ (២០០៨-២០១១)** សម្រាប់រដ្ឋាភិបាលថ្នាក់កណ្តាល។ ផែនការនេះមានគោលបំណងជំរុញ និងចាប់ផ្តើមការអនុវត្តលទ្ធកម្មសាធារណៈបៃតងក្នុងវិស័យនានារបស់រដ្ឋាភិបាល ដោយបានបង្កើតឧបករណ៍គ្រប់គ្រាន់ដើម្បីគាំទ្រការអនុវត្ត GPP។

ក្នុងឆ្នាំ២០១២ សេចក្តីព្រាង**ផែនការជំរុញលទ្ធកម្មសាធារណៈបៃតងលើកទី២ (២០១៣-២០១៦)** ត្រូវបានបង្កើតឡើងដើម្បីពង្រីកវិសាលភាពនៃលទ្ធកម្មសាធារណៈបៃតង ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន វិស័យឯកជន និងសាធារណៈជនទូទៅ។ ទន្ទឹមនឹងការរង់ចាំសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីបន្ទាប់ពីមានការអនុម័តដោយក្រុមប្រឹក្សាបរិស្ថានជាតិក៏ដោយ នាយកដ្ឋានត្រួតពិនិត្យការបំពុល បានផ្តួចផ្តើមសកម្មភាពលទ្ធកម្មសាធារណៈបៃតងក្រោមផែនការរួចទៅហើយ។ គោលបំណងចម្បងនៃផែនការទី២ គឺដើម្បីលើកទឹកចិត្តទីភ្នាក់ងាររដ្ឋ ឱ្យអនុវត្តលទ្ធកម្មសាធារណៈបៃតង, គាំទ្រវិស័យឯកជនក្នុងផលិតកម្មបៃតង, និងជំរុញវត្តមានផលិតផលបៃតងនៅលើទីផ្សារ ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព។

ក្នុងឆ្នាំ២០១៦ រដ្ឋាភិបាលថៃបានបង្កើតផែនទីជាតិបង្ហាញផ្លូវមួយស្តីពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព (២០១៧-២០២៣) ដោយទទួលបានការយល់ព្រមពីគណៈកម្មាធិការជាតិស្តីពីការអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងឆ្នាំ២០១៧។ ផែនទីបង្ហាញផ្លូវនេះផ្តល់ជាគោលការណ៍ណែនាំ ដើម្បីបង្កើនសមត្ថភាពក្នុងសម្រួចប្រសិទ្ធផលធនធាន កំណើនប្រកបដោយបរិយាបន្ន និងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ដោយក្នុងនោះលទ្ធកម្មសាធារណៈបៃតង ត្រូវបានកំណត់ថាជាផ្នែកមួយក្នុងចំណោមវិស័យអាទិភាពក្រោមផែនទីបង្ហាញផ្លូវ។

ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ការអនុវត្តលទ្ធកម្មសាធារណៈបៃតង នៅតែបន្តដំណើរការ ទោះជាផែនការលើកកម្ពស់លទ្ធកម្មសាធារណៈបៃតងលើកទី៣មិនទាន់មានការអនុម័តជាផ្លូវការក៏ដោយ ដោយសារតែការផ្លាស់ប្តូរខ្លះ នៅក្នុងពិធីការអនុម័តរបស់រដ្ឋាភិបាលថៃ។ យ៉ាងណាក៏ដោយ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ ក្រុមប្រឹក្សាបរិស្ថានជាតិបានអនុម័ត**ផែនការស្តីពីលើកកម្ពស់លទ្ធកម្មសាធារណៈបៃតង លើកទី៤ (២០២២-២០២៧)** ដែលមានការគាំទ្រពីសំណាក់ EU SWITCH-Asia SCP Facility។ ផែនការនេះមានគោលបំណងបង្កើនចំនួនទីភ្នាក់ងារចូលរួម ឱ្យគ្របដណ្តប់លើទីភ្នាក់ងាររដ្ឋាភិបាលកថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន, សហគ្រាសរដ្ឋ, ស្ថាប័នសាធារណៈ និងស្ថាប័នអប់រំរបស់រដ្ឋាភិបាល។ គោលដៅសំខាន់ៗរួមមានការជំរុញកំណើនសមាមាត្រនៃលទ្ធកម្មបៃតងទាំងក្នុងផ្នែករូបិយវត្ថុ និងចំនួនផលិតផល និងសេវាកម្មដែលបានទិញ។

## ៥.៣. ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ

ដោយសារប្រទេសថៃខ្វះបទប្បញ្ញត្តិជាក់លាក់ស្តីពីលទ្ធកម្មសាធារណៈបៃតង ការរៀបចំក្របខ័ណ្ឌគោលនយោបាយ ជាពិសេសគោលនយោ បាយលើកកម្ពស់លទ្ធកម្មសាធារណៈបៃតង ជួបផលវិបាកខ្លះៗ។ នៅឆ្នាំ២០២២ ក្រសួងហិរញ្ញវត្ថុបានឆ្លើយតបដោយបានដាក់ចេញ *បទប្បញ្ញត្តិក្រសួង៖ ការកំណត់វិធីលទ្ធកម្ម និងកិច្ចសន្យាសម្រាប់ទំនិញ និងសេវាកម្មដែលត្រូវបានលើកកម្ពស់ ឬគាំទ្រដោយរដ្ឋ (កំណែទី២) ព.ស. ២៥៦៣*។ បទប្បញ្ញត្តិនេះផ្តល់គោលការណ៍ណែនាំ និងនីតិវិធីសម្រាប់លទ្ធកម្ម និងកិច្ចសន្យាទំនិញ និងសេវាកម្ម ដែលអាចទទួលបានការលើកកម្ពស់ ឬគាំទ្រដោយរដ្ឋាភិបាលថៃ។ មាត្រា ៧/២ នៃបទប្បញ្ញត្តិនេះបញ្ជាក់ថា ផលិតផលមេត្រីបរិស្ថាន ដែលត្រូវបានចុះបញ្ជីដោយនាយកដ្ឋានត្រួតពិនិត្យការបំពុល គឺជាផលិតផលដែលរដ្ឋមានបំណងលើកកម្ពស់ ឬគាំទ្រ។

## ៥.៤. ការរៀបចំស្ថាប័ន

លទ្ធកម្មសាធារណៈបៃតង ត្រូវបានផ្តួចផ្តើមដោយ**ក្រសួងធនធានធម្មជាតិ និងបរិស្ថាន** ដែលមាន**នាយកដ្ឋានត្រួតពិនិត្យ**

**ការបំពុល** ដឹកនាំការអនុវត្តផែនការលើកកម្ពស់លទ្ធកម្មសាធារណៈបៃតង។ គណៈកម្មាធិការចំនួនបួន ជាអ្នកត្រួតត្រាមើលលើលទ្ធកម្មសាធារណៈបៃតង (គំនូសតាងទី៤) រួមមាន **ក្រុមប្រឹក្សាត្រួតពិនិត្យការបំពុល, អនុគណៈកម្មាធិការផ្សព្វផ្សាយលើកកម្ពស់លទ្ធកម្មសាធារណៈបៃតង, អនុគណៈកម្មាធិការបច្ចេកទេសនៃលទ្ធកម្មសាធារណៈបៃតង និងអនុគណៈកម្មាធិការសម្រាប់ការចុះបញ្ជីផលិតផល និងសេវាកម្មបៃតង**។ ក្រុមប្រឹក្សាត្រួតពិនិត្យការបំពុលបានអនុម័តផែនការ និងលក្ខណៈវិនិច្ឆ័យលទ្ធកម្មសាធារណៈបៃតង ខណៈអនុគណៈកម្មាធិការលើកកម្ពស់លទ្ធកម្មសាធារណៈបៃតងជាអ្នកអនុម័តលើប្រភេទផលិតផល និងលក្ខណៈវិនិច្ឆ័យបន្ថែម។ អនុគណៈកម្មាធិការបច្ចេកទេសលទ្ធកម្មសាធារណៈបៃតងជាអ្នករៀបចំលក្ខណៈវិនិច្ឆ័យសម្រាប់ស្នើទៅក្រុមប្រឹក្សាត្រួតពិនិត្យការបំពុល, ធ្វើការសម្របសម្រួលវិធីសាស្ត្រសាកល្បង និងត្រួតត្រាមើលការអនុវត្តលទ្ធកម្មសាធារណៈបៃតង ដោយសហការជាមួយអនុគណៈកម្មាធិការលើកកម្ពស់លទ្ធកម្មសាធារណៈបៃតង។




**គំនូសតាងទី៤៖** ក្របខ័ណ្ឌស្ថាប័នរបស់លទ្ធកម្មសាធារណៈបៃតងនៅប្រទេសថៃ[20]

**នាយកដ្ឋានត្រួតពិនិត្យការបំពុល** (PCD) ដែលនៅក្រោមឱវាទក្រសួងធនធានធម្មជាតិ និងបរិស្ថាន បានធ្វើការសាកល្បងអនុវត្តកម្មវិធីលទ្ធកម្មសាធារណៈបៃតងរបស់ប្រទេសថៃ។ នាយកដ្ឋាននេះ ទទួលបន្ទុកលើការជ្រើសរើសផលិតផល និងការបង្កើតផលិតផល និងលក្ខណៈវិនិច្ឆ័យសេវាកម្មនៃលទ្ធកម្មសាធារណៈបៃតង។ នាយកដ្ឋានដើរតួនាទីយ៉ាងសំខាន់មួយទៀត ក្នុងការអនុវត្តលទ្ធកម្មសាធារណៈបៃតង, ការតាមដាន និងរាយការណ៍, ត្រួតពិនិត្យលើការវាយតម្លៃ, ធ្វើការកែសម្រួល, និងការពង្រីកសក្ដានុពលនៃកម្មវិធីទៅកាន់ទីភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត។ នាយកដ្ឋាននេះ ក៏ជាលេខាធិការដ្ឋានរបស់អនុគណៈកម្មាធិការលើកកម្ពស់លទ្ធកម្មសាធារណៈបៃតង និងអនុគណៈកម្មាធិការបច្ចេកទេសលទ្ធកម្មសាធារណៈបៃតង ផងដែរ។

**ក្រសួងហិរញ្ញវត្ថុ៖** អគ្គនាយកដ្ឋានហិរញ្ញិក (CGD) ជាទីភ្នាក់ងារសំខាន់ក្នុងការធ្វើលទ្ធកម្មសាធារណៈបៃតង។ ជាអ្នកទទួលខុសត្រូវលើការបង្កើតច្បាប់ និងបទប្បញ្ញត្តិលទ្ធកម្ម អគ្គនាយកដ្ឋាននេះបែងចែកថវិកាទៅដល់ទីភ្នាក់ងាររដ្ឋាភិបាល និងត្រួតពិនិត្យលើការចំណាយថវិកា។ ចាប់ពីឆ្នាំ២០០៨ បន្ទាប់ពីមានការអនុម័តផែនការលើកកម្ពស់លទ្ធកម្មសាធារណៈបៃតង នាយកដ្ឋាននេះបានចេញលិខិតជាបន្តបន្ទាប់ទៅកាន់ទីភ្នាក់ងាររដ្ឋាភិបាលទាំងអស់។ ដោយអនុលោមតាមបទប្បញ្ញត្តិរបស់ការិយាល័យនាយករដ្ឋមន្ត្រីស្ដីពីលទ្ធកម្ម លិខិតទាំងនេះលើកទឹកចិត្តឱ្យមានការធ្វើលទ្ធកម្មផលិតផល និងសេវាកម្មដែលមេត្រីបរិស្ថាន ក្នុងគោលបំណងពង្រឹងការគាំទ្រដល់ផែនការលើកកម្ពស់លទ្ធកម្មសាធារណៈបៃតង។ ក្នុងឆ្នាំ២០២០ ក្រសួងហិរញ្ញវត្ថុបានដាក់ចេញបទប្បញ្ញត្តិមួយ ដែលមានចំណងជើងថា *ការកំណត់វិធីលទ្ធកម្ម និងកិច្ចសន្យាសម្រាប់ទំនិញ និងសេវាកម្មដែលត្រូវបានលើកកម្ពស់ ឬគាំទ្រដោយរដ្ឋ (កំណែទី២) ព.ស. ២៥៦៣*។ បទប្បញ្ញត្តិនេះផ្ដល់ការណែនាំ និងនីតិវិធីសម្រាប់លទ្ធកម្ម និងកិច្ចសន្យាទំនិញ និងសេវាកម្មដែលមេត្រីបរិស្ថាន ដែលនឹងត្រូវបានលើកកម្ពស់ ឬគាំទ្រដោយរដ្ឋាភិបាលថៃ។

20 Modified from PCD (2023). Meeting document – GPP Promotion Subcommittee Meeting 1/2566.

**ក្រសួងឧស្សាហកម្ម៖** នាយកដ្ឋានការងារឧស្សាហកម្ម (DIW) ដើរតួនាទីសំខាន់ក្នុងការជំរុញផលិតកម្មប្រកបដោយនិរន្តរភាពនៅកម្រិតឧស្សាហកម្ម។ ក្រសួងឧស្សាហកម្មពង្រីកការគាំទ្រដល់ក្រុមហ៊ុនផលិត ដោយជួយពួកគេក្នុងការបង្កើនដំណើរការ និងផលិតផលដើម្បីបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់លទ្ធកម្មសាធារណៈបៃតង។

**នាយកដ្ឋានលើកកម្ពស់ឧស្សាហកម្ម** (DIP) មានភារកិច្ចលើកកម្ពស់ និងបីបាច់ថែរក្សាវិស័យឧស្សាហកម្មនៅក្នុងប្រទេសថៃ។ នាយកដ្ឋាននេះ គាំទ្រយ៉ាងសកម្មដល់ការធ្វើលទ្ធកម្មសាធារណៈបៃតង ដោយលើកទឹកចិត្តដល់ក្រុមហ៊ុនផលិតដែលមានគ្រឿងសម្ភារផលិតបៃតង និងការផលិតនូវផលិតផលបៃតង ដើម្បីបំពេញតាមលក្ខណៈសម្បត្តិសម្រាប់លទ្ធកម្មសាធារណៈបៃតង។

**នាយកដ្ឋានការប្រែប្រួលអាកាសធាតុ និងបរិស្ថាន** (DCCE) រួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព (SCP) ក្នុងចំណោមសាធារណជនទូទៅ, នៅតាមទីក្រុង និងសហគ្រាសធុនតូច និងមធ្យម តាមរយៈគំនិតផ្តួចផ្តើមនានា រួមមានកម្មវិធីពង្រឹងសមត្ថភាព ការអនុវត្តគម្រោង និងយុទ្ធនាការទំនាក់ទំនងសាធារណៈ។

**វិទ្យាស្ថានស្តង់ដាឧស្សាហកម្មថៃ** (TISI) ជាស្ថាប័នស្តង់ដាជាតិរបស់ប្រទេសថៃ។ វិទ្យាស្ថាននេះគ្រប់គ្រងគម្រោងកម្មវិធីស្លាកបៃតងថៃ (Thai Green Label Scheme) ដោយសហការជាមួយវិទ្យាស្ថានបរិស្ថានថៃ (TEI)។

**វិទ្យាស្ថានបរិស្ថានថៃ** (TEI) ជាអង្គការក្រៅរដ្ឋាភិបាលដែលដើរតួនាទីសំខាន់ៗជាច្រើន ក្នុងកិច្ចការពារអាកាសធាតុ ការកាត់បន្ថយការបំភាយឧស្ម័ន និងការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព តាមរយៈការស្រាវជ្រាវ ការអនុវត្តគម្រោង ការពិគ្រោះយោបល់ និងការរៀបចំវគ្គបណ្តុះបណ្តាលលើប្រធានបទបរិស្ថាន។ វិទ្យាស្ថាននេះជាលេខាធិការដ្ឋានសម្រាប់ស្លាកបៃតងថៃ។

## ៥.៥. គោលការណ៍ណែនាំ និងលក្ខណៈវិនិច្ឆ័យ

នាយកដ្ឋានត្រួតពិនិត្យការបំពុល ទទួលខុសត្រូវក្នុងការរៀបចំបង្កើត និងការធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំលទ្ធកម្មសាធារណៈបៃតង។

ស្លាកអេកូ (ecolabel) ដើរតួនាទីយ៉ាងសំខាន់នៅក្នុងលទ្ធកម្មសាធារណៈបៃតងរបស់ប្រទេសថៃ ដោយផ្តល់ជាឧបករណ៍សម្រាប់ឱ្យមន្ត្រីលទ្ធកម្មមានភាពងាយស្រួលក្នុងការកំណត់អត្តសញ្ញាណផលិតផលបៃតង។ នៅប្រទេសថៃ ស្រដៀងគ្នាទៅនឹងប្រទេសជាច្រើនដែរ ស្លាកអេកូត្រូវបានបង្កើតឡើងមុនពេលចាប់ផ្តើមអនុវត្តលទ្ធកម្មសាធារណៈបៃតង ហើយតាមរយៈនេះវាដើរតួជាប្រភពយោងសំខាន់មួយ សម្រាប់លក្ខណៈវិនិច្ឆ័យលទ្ធកម្មសាធារណៈបៃតង សម្រាប់ផលិតផល និងសេវាកម្ម។ គួរកត់សំគាល់ថាស្លាកបៃតងថៃ (TGL) ជាកម្មវិធីស្លាកបរិស្ថានដំបូងគេរបស់ថៃ ដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៩៣។ កម្មវិធីនេះ ធ្វើតាមស្តង់ដា Environmental Labeling Type-1 យោងតាម ISO 14024។

នៅក្នុងដំណាក់កាលដំបូងនៃការអនុវត្តលទ្ធកម្មសាធារណៈបៃតង លក្ខណៈវិនិច្ឆ័យផលិតផលរបស់កម្មវិធីស្លាកបៃតងថៃ (TGL) បានដើរតួជាវិធានយោងសម្រាប់ការបង្កើតលក្ខណៈវិនិច្ឆ័យលទ្ធកម្មសាធារណៈបៃតង (Green Cart)។ លក្ខណៈវិនិច្ឆ័យវិញ្ញាបនបត្រស្លឹកបៃតង (Green Leaf Certification) ត្រូវបានប្រើជាវិធានយោងសម្រាប់លក្ខណៈវិនិច្ឆ័យលទ្ធកម្មសាធារណៈបៃតង សម្រាប់សេវាកម្មស្នាក់នៅ (សណ្ឋាគារ)។ យ៉ាងណាក៏ដោយ ការអនុវត្តជាក់ស្តែងមិនដូចគ្នាទាំងអស់ទេ ដោយសារតែភាពខុសគ្នានៅក្នុងភាពតឹងរឹងនៃលក្ខណៈវិនិច្ឆ័យបរិស្ថាន ម៉្យាងទៀតដោយសារផលិតផលដែលមានការបញ្ជាក់ TGL សម្រាប់ទីផ្សារលទ្ធកម្មសាធារណៈបៃតង មានបរិមាណមិនជាច្រើនប៉ុន្មានដែរ។ ផលិតផលដែលមានវិញ្ញាបនបត្រ TGL និងសណ្ឋាគារដែលមានវិញ្ញាបនបត្រ Green Leaf ត្រូវបានចាត់ទុកថាស្របតាមលក្ខណៈវិនិច្ឆ័យលទ្ធកម្មសាធារណៈបៃតង ហើយអាចត្រូវបានចុះបញ្ជិកាក្នុងកាតាឡុកលទ្ធកម្មសាធារណៈបៃតង។ ផលិតផលដែលមិនមានវិញ្ញាបនបត្រណាមួយក្នុងចំណោមវិញ្ញាបនបត្រទាំងពីរនេះ ត្រូវតែដាក់ឯកសារ និងរបាយការណ៍តេស្តស្របតាមលក្ខណៈវិនិច្ឆ័យលទ្ធកម្មសាធារណៈបៃតង ទៅឱ្យនាយកដ្ឋានត្រួតពិនិត្យការបំពុល (PCD) ធ្វើការផ្ទៀងផ្ទាត់ និងអនុម័ត មុននឹងអាចចុះបញ្ជិកាក្នុងកាតាឡុកលទ្ធកម្មសាធារណៈបៃតង បាន។ មិនយូរប៉ុន្មាន ចំនួននៃផលិតផលដែលទទួលបានវិញ្ញាបនបត្រ TGL និងសណ្ឋាគារដែលមានវិញ្ញាបនបត្រ Green Leaf នៅលើទីផ្សារបានកើនឡើងជាបន្តបន្ទាប់ ក្រោយពីមានការអនុវត្តផែនការលើកកម្ពស់ផលិតផលបៃតង ។

បញ្ជីលទ្ធកម្មសាធារណៈបៃតងដំបូងគេនៅប្រទេសថៃ ក្នុងឆ្នាំ២០០៨ មានផលិតផល ១៤មុខ និងសេវាកម្ម ៣មុខ ដែលលក្ខណៈវិនិច្ឆ័យរបស់វាត្រូវបាននាយកដ្ឋានត្រួតពិនិត្យការបំពុលបង្កើតឡើង។ ភាគច្រើននៃផលិតផល និងសេវាកម្មទាំងនោះ ទាក់ទងនឹងសកម្មភាពការិយាល័យរដ្ឋាភិបាល ដូចជា សម្ភារការិយាល័យ រថយន្តដឹកអ្នកដំណើរ សេវាសម្អាត។ល។ បន្ទាប់មក នៅក្នុង

ដំណាក់កាលទីពីរនៃផែនការលើកកម្ពស់លទ្ធកម្មសាធារណៈបៃតង អនុគណៈកម្មាធិការបច្ចេកទេសត្រូវបានតែងតាំងឡើង និងប្រគល់ភារកិច្ចឱ្យទទួលខុសត្រូវចំពោះការរៀបចំបង្កើតលក្ខណៈវិនិច្ឆ័យលទ្ធកម្មសាធារណៈបៃតង។ អនុគណៈកម្មាធិការនេះមានតំណាងមកពីទីភ្នាក់ងាររដ្ឋាភិបាល មន្ទីរពិសោធន៍ អង្គការក្រៅរដ្ឋាភិបាល វិស័យឯកជន អ្នកជំនាញមកពីស្ថាប័នបរិស្ថាន និងទីភ្នាក់ងារពាក់ព័ន្ធសម្រាប់ផលិតផល និងសេវាកម្មដែលបានជ្រើសរើស។

ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការ និងនៃនិន្នាការឆ្ពោះទៅរកការប្រើប្រាស់បៃតង រដ្ឋាភិបាលមានគោលបំណងពង្រីកបញ្ជីលទ្ធកម្មសាធារណៈបៃតង ដើម្បីបញ្ចូលផលិតផលកាន់តែច្រើន និងពន្លឿនការបង្កើតលក្ខណៈវិនិច្ឆ័យលទ្ធកម្មសាធារណៈបៃតង រួមជាមួយនឹងការចុះបញ្ជិកាផលិតផលបៃតងនៅក្នុងកាតាឡុកលទ្ធកម្មសាធារណៈបៃតង។ វិញ្ញាបនបត្រស្លាកអេកូបន្ថែមទៀត ដូចជាប្រភេទ G-Mark សម្រាប់សណ្ឋាគារបៃតង, Cool Mode សម្រាប់សំលៀកបំពាក់ និងក្រណាត់ និង Carbon Footprint Reduction Label ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជិកាលទ្ធកម្មសាធារណៈបៃតង។ តារាងទី៣ ផ្តល់ទិដ្ឋភាពសង្ខេបអំពីស្លាកអេកូ ដែលត្រូវបានទទួលយកសម្រាប់ចុះបញ្ជីលទ្ធកម្មសាធារណៈបៃតងរបស់ថៃ។

ដើម្បីជួយសម្រួលដល់ការចុះបញ្ជីផលិតផលបៃតងទៅក្នុងកាតាឡុកលទ្ធកម្មសាធារណៈបៃតង នាយកដ្ឋានត្រួតពិនិត្យការបំពុល និងវិទ្យាស្ថានបរិស្ថានថៃ បានចុះហត្ថលេខាលើអនុស្សរណៈយល់គ្នាមួយ ក្នុងខែមីនា ឆ្នាំ២០២២ ដោយអនុញ្ញាតឱ្យផលិតផលថៃបិទស្លាកបៃតង (Green Label) ដែលទទួលបានវិញ្ញាបនបត្របញ្ជាក់ ដាក់បញ្ចូលទៅក្នុងកាតាឡុកលទ្ធកម្មសាធារណៈបៃតងនៃនាយកដ្ឋានត្រួតពិនិត្យការបំពុល។ លក្ខណៈវិនិច្ឆ័យស្លាកបៃតងថៃ (TGL) ត្រូវបានប្រើជាលក្ខខណ្ឌតម្រូវ សម្រាប់ការចុះបញ្ជីផលិតផល និងសេវាកម្មដែលមេត្រីបរិស្ថាន ជាមួយនាយកដ្ឋានត្រួតពិនិត្យការបំពុល។

គិតត្រឹមខែមីនា ឆ្នាំ២០២៣ កាតាឡុកលទ្ធកម្មសាធារណៈបៃតង មានបញ្ជីផលិតផលចំនួន ៥៤ប្រភេទ គ្របដណ្តប់លើផលិតផលដែលបានចុះបញ្ជីចំនួនប្រហែល ១៧០០មុខ។[21] កាតាឡុកលទ្ធកម្មសាធារណៈថៃ មាននៅលើអ៊ីនធឺណិត ក្នុងអាសយដ្ឋានវ៉េប http://gp.pcd.go.th/ (មានតែជាភាសាថៃទេ)។

**តារាងទី៣៖** សង្ខេបស្លាកអេកូ (ecolabel) ដែលបានទទួលយកសម្រាប់ចុះបញ្ជីលទ្ធកម្មសាធារណៈបៃតងថៃ

| ស្លាកអេកូ/វិញ្ញាបនបត្របញ្ជាក់ | ឡូហ្គោ | លម្អិត | ស្ថាប័នម្ចាស់ស្លាក/វិញ្ញាបនបត្រ |
|---|---|---|---|
| **ស្លាកអេកូប្រភេទ Type I និងវិញ្ញាបនបត្រ** | | ស្លាកបៃតងថៃ (ផលិតផល, សេវាកម្ម) / Thai Green Label (Products and services) | វិទ្យាស្ថានបរិស្ថានថៃ (TEI) |
| | | ស្លឹកបៃតង / Green Leaf (សម្រាប់សណ្ឋាគារ) | មូលនិធិស្លឹកបៃតង / Green Leaf Foundation |
| | | G-Mark (សម្រាប់សណ្ឋាគារ) | នាយកដ្ឋានប្រែប្រួលអាកាសធាតុ និងបរិស្ថាន (DCCE) |
| | | ប្រព័ន្ធគ្រប់គ្រងបរិស្ថាន (សេវាមួយចំនួន) | |
| | | ម៉ូដយូល (សម្លៀកបំពាក់ និងក្រណាត់) / Cool Mode (Clothes and fabric) | អង្គការគ្រប់គ្រងឧស្ម័នផ្ទះកញ្ចក់ថៃ (TGO) |
| **ស្លាករទេះបៃតង / Green Cart** | | ផលិតផល និងសេវាកម្មដែលផ្ទៀងផ្ទាត់ដោយនាយកដ្ឋានត្រួតពិនិត្យការបំពុល ស្របតាមលក្ខណៈវិនិច្ឆ័យលទ្ធកម្មសាធារណៈបៃតង | នាយកដ្ឋានត្រួតពិនិត្យការបំពុល (PCD) |
| **ស្លាកអេកូជម្រើសផ្សេង** | | ស្លាកសម្គាល់ការកាត់បន្ថយដានកាបូន | អង្គការគ្រប់គ្រងឧស្ម័នផ្ទះកញ្ចក់ថៃ (TGO) |

21 Pollution Control Department 2023. Report - GPP Promotion Subcommittee Meeting 1/2566 (in Thai).

## ៥.៦. កម្មវិធីកសាងសមត្ថភាព បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង

ជាទៀងទាត់ នាយកដ្ឋានត្រួតពិនិត្យការបំពុលធ្វើការបណ្តុះបណ្តាលស្តីពីលទ្ធកម្មសាធារណៈបៃតង ជូនមន្ត្រីលទ្ធកម្មរបស់រដ្ឋាភិបាល ដោយផ្តល់ព័ត៌មានអំពីសៀវភៅណែនាំអំពីលទ្ធកម្មសាធារណៈបៃតង, ការចំណាយថ្លៃដើមលើវដ្តនៃផលិតផល, ឧបករណ៍ចំណាយលើបរិស្ថាន និងការផ្តល់វេទិកាសម្រាប់ធ្វើសេចក្តីរាយការណ៍អំពីការអនុវត្តរបស់ខ្លួន។ ចាប់តាំងពីឆ្នាំ២០០៩ ទីភ្នាក់ងារផ្តើមៗបានទទួល "ពានរង្វាន់លទ្ធកម្មសាធារណៈបៃតង" (Green Public Procurement Recognition Award) ដោយផ្អែកលើលទ្ធផលដែលបានដាក់ជូនសម្រាប់ធ្វើការវិនិច្ឆ័យ។ លើសពីនេះទៀត គ្រោងការណ៍រង្វាន់ត្រូវបានអនុវត្តដែរ ជាការទទួលស្គាល់ការិយាល័យដែលមានសមិទ្ធកម្មគួរឱ្យសរសើរក្នុងការអនុវត្តលទ្ធកម្មសាធារណៈបៃតង និងអ្នកផលិត/អ្នកផ្តល់សេវាដែលផ្តល់ផលិតផល/សេវាកម្មបៃតងបានទៀងទាត់។

ប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីអនឡាញត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ ដើម្បីផ្សព្វផ្សាយចំណេះដឹង និងសម្រួលការប្រាស្រ័យទាក់ទងអំពីសកម្មភាពលទ្ធកម្មសាធារណៈបៃតង។ នាយកដ្ឋានត្រួតពិនិត្យការបំពុលផ្តល់ការផ្តល់ជំនួយទាន់ពេលវេលាដល់មន្ត្រីលទ្ធកម្មដោយដោះស្រាយរាល់សំណួរដែលពួកគេអាចមានអំពីលទ្ធកម្មសាធារណៈបៃតង។ វិធីសាស្ត្រឌីជីថលនេះបង្កើនភាពងាយស្រួល និងធានាបាននូវជំនួយទាន់ពេលវេលាក្នុងចំណាត់លទ្ធកម្មសាធារណៈបៃតង។

## ៥.៧. ការតាមដាន និងវាយតម្លៃ

នាយកដ្ឋានតាមដានត្រួតពិនិត្យការបំពុលទទួលបន្ទុកក្នុងការប្រមូលទិន្នន័យស្តីពីគុណផលនៃលទ្ធកម្មសាធារណៈបៃតង និងធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាត្រួតពិនិត្យការបំពុលជារៀងរាល់ឆ្នាំ។ វេទិការាយការណ៍លទ្ធកម្មសាធារណៈបៃតង (GPP Reporting Platform) សម្រាប់មន្ត្រីលទ្ធកម្ម មាននៅលើគេហទំព័រ http://gp.pcd.go.th/។ របាយការណ៍ការអនុវត្តន៍លទ្ធកម្មសាធារណៈចុងក្រោយបំផុតសម្រាប់ឆ្នាំសារពើពន្ធ២០២២ (ខែតុលា ឆ្នាំ២០២១ ដល់ខែកញ្ញា ឆ្នាំ២០២២, នាយកដ្ឋានត្រួតពិនិត្យការបំពុល ឆ្នាំ 2023) អាចសង្ខេបដូចខាងក្រោម៖

- ចំនួនទីភ្នាក់ងារចូលរួម:
  - ៨២% នៃទីភ្នាក់ងាររដ្ឋាភិបាលថ្នាក់កណ្តាល សហគ្រាសរដ្ឋ ក្រុមហ៊ុនសាធារណៈ និងសាកលវិទ្យាល័យចូលរួមនៅក្នុងកម្មវិធីលទ្ធកម្មសាធារណៈបៃតង។ ចំនួននេះគឺលើសពីគោលដៅឆ្នាំ២០២២ ដែលត្រូវបានកំណត់ត្រឹមតែ ៨០%។
  - ១៣% នៃទីភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋានចូលរួមក្នុងកម្មវិធីលទ្ធកម្មសាធារណៈបៃតង។ ចំនួននេះគឺទាបជាងគោលដៅឆ្នាំ២០២២ ដែលត្រូវបានកំណត់ ៦០% ។
- យោងតាមទិន្នន័យពីគេហទំព័ររបស់នាយកដ្ឋាន (http://gp.pcd.go.th/) មានសកម្មភាពលទ្ធកម្ម និងសកម្មភាពទិញទំនិញដែលមេត្រីបរិស្ថានសរុបចំនួន ៣៤៧១ នៅក្នុងប្រភេទផ្សេងៗគ្នា ដែលមានតម្លៃទឹកប្រាក់សរុបចំនួន ២១៧,៨លានបាត ឬ ៤៩% នៃតម្លៃសរុបនៃសកម្មភាពលទ្ធកម្ម និងការទិញទាំងអស់ដែលទីភ្នាក់ងារចូលរួមបានអនុវត្ត។ ឆ្លងតាមរយៈសកម្មភាពទាំងនេះ ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់មានប្រហែល ១ ៩០៨ ៨១៨kg$CO_2$e ដែលសមមូលទៅនឹងការកាត់បន្ថយការបំភាយឧស្ម័នពីរថយន្តចំនួន ១៩០៨គ្រឿង ក្នុងមួយឆ្នាំ។

វាជាការសំខាន់ក្នុងការកត់សម្គាល់ដែរថា ទិន្នន័យដែលបានដាក់ជូននាយកដ្ឋានត្រួតពិនិត្យការបំពុល តំណាងឱ្យតែ ១៣% នៃទីភ្នាក់ងារដែលចូលរួមប៉ុណ្ណោះ ដូច្នេះមានន័យថាវាមិនបានឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពជាក់ស្តែងបានពេញលេញនោះទេ។ ត្រង់នេះកាន់តែគូសបញ្ជាក់អំពីភាពចាំបាច់ឱ្យលទ្ធកម្មបៃតងរបស់ថៃបង្កើនដំណើរការនៃការតាមដាន ការរាយការណ៍ និងវាស់វែងឥទ្ធិពលរបស់វា ដើម្បីយល់ដឹងបានកាន់តែទូលំទូលាយ និងវាយតម្លៃភាពជាតំណាងនៃវឌ្ឍនភាពរបស់កម្មវិធី ឱ្យបានកាន់តែត្រឹមត្រូវថែមទៀត។

## ៥.៨. កិច្ចសហការ និងភាពជាដៃគូ

ក្រសួងធនធានធម្មជាតិ និងបរិស្ថាន - ដែលជាអ្នកនាំមុខនៃការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាពក្រោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDG12 - សហការយ៉ាងទូលំទូលាយជាមួយអង្គការអន្តរជាតិ លើសកម្មភាពជុំវិញការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព និងលទ្ធកម្មសាធារណៈបៃតង។ កិច្ចសហការគួរឱ្យកត់សម្គាល់រួមមាន៖

- **រដ្ឋាភិបាលអាល្លឺម៉ង់ (GIZ Thailand)៖** ចាប់តាំងពីឆ្នាំ២០១០ GIZ Thailand បានគាំទ្របច្ចេកទេសដល់លទ្ធកម្មសាធារណៈបៃតង និងការអនុវត្តការដាក់ស្លាកអេកូរបស់ប្រទេសថៃ។
- **EU SWITCH-Asia៖** ក្នុងឆ្នាំ២០១៦ EU SWITCH-Asia បានគាំទ្របច្ចេកទេសដល់ប្រទេសថៃក្នុងការរៀបចំបង្កើតផែនទីបង្ហាញផ្លូវស្តីពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព ដោយផ្តល់ជាក្របខ័ណ្ឌទូទៅសម្រាប់ការអនុវត្តលទ្ធកម្មសាធារណៈបៃតង។
- **គម្រោងភាពជាដៃគូលទ្ធកម្មសាធារណៈបៃតងរបស់អាស៊ីប៉ាស៊ីហ្វិក៖** ក្នុងឆ្នាំ២០១៧-២០១៨ គម្រោងនេះ - ដែលគាំទ្រមូលនិធិដោយឧស្សាហកម្ម និងបច្ចេកវិទ្យាបរិស្ថានកូរ៉េ (KEITI) និងអង្គការ UNEP តាមរយៈ 10YFP[22] សម្រាប់ការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព - បានគាំទ្រ លទ្ធកម្មសាធារណៈបៃតងនៅប្រទេសថៃ ដោយផ្តោតលើលក្ខណៈវិនិច្ឆ័យសម្រាប់សម្ភារសំណង់ យន្តការលើកទឹកចិត្ត និងការលើកកម្ពស់ការយល់ដឹង។
- **EU SWITCH-Asia (២០២០-២០២២)៖** ដោយសហការជាមួយបណ្តានាយកដ្ឋាននៃក្រសួងធនធានធម្មជាតិ និងបរិស្ថាន និង សហព័ន្ធឧស្សាហកម្មថៃ (FTI), EU SWITCH-Asia បានជួយបង្កើតផែនការលើកកម្ពស់លទ្ធកម្មសាធារណៈបៃតង លើកទី៤ (២០២២-២០២៧) ហើយបានដាក់បញ្ចូលប្រព័ន្ធចុះបញ្ជីអ្នកលក់ទៅក្នុងថ្នាលបញ្ជិកា Thai Green Directory។
- **កិច្ចសហការរវាងនាយកដ្ឋានត្រួតពិនិត្យការបំពុល និងវិទ្យាស្ថានបរិស្ថានថៃ** ក្នុងឆ្នាំ២០២២ លើការបញ្ចូលផលិតផល និងសេវាកម្មដែលមានការបញ្ជាក់របស់ Thai Green Label ទៅក្នុងបញ្ជីលទ្ធកម្មសាធារណៈបៃតង ដែលគ្រប់គ្រងដោយនាយកដ្ឋានត្រួតពិនិត្យការបំពុល។ កិច្ចសហការនេះមានគោលបំណងរួមបញ្ចូលឱ្យបានរលូននូវផលិតផលបៃតង ទៅក្នុងសកម្មភាពលទ្ធកម្មសាធារណៈបៃតង ដោយសម្របកិច្ចខិតខំប្រឹងប្រែងនានាដើម្បីលើកកម្ពស់ទម្លាប់អនុវត្តការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព។

## ៥.៩. កំណត់ចំណាំ

ការអនុវត្តលទ្ធកម្មសាធារណៈបៃតងរបស់ប្រទេសថៃ មានការចូលរួមល្អប្រសើរពីសំណាក់តួអង្គពាក់ព័ន្ធ ដោយជំរុញឱ្យមានការចូលរួមកាន់តែសកម្មពីភាគីពាក់ព័ន្ធចម្រុះជុំវិញការរៀបចំគោលនយោបាយ និងការបង្កើតលក្ខណៈវិនិច្ឆ័យលទ្ធកម្មសាធារណៈបៃតង។ អភិក្រមបែបបរិយាបន្ននេះ ធានាបាននូវកិច្ចខិតខំប្រឹងប្រែងរួមគ្នា ពង្រឹងការអនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាពក្នុងប្រទេស។

ការអនុវត្តលទ្ធកម្មសាធារណៈបៃតងតាមគោលការណ៍ស្ម័គ្រចិត្តនៅប្រទេសថៃ បានបណ្តាលឱ្យមានទីភ្នាក់ងារតិចជាង ១៥% ប៉ុណ្ណោះដែលបញ្ជូនរបាយការណ៍លទ្ធកម្មទៅនាយកដ្ឋានត្រួតពិនិត្យការបំពុល មានន័យថាការចូលរួមនៅមានកម្រិត ដែលអាចជាឧបសគ្គដល់គោលដៅនិរន្តរភាពដែរ។ ផែនការលើកកម្ពស់លទ្ធកម្មសាធារណៈបច្ចុប្បន្ន មានគោលបំណងធ្វើឱ្យលទ្ធកម្មសាធារណៈជាកាតព្វកិច្ច ដោយទទួលស្គាល់ពីតម្រូវការឱ្យមានកិច្ចខិតខំច្រើនទៀត ដើម្បីបង្កើតហេដ្ឋារចនាសម្ព័ន្ធចាំបាច់សម្រាប់ការអនុវត្តប្រកបដោយជោគជ័យ ជាមួយនឹងការទទួលស្គាល់នូវភាពចាំបាច់ក្នុងការធ្វើការផ្លាស់ប្តូរជាជំហានៗ ឆ្ពោះទៅរកលទ្ធកម្មសាធារណៈបៃតង។

ការរាយការណ៍អំពីលទ្ធកម្មសាធារណៈបៃតងនៅប្រទេសថៃ ធ្វើនៅលើថ្នាលដាច់ដោយឡែកពីថ្នាលរាយការណ៍លទ្ធកម្មធម្មតារបស់ក្រសួងហិរញ្ញវត្ថុ។ កាតាឡុកលទ្ធកម្មសាធារណៈបៃតង រួមមានផលិតផលដែលមានការបញ្ជាក់បៃតងដែលផុតកាលបរិច្ឆេទប្រើប្រាស់ ដូច្នេះវាទាមទារឱ្យមានការអាប់ដេតញឹកញាប់។ ការណ៍ដែលមានថ្នាលសម្រាប់រាយការណ៍ពីរទន្ទឹមគ្នាបែបនេះ អាចធ្វើឱ្យមន្ត្រីលទ្ធកម្មមិនសូវចង់ចូលរួមក្នុងលទ្ធកម្មសាធារណៈបៃតងដែរ ដោយសារតែតម្រូវការឱ្យដាក់របាយការណ៍ដល់ទៅពីរដង។

នៅប្រទេសថៃ លទ្ធកម្មសាធារណៈបៃតង ស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងធនធានធម្មជាតិ និងបរិស្ថាន ជាពិសេសនៅលើទិដ្ឋភាពបរិស្ថាន រីឯក្រសួងហិរញ្ញវត្ថុជាអ្នកមានអាជ្ញាបង្គំឱ្យអនុវត្ត។ លទ្ធកម្មសាធារណៈបៃតងកំពុងតែមានវឌ្ឍនភាពបន្តិចម្តងៗស្របពេលដែលក្រសួងធនធានធម្មជាតិ និងបរិស្ថាន ព្យាយាមធ្វើការប្រាស្រ័យទាក់ទង និងបញ្ចុះបញ្ចូលក្រសួងហិរញ្ញវត្ថុឱ្យកែប្រែច្បាប់ ដែលត្រង់នេះរំលេចឱ្យឃើញនូវបញ្ហាប្រឈមក្នុងការសម្របគោលនយោបាយ និងការអនុវត្ត រវាងអ្នកជំនាញបរិស្ថាន និងការអនុវត្តច្បាប់លទ្ធកម្ម។

22 10YFP: 10 Year Framework of Programmes on Sustainable Consumption and Production Patterns

# ៦. វៀតណាម



## គោលនយោបាយ

វៀតណាមអនុម័តច្បាប់ដេញថ្លៃឆ្នាំ២០២៣ ស្របតាមយុទ្ធសាស្ត្រកំណើនបៃតងជាតិ (២០២១-២០៣០)។

## កត្តាជោគជ័យធំៗ

- ការប្តេជ្ញាចិត្តផ្នែកនយោបាយ៖ លទ្ធកម្មសាធារណៈបៃតងត្រូវបានកំណត់ថាជាឧបករណ៍គន្លឹះដើម្បីសម្រេចបាននូវកំណើនបៃតង នៅក្នុងផែនការសកម្មភាពជាតិស្តីពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព (២០២១-២០៣០) និងយុទ្ធសាស្ត្រកំណើនបៃតងជាតិ (២០២១-២០៣០)។
- ការរៀបចំស្ថាប័ន៖ តួនាទី និងការទទួលខុសត្រូវច្បាស់លាស់ត្រូវបានកំណត់ក្នុងចំណោមក្រសួងនៅក្នុងផែនការសកម្មភាពជាតិស្តីពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព។

## មហិច្ឆតា

ចេញអនុក្រឹត្យ និងសារាចរ ស្របតាមច្បាប់ដេញថ្លៃថ្មី ឆ្នាំ២០២៣ ដើម្បីសម្រេចបាននូវគោលដៅលទ្ធកម្មសាធារណៈបៃតង ៣៥% និង ៥០% នៃលទ្ធកម្មសាធារណៈសរុប នៅឆ្នាំ២០៣០ និងឆ្នាំ២០៥០។

## ការផ្តោត

សម្ភារសំណង់ ផលិតផល ICT ផលិតផលកសិកម្ម គ្រឿងអគ្គិសនី។

## ៦.១. សេចក្តីផ្តើម

វៀតណាម ជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានការលូតលាស់លឿនបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយបានប្រឹងប្រែងខ្លាំងក្នុងការធ្វើឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងនិរន្តរភាព។ ឯកសារសេចក្តីសម្រេចចិត្តនៃមហាសន្និបាតជាតិលើកទី១៣ របស់បក្សកុម្មុយនិស្តវៀតណាម បានដាក់ "ការកសាងសេដ្ឋកិច្ចបៃតង និងចក្រាដែលមានមេត្រីបរិស្ថាន" ជាចំណុចស្នូលនៅលើមាគ៌ាអភិវឌ្ឍន៍របស់ប្រទេសសម្រាប់រយៈពេល ២០២១-២០៣០។ រដ្ឋាភិបាលបានចាត់វិធានការជាច្រើន និងធ្វើឱ្យសំណុំគោលនយោបាយដែលមានស្រាប់របស់ខ្លួនកាន់តែមានភាពចុះសម្រុងគ្នា ដើម្បីឈានទៅសម្រេចគោលបំណងនេះក្នុងរយៈពេលខ្លី មធ្យម និងវែង។ នៅក្នុងច្បាប់ស្តីពីការដេញថ្លៃ 22/2023/QH15 ដែលទើបអនុម័តថ្មីៗនេះ (ខែមិថុនា ឆ្នាំ២០២៣) រដ្ឋាភិបាលបានដាក់អនុសាសន៍ឱ្យផ្តល់ភាពអនុគ្រោះដល់អ្នកដេញថ្លៃ និងអ្នកវិនិយោគទាំងឡាយណាដែលមានកេរ្តិ៍ឈ្មោះខាងនិរន្តរភាព នៅក្នុងការដេញថ្លៃជាសាធារណៈ ស្របតាមច្បាប់ស្តីពីការការពារបរិស្ថាន។ ត្រង់នេះបង្ហាញថារដ្ឋាភិបាលវៀតណាមមានចេតនាយ៉ាងមុតមាំក្នុងការប្រើប្រាស់ការចំណាយលើលទ្ធកម្មរបស់ខ្លួន ដើម្បីសម្រេច បាននូវគោលដៅប្រកបដោយនិរន្តរភាពកាន់តែទូលំទូលាយ និងដើម្បីកសាងសេដ្ឋកិច្ចបៃតង សេដ្ឋកិច្ចធន់ និងសេដ្ឋកិច្ចចក្រា។

វៀតណាមជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួនក្នុងតំបន់ ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងពហុភាគី ជាមួយគោលបំណងទាក់ទាញការវិនិយោគ ព្រមទាំងទាញយកផលប្រយោជន៍ពីផ្លូវពាណិជ្ជកម្ម សម្រាប់ធ្វើឱ្យផលិតផលរបស់ខ្លួនកាន់តែមានភាពប្រកួតប្រជែងលើទីផ្សារនាំចេញ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី EU-Vietnam (EVFTA) អនុញ្ញាតឱ្យមានការប្រព្រឹត្តដូចគ្នាចំពោះអ្នកដេញថ្លៃមកពីសហភាពអឺរ៉ុប និងវៀតណាម នៅក្នុងលទ្ធកម្មសាធារណៈ។ កិច្ចព្រមព្រៀងនេះអនុវត្តចំពោះកញ្ចប់ដេញថ្លៃ ក្រោមក្របខ័ណ្ឌនៃ EVFTA លើសពីកម្រិតគោលអប្បបរមា សម្រាប់បញ្ជីស្ថាប័នសាធារណៈដែលមានការបញ្ជាក់អាជ្ញាបណ្ណ និងជាមួយការដកចេញនូវផលិតផល និងសេវាកម្មមួយចំនួន ដូចមានលម្អិតនៅក្នុងកិច្ចព្រមព្រៀង EVFTA - ជំពូកទី៩ លទ្ធកម្មសាធារណៈ។ កិច្ចព្រមព្រៀងនេះស្នើឱ្យមានការដោះស្រាយបញ្ហាការងារ និងបញ្ហា

បរិស្ថាន ដែលពាក់ព័ន្ធចម្រុះ នៅក្នុងបរិបទនៃទំនាក់ទំនងពាណិជ្ជកម្មរវាង សហភាពអឺរ៉ុប និងវៀតណាម។

## ៦.២. ការបង្កើតគោលនយោបាយ

លទ្ធកម្មសាធារណៈក្នុងប្រទេសវៀតណាមស្ថិតក្រោមការគ្រប់គ្រងដោយច្បាប់លេខ 43/2013/QH13 ស្តីពីការដេញថ្លៃ ដែលមានសុពលភាពចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៤ ដែលត្រូវបានធ្វើវិសោធនកម្ម និងបន្ថែមដោយច្បាប់លេខ 03/2016/QH14 ក្នុងវិសោធនកម្ម និងបន្ថែមលើមាត្រាទី៦ និងឧបសម្ព័ន្ធទី ៤ ស្តីពី បញ្ជីនៃអាជីវកម្មភ្ជាប់លក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ស្តីពីការវិនិយោគ ដែលចូលជាធរមានចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៧។ ច្បាប់នេះត្រូវបានបំពេញបន្ថែមគោលការណ៍ណែនាំការអនុវត្តមួយចំនួន ដូចជា ក្រឹត្យរដ្ឋាភិបាល, សារាចរក្រសួង, សេចក្តីណែនាំ/សេចក្តីសម្រេចរដ្ឋបាល និងឯកសារដេញថ្លៃស្តង់ដា។ រដ្ឋាភិបាលបានបន្តកសាង ពង្រឹង និងកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈរបស់ខ្លួន ដើម្បីឱ្យសមស្របសម្រាប់សម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងជួយប្រទេសឱ្យសម្រេចគោលដៅដែលបានកំណត់ក្នុងចក្ខុវិស័យឆ្នាំ២០៣៥ របស់ខ្លួន។ លើសពីនេះទៀត រដ្ឋាភិបាលជំរុញការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មរដ្ឋាភិបាលអេឡិចត្រូនិក (e-GP) ចាប់តាំងពីឆ្នាំ២០០៩ ហើយឥឡូវនេះបានដាក់កំហិតជាកាតព្វកិច្ចនូការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិកជាតិវៀតណាម (VNEPS)។

ថ្មីៗនេះ រដ្ឋាភិបាលបានអនុម័តច្បាប់ថ្មីស្តីពីការដេញថ្លៃលេខ 22/2023/QH15[23] (ខែមិថុនា ឆ្នាំ២០២៣) ដែលចូលជាធរមានចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤។ ច្បាប់នេះមានបទប្បញ្ញត្តិគួរឱ្យកត់សម្គាល់ជាច្រើន ដែលទាក់ទងនឹងការបញ្ចូលការគិតគូរអំពីនិរន្តរភាពទៅក្នុងការសម្រេចចិត្តទិញ ដូចជាការទិញផលិតផល និងសេវាកម្មដែលមេត្រីបរិស្ថាន; បទប្បញ្ញត្តិសម្រាប់ការបញ្ចូលការអនុគ្រោះពន្ធសម្រាប់ក្រុមហ៊ុនក្នុងស្រុក និងសម្រាប់ការគាំទ្រដល់សហគ្រាសខ្នាតតូច និងមធ្យម, ការអនុគ្រោះក្នុងការទិញ សម្រាប់អ្នកម៉ៅការដែលប្រើកម្លាំងពលកម្មស្ត្រី ២៥% ឬច្រើនជាងនេះ, កម្លាំងពលកម្មនៃជនមានពិការភាព ២៥% ឬច្រើនជាងនេះ, កម្លាំងពលកម្មនៃជនជាតិដើមភាគតិច ២៥% ឬច្រើនជាងនេះ, ការប្រើប្រាស់ចំណាយថ្លៃដើមក្នុងវដ្តផលិតផលជាលក្ខណៈវិនិច្ឆ័យវាយតម្លៃ ជាដើម។ បច្ចុប្បន្ន រដ្ឋាភិបាលកំពុងដំណើរការរៀបចំសេចក្តីព្រាងអនុក្រឹត្យមួយ ដើម្បីបញ្ជាក់លម្អិតអំពីបទប្បញ្ញត្តិផ្សេងៗ ដែលមាននៅក្នុងច្បាប់នេះ។

## ៦.៣. ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ

ទោះបីជាការគិតគូរលើទិដ្ឋភាពបរិស្ថានក្នុងលទ្ធកម្មសាធារណៈ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈច្បាប់ដេញថ្លៃថ្មីឆ្នាំ២០២៣ ក៏ដោយ ក៏ប្រទេសវៀតណាមមានឯកសារយុទ្ធសាស្ត្រមួយចំនួនរួចហើយ ដែលគាំទ្រការរួមបញ្ចូលនិរន្តរភាពទៅក្នុងការទិញសាធារណៈ ដើម្បីសម្រេចបាននូវគោលដៅសេដ្ឋកិច្ចសង្គមជាតិកាន់តែទូលំទូលាយ និងចក្ខុវិស័យរយៈពេលវែង ដើម្បីប្រែក្លាយវៀតណាមទៅជាប្រទេសមួយដែលមានសេដ្ឋកិច្ចបៃតង ធន់ និងចក្រា។ ឧទាហរណ៍ ផែនការសកម្មភាពជាតិស្តីពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព (២០២១-២០៣០) គិតគូរអំពីការប្រើប្រាស់លទ្ធកម្មសាធារណៈបៃតង ជាឧបករណ៍មួយដើម្បីសម្រេចបាននូវកំណើនកាន់តែទូលំទូលាយ និងបៃតង[24]។ យុទ្ធសាស្ត្រកំណើនបៃតងជាតិ (២០២១-២០៣០) បានកំណត់គោលដៅសម្រាប់លទ្ធកម្មសាធារណៈបៃតងឱ្យបាន ៣៥% នៅឆ្នាំ២០៣០ និង ៥០% នៅឆ្នាំ២០៥០ នៃលទ្ធកម្មសាធារណៈសរុប[25]។ សារៈតារគោលនយោបាយនេះ បានជំរុញឱ្យរដ្ឋាភិបាលពន្លឿនការបង្កើតគោលនយោបាយលទ្ធកម្មសាធារណៈបៃតង និងក្របខ័ណ្ឌស្ថាប័នដើម្បីឈានទៅសម្រេចបានកំណើនបៃតង។ លើសពីនេះ ច្បាប់ស្តីពីការការពារបរិស្ថានលេខ 72/2020/QH14 ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០ ចែងថា៖ "ធ្វើអាទិភាពលទ្ធកម្មបៃតងសម្រាប់គម្រោង និងភារកិច្ចដែលទទួលមូលនិធិពីថវិការដ្ឋ តាមការកំណត់របស់រដ្ឋាភិបាល"។ ប្រការនេះបានចែងលម្អិតទៀត នៅក្នុងក្រឹត្យរដ្ឋាភិបាលលេខ 08/2022/ND-CP ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២[26] ដោយតម្រូវឱ្យរដ្ឋាភិបាលធ្វើអាទិភាពការប្រើប្រាស់ផលិតផលមេត្រីបរិស្ថាន ដែលមានការបញ្ជាក់ដោយវិញ្ញាបនបត្រស្លាកមេត្រីបរិស្ថានវៀតណាម។ ទន្ទឹមនឹងនេះ ការរួមបញ្ចូលធាតុពាក់ព័ន្ធផ្សេងទៀតដែលលើកកម្ពស់និរន្តរភាព (កត្តាសេដ្ឋកិច្ច សង្គម បរិស្ថាន) ទៅក្នុងបទប្បញ្ញត្តិគ្រប់គ្រងសកម្មភាពលទ្ធកម្ម មានគោលបំណងធ្វើឱ្យការបញ្ចូលនិរន្តរភាព ក្លាយជាទម្លាប់មួយក្នុង

23 Available at https://english.luatvietnam.vn/dau-thau/bidding-law-no-22-2023-qh15-259737-d1.html#:~:text=This%20Law%20prescribes%20the%20state,to%20implement%20business%20investment%20projects., Accessed on 21.11.2023

24 Available at https://www.switch-asia.eu/resource/vietnam-national-action-plan-on-scp-2021-2030/#:~:text=The%20National%20Action%20Plan%20on,lives%20towards%20a%20circular%20economy. Accessed on 21.11.2023

25 Available at https://en.baochinhphu.vn/national-green-growth-strategy-for-2021-2030-vision-towards-2050-11142515.htm Accessed on 21.11.2023

26 Available at https://lawnet.vn/en/vb/Circular-02-2022-TT-BTNMT-Detailing-articles-of-law-on-environmental-protection-7BF03.html, Accessed on 20.11.2023

រាល់សកម្មភាពចំណាយ។ យុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ ក៏បញ្ចូលផងដែរនូវការកំណត់គូតាមួយចំនួន លើការបំភាយឧស្ម័នផ្ទះកញ្ចក់សម្រាប់វិស័យសាធារណៈ ដើម្បីសម្រេចបាននូវគោលដៅសូន្យសុទ្ធត្រឹមឆ្នាំ២០៥០ ដោយប្រែក្លាយវិធានការមួយចំនួនជាកាតព្វកិច្ចចាំបាច់ រួមទាំងលទ្ធកម្មសាធារណៈបៃតងដែរ ដើម្បីរក្សាស្ថានភាពក្នុងកូតានៃការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលបានបែងចែករួចហើយ។ វៀតណាមជាសមាជិកនៃអង្គការពលកម្មអន្តរជាតិ (ILO) និងបានផ្តល់សច្ចាប័នលើអនុសញ្ញាចំនួន៧ ក្នុងចំណោមអនុសញ្ញាជាមូលដ្ឋានចំនួន ៨ (មិនរាប់បញ្ចូលសេរីភាពក្នុងការបង្កើតសមាគម)។[27]

ដូច្នេះ គួរកត់សម្គាល់ដែរថា បទប្បញ្ញត្តិដែលមាននៅក្នុងច្បាប់ដេញថ្លៃថ្មីឆ្នាំ២០២៣ ទាក់ទងការគិតគូរអំពីនិរន្តរភាពក្នុងលទ្ធកម្មសាធារណៈ ត្រូវបានតម្រឹមជាមួយនឹងឯកសារយុទ្ធសាស្ត្រទូលំទូលាយ។ ភាពសុខដុមរមនានៃគោលនយោបាយផ្សេងៗបែបនេះ មានសារៈសំខាន់សម្រាប់ការអនុវត្តលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាពនៅវៀតណាម។ យ៉ាងណាក៏ដោយ គោលបំណងទាំងនេះអាចសម្រេចបាន លុះត្រាតែនិរន្តរភាពត្រូវបានកំណត់ជាគោលដៅច្បាស់លាស់ក្នុងច្បាប់លទ្ធកម្មសាធារណៈ ហើយកាតព្វកិច្ចបញ្ចូលការគិតគូរអំពីនិរន្តរភាពនៅដំណាក់កាលផ្សេងៗនៃដំណើរការលទ្ធកម្ម ត្រូវបានចែងឱ្យបានច្បាស់លាស់នៅក្នុងក្រឹត្យ និងសារាចរ ដើម្បីជាប្រយោជន៍ដល់អ្នកជំនាញលទ្ធកម្ម។

## ៦.៤. ការរៀបចំស្ថាប័ន

ក្រសួងផែនការ និងវិនិយោគ ជាស្ថាប័នស្នូលជាតិសម្រាប់កំណើនបៃតង និងទទួលខុសត្រូវក្នុងការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ ស្ថាប័ន គោលនយោបាយ និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ រួមទាំងលទ្ធកម្មប្រកបដោយនិរន្តរភាព/បៃតង ដែរ។ តាមរយៈទីភ្នាក់ងារលទ្ធកម្មសាធារណៈ ក្រសួងផែនការ និងវិនិយោគតាមដាន និងរាយការណ៍អំពីលទ្ធកម្មសាធារណៈ ហើយក៏ជាអ្នកតាក់តែងក្រឹត្យមួយដើម្បីបំពេញបន្ថែមច្បាប់ដេញថ្លៃផងដែរ។ អង្គភាពផ្តល់សេវាលទ្ធកម្មថ្នាក់កណ្តាលក្នុងក្របខ័ណ្ឌក្រសួងផែនការ និងវិនិយោគ គឺជាការិយាល័យទទួលខុសត្រូវក្នុងការផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីលទ្ធកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ក្រសួងហិរញ្ញវត្ថុ ទទួលខុសត្រូវលើការចេញបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ផ្សព្វផ្សាយស្តង់ដា និងបទដ្ឋានសម្រាប់ការប្រើប្រាស់គ្រឿងចក្រ និងបរិក្ខារ និងការចេញបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដែលក្នុងនោះរាល់ការចំណាយលើលទ្ធកម្មដែលប្រើប្រាស់ធនធានថវិការដ្ឋផ្តល់អាទិភាពដល់ទំនិញដែលមានស្លាកអេកូ និងទំនិញដែលអាចកែច្នៃឡើងវិញបាន។

ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម ជាអ្នកបង្កើត និងពិនិត្យមើលលើស្តង់ដាជាតិស្តីពីប្រសិទ្ធភាពថាមពល, ផ្សព្វផ្សាយបទប្បញ្ញត្តិបច្ចេកទេសជាតិ និងស្តង់ដាជាតិក្នុងវិស័យសេដ្ឋកិច្ច និងការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធផល, ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ កំណើនបៃតង និងការអភិវឌ្ឍប្រកបដោយចីរភាព និងបង្កើត និងដាក់ពង្រាយដំណោះស្រាយ ដើម្បីគាំទ្រដល់ការអនុវត្តគ្រោងការណ៍ដាក់ស្លាកថាមពល។ ក្រសួងនេះក៏គ្រប់គ្រងស្លាកប្រសិទ្ធផលថាមពលវៀតណាមផងដែរ។

ក្រសួងធនធានធម្មជាតិ និងបរិស្ថាន ជាអ្នកបង្កើត និងធ្វើអធិការកិច្ចលើអនុវត្តលក្ខណៈវិនិច្ឆ័យស្លាកអេកូរបស់វៀតណាម (Vietnam Ecolabel) និងគោលនយោបាយប្រែប្រួលអាកាសធាតុ ហើយលើសពីនេះទៅទៀតគឺនាំមុខផ្នែកគោលនយោបាយសេដ្ឋកិច្ចចក្រា។

សរុបមក ក្រសួងផែនការ និងវិនិយោគ, ក្រសួងហិរញ្ញវត្ថុ, ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម និងក្រសួងធនធានធម្មជាតិ និងបរិស្ថាន ជាសសរស្តម្ភសំខាន់ៗបួន សម្រាប់ការអនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាព/បៃតងនៅប្រទេសវៀតណាម រួមជាមួយក្រសួងផ្សេងទៀតដូចជា ក្រសួងការងារ, ក្រសួងសុខុមាលភាពសង្គម ជាដើម។ សូមមើលគំនូសតាងទី៥។

27 Available at https://www.ilo.org/dyn/normlex/en/f?p=NORMLEXPUB:11200:0::NO::p11200_country_id:103004 Accessed on 28.11.2023




**គំនូសតាងទី៥៖** ទីភ្នាក់ងាររដ្ឋាភិបាល និងការទទួលខុសត្រូវរៀងៗខ្លួន ក្នុងការអនុវត្តលទ្ធកម្មសាធារណៈបៃតង នៅវៀតណាម[28]

## ៦.៥. គោលការណ៍ណែនាំ និងលក្ខណៈវិនិច្ឆ័យ

ដូចដែលបានរៀបរាប់ និងបង្ហាញជូនក្នុងគំនូសតាងទី៥ នៅខាងលើ បច្ចុប្បន្ននេះ ក្រសួងផែនការ និងវិនិយោគ កំពុងតាក់តែងសេចក្តីព្រាងក្រឹត្យមួយចំនួន ដើម្បីបំពេញបន្ថែមលើច្បាប់ស្តីពីការដេញថ្លៃឆ្នាំ២០២៣។ ដោយសារថាច្បាប់ដេញថ្លៃថ្មីគ្រោងនឹងចូលជាធរមានចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ ហេតុនេះគេរំពឹងថា ក្រឹត្យសម្រាប់ច្បាប់នេះ អាចចូលជាធរមាននៅត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ គេរំពឹងថាទៀតថាក្រឹត្យនេះនឹងបញ្ជាក់លម្អិតអំពីបទប្បញ្ញត្តិដែលបានធ្វើឡើងនៅក្នុងច្បាប់ដេញថ្លៃ ទាក់ទងការប្រែបាច់បញ្ចូលនិរន្តរភាពទៅក្នុងការសម្រេចចិត្តលទ្ធកម្ម ដើម្បីបញ្ជូនសញ្ញាច្បាស់លាស់ទៅកាន់ទីផ្សារ និងផ្សព្វផ្សាយអំពីចក្ខុវិស័យរយៈពេលវែងរបស់រដ្ឋាភិបាល អំពីការប្រើប្រាស់លទ្ធកម្មសាធារណៈជាឧបករណ៍យុទ្ធសាស្ត្រ ដើម្បីទទួលបានមកវិញនូវផលសមនឹងតម្លៃនៃប្រាក់ (value for money) និងដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិកាន់តែទូលំទូលាយ។

ដោយផ្អែកលើប្រការនៅក្នុងក្រឹត្យនេះ រដ្ឋាភិបាលទំនងជានឹងធ្វើការចុះផ្សាយសារាចរបញ្ជាក់ពីបទប្បញ្ញត្តិនៅក្នុងក្រឹត្យនេះ និងការកែសម្រួលឯកសារដេញថ្លៃស្តង់ដា (SBDs) សម្រាប់លទ្ធកម្មទំនិញ ការងារសាងសង់ និងសេវាកម្មផ្សេងៗ។

ក្រសួងធនធានធម្មជាតិ និងបរិស្ថាន បានបង្កើតកម្មវិធីជាតិស្លាកបៃតង (Ecolabelling) និងគ្រប់គ្រងគម្រោងស្លាកបៃតង Type-1[29] មាន ឈ្មោះថា "Vietnam Green Label" ដែលអនុលោមតាមលក្ខណៈវិនិច្ឆ័យនៃស្លាកបៃតងដែលក្រសួងបានដាក់ឱ្យប្រើ។ កម្មវិធីនេះបានបង្កើតលក្ខណៈវិនិច្ឆ័យស្លាកបៃតងសម្រាប់ផលិតផលចំនួន ១៧ក្រុម ហើយក្រុមហ៊ុនចំនួន ៥៣ នៅក្នុងប្រទេសវៀតណាម បានទទួលវិញ្ញាបនបត្រដើម្បីប្រើប្រាស់ស្លាកបៃតងវៀតណាមលើផលិតផលរបស់ពួកគេ[30]។ ថ្មីៗនេះ ប្រទេសវៀតណាមបានប្រកាសលក្ខណៈវិនិច្ឆ័យសម្រាប់ការវេចខ្ចប់ប្លាស្ទិកដែលមេត្រីបរិស្ថាន[31] ។

28 GiZ (2021). National Green Public Procurement and Environmental Labels in Cambodia, Lao PDR, Myanmar, Vietnam, and Bhutan.

29 A Type-1 Ecolabelling Scheme involves independent third-party verification and certification. Its implementation adheres to the guidelines outlined in ISO 14024 (Environmental labels and declarations – Type I environmental labelling – Principles and procedures) which outlines the requirements for developing 'Type I environmental labelling programmes', more commonly known as ecolabelling schemes. These schemes award a mark or logo to products or services upon fulfilling a set of criteria. ISO 14024 features the principles and procedures for selecting product categories, product-environmental criteria, product-function characteristics and for assessing and demonstrating compliance. It also establishes the certification procedures for awarding the label.

30 United Nations Environment Programme (2016). Project 'Stimulating the Demand and Supply of Sustainable Products through Sustainable Public Procurement and Ecolabelling' (SPPEL): SWOT Analysis of Vietnam Green Label Programme Report. https://wedocs.unep.org/20.500.11822/37481.

31 Available at https://en.vietnamplus.vn/vietnam-ecolabel-criteria-for-environmentally-friendly-plastic-issued/271540.vnp Accessed on 28.11.2023

វៀតណាមក៏មានកម្មវិធីស្តង់ដាប្រសិទ្ធភាពថាមពល និងស្លាកសញ្ញា ដែរ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពថាមពលនៅក្នុងឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ។ ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម ជាទីភ្នាក់ងារកណ្តាលសម្រាប់ការគ្រប់គ្រងស្លាកអនុម័តយល់ព្រមមានឈ្មោះថា "Viet Energy Star" សម្រាប់ផលិតផលបំភ្លឺដែលមានប្រសិទ្ធភាពអត្តិសនីខ្ពស់ និងស្លាកប្រហាក់ប្រហែលសម្រាប់ឧបករណ៍ប្រើក្នុងផ្ទះ និងក្នុងការិយាល័យ។ សកម្មភាពដាក់ស្លាកថាមពលនៅប្រទេសវៀតណាម ត្រូវបានអនុវត្តដោយស្ម័គ្រចិត្តចាប់ពីឆ្នាំ២០០៨ និងជាកាតព្វកិច្ច (សម្រាប់យានជំនិះ និងឧបករណ៍មួយចំនួន) ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៣។ រហូតមកដល់បច្ចុប្បន្ន កម្មវិធីស្លាកថាមពលសម្រេចបានសមិទ្ធផលសំខាន់ៗមួយចំនួន។ ជាពិសេស ជារៀងរាល់ឆ្នាំ មានលេខកូដផលិតផលថ្មីចំនួនប្រហែល ១០ ០០០ ដែលជាកម្មសិទ្ធិរបស់គ្រឿងបរិក្ខារចំនួន ២៦ប្រភេទ ដែលមានស្លាកថាមពលចាប់ពីផ្កាយ ១ ដល់ផ្កាយ ៥។

វត្តមានរបស់ស្លាកអេកូ និងស្លាកប្រសិទ្ធភាពថាមពលក្នុងប្រទេសវៀតណាម ជាហេតុផលល្អមួយសម្រាប់ភ្ជាប់កម្មវិធីទាំងនេះជាមួយការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងប្រចាប់បញ្ចូលការគិតគូរអំពីនិរន្តរភាព ទៅក្នុងការសម្រេចចិត្តទិញនៅក្នុងច្បាប់ដេញថ្លៃថ្មី។ ក្រឹត្យដែលបានស្នើឡើងដើម្បីបំពេញបន្ថែមច្បាប់ដេញថ្លៃ អាចដើរតួកំណត់ថាតើត្រូវប្រើស្លាកដោយស្ម័គ្រចិត្ត ឬជាកាតព្វកិច្ចជាកំហិត កាលណាអ្នកទិញជាទីភ្នាក់ងារសាធារណៈ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើបរិស្ថានពីការធ្វើលទ្ធកម្មសាធារណៈ។

## ៦.៦. កម្មវិធីកសាងសមត្ថភាព បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង

សេវាលទ្ធកម្មថ្នាក់កណ្តាល (CPS) ដែលនៅក្រោមឱវាទទីភ្នាក់ងារលទ្ធកម្មសាធារណៈ មានភារកិច្ចធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាព អំពីលទ្ធកម្មសាធារណៈ។ គ្រូឧទ្ទេសក្នុងស្រុកជាច្រើនក្រុម បានបណ្តុះបណ្តាលកាវីជំនាញលទ្ធកម្មជាង ៦ ០០០នាក់រួចហើយ ដែលមកពីក្រសួង និងស្ថាប័នសាធារណៈផ្សេងៗគ្នា។ ជាមួយច្បាប់ដេញថ្លៃថ្មីឆ្នាំ២០២៣ ដែលចូលជាធរមានចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ ពួកគេចាំបាច់ត្រូវកែសម្រួលម៉ូឌុលបណ្តុះបណ្តាលរបស់ខ្លួន ឱ្យស្របតាមច្បាប់ថ្មី រួមទាំងបទប្បញ្ញត្តិទាក់ទងនឹងលទ្ធកម្មប្រកបដោយនិរន្តរភាពផងដែរ។

## ៦.៧. ការតាមដាន និងវាយតម្លៃ

ក្រសួងផែនការ និងវិនិយោគ ទទួលបន្ទុកពិនិត្យមើលឡើងវិញ និងតាមដានសកម្មភាពលទ្ធកម្ម តាមនីតិវិធីដែលមានស្រាប់។ បច្ចុប្បន្ននេះ ក្រសួងប្រើប្រាស់ប្រព័ន្ធ e-GP ដើម្បីប្រមូលទិន្នន័យសម្រាប់ធ្វើការវិភាគ និងការតាមដានសូចនាករនៃការអនុវត្តសំខាន់ៗ (KPIs) ទាក់ទងនឹងលទ្ធកម្ម។ ដោយសារបច្ចុប្បន្នទីភ្នាក់ងារសាធារណៈគ្មានកាតព្វកិច្ចក្នុងការទិញផលិតផល ឬសេវាកម្មដែលមានលក្ខណៈវិនិច្ឆ័យនិរន្តរភាព ទីភ្នាក់ងារនេះមិនស្ថិតក្រោមការត្រួតពិនិត្យនៅកម្រិតរដ្ឋាភិបាលទេ។

## ៦.៨. កិច្ចសហការ និងភាពជាដៃគូ

ពេលខ្លះ រដ្ឋាភិបាលធ្វើការពាក់ព័ន្ធជាមួយសភាពាណិជ្ជកម្ម និងឧស្សាហកម្មវៀតណាម (VCCI) រណសិរ្សមាតុភូមិវៀតណាម (VFF) សហភាពវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាវៀតណាម (VUSTA) ក្រុមប្រឹក្សាប្រជាជន និងបញ្ហាផ្សេងទៀតទាក់ទងនឹងលទ្ធកម្ម។ ទម្លាប់អនុវត្តបែបនេះក្នុងការពាក់ព័ន្ធជាមួយសមាគមឧស្សាហកម្ម អាចត្រូវបានគេប្រើប្រាស់សម្រាប់ផ្តល់សញ្ញាឱ្យទីផ្សារ អំពីចេតនារបស់រដ្ឋាភិបាល ក្នុងការអនុវត្ត លទ្ធកម្មប្រកបដោយនិរន្តរភាព។

## ៦.៩. កំណត់ចំណាំ

បច្ចុប្បន្ននេះ វៀតណាមមិនទាន់មានគោលនយោបាយលទ្ធកម្មប្រកបដោយនិរន្តរភាពគ្រប់ជ្រុងជ្រោយនោះទេ ប៉ុន្តែតាមរយៈការបង្កើតបទប្បញ្ញត្តិអំណោយផលនៅក្នុងច្បាប់ដេញថ្លៃថ្មីឆ្នាំ២០២៣ សម្រាប់បញ្ចូលការគិតគូរអំពីនិរន្តរភាពទៅក្នុងការលទ្ធកម្មសាធារណៈ រដ្ឋាភិបាលហាក់ដូចជាបានបញ្ជូនសញ្ញាទៅកាន់ទីផ្សារ ឱ្យត្រៀមខ្លួនធ្វើការផ្លាស់ប្តូរប្រព័ន្ធផលិតកម្មស្របតាមគោលការណ៍បំភាយកាបូនតិច, ប្រសិទ្ធផលធនធាន និងសេដ្ឋកិច្ចចក្រា។

- វត្តមាននៃគ្រោងការណ៍ស្លាកអេកូ (ecolabel) សម្រាប់ផលិតផលដែលមេត្រីបរិស្ថាន និងមានប្រសិទ្ធភាពថាមពលមានសក្តានុពលក្នុងការពន្លឿនការទិញផលិតផលទាំងនោះដោយទីភ្នាក់ងារសាធារណៈ។

- បទប្បញ្ញត្តិទាក់ទងការគិតគូរអំពីនិរន្តរភាពនៅក្នុងច្បាប់ដេញថ្លៃ ចាំបាច់ត្រូវប្រែក្លាយឱ្យទៅជាក្រឹត្យ និងសារាចរ ដើម្បីឱ្យវាអាចបំពេញបាននូវតាមគោលបំណងនៃច្បាប់។
- កិច្ចព្រមព្រៀងពាណិជ្ជកម្មអាចបង្កើនការប្រកួតប្រជែងការនាំចេញរបស់ឧស្សាហកម្មក្នុងស្រុក ប្រសិនបើទីផ្សារទទួលយកទម្លាប់អនុវត្តផលិតកម្មប្រកបដោយនិរន្តរភាព ដែលភ្ជាប់ជាមួយការអនុវត្ត ការធ្វើលទ្ធកម្មសាធារណៈបៃតង ឬប្រកបដោយនិរន្តរភាព។

# ៧. សេចក្តីសន្និដ្ឋាន

មកដល់ត្រឹមនេះ ជាការណ៍សំខាន់ដែលត្រូវគូសរំលេចចំណុចសំខាន់ៗមួយចំនួន ក្រោយពីបានពិនិត្យមើលបទពិសោធន៍នានានៅក្នុងបណ្តាប្រទេសក្នុងតំបន់អាស៊ី។

គោលនយោបាយលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព/បៃតង (S/GPP) ត្រូវបានបង្កប់នៅក្នុងគោលបំណងអភិវឌ្ឍន៍ជាតិ។ វាដើរតួជាមាគ៌ាមួយសម្រាប់ឈានទៅកៀរគរហិរញ្ញវត្ថុសាធារណៈបៃតង តាមរយៈថវិកាសាធារណៈ និងមូលនិធិឯកជន ឬចម្រុះ។ លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព/បៃតង បានក្លាយជាគំរូជាក់ស្តែងមួយសម្រាប់បណ្តារដ្ឋាភិបាល យកទៅអនុវត្តគោលនយោបាយនិរន្តរភាពរបស់ខ្លួន និងផ្តល់សញ្ញាដល់ទីផ្សារ ដើម្បីធ្វើឱ្យផលិតផលប្រកបដោយនិរន្តរភាព ក្លាយជាបទដ្ឋានទូទៅមួយ។

ការអនុវត្តលទ្ធកម្មសាធារណៈបៃតងមិនត្រឹមតែជាបញ្ហាគោលនយោបាយលទ្ធកម្មប៉ុណ្ណោះទេ វាទាមទារឱ្យមានអភិក្រមពហុជំនាញ និងការសហការគ្នារវាងភាគីពាក់ព័ន្ធ ដែលប្រតិបត្តិការនៅកម្រិតផ្សេងៗនៃរដ្ឋាភិបាល (មជ្ឈិម មូលដ្ឋាន ទីក្រុង។ល។)។ ប្រទេសដែលមានភាពស្ទាត់ជំនាញខាងអភិក្រមពហុជំនាញ និងអន្តរស្ថាប័ន ទទួលបានផលលឿន ឬមានប្រសិទ្ធភាពជាងគេក្នុងការអនុវត្តលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព/បៃតង។

លទ្ធកម្មសាធារណៈបៃតង ទាមទារឱ្យមានអភិក្រមតាមវិស័យ ឬតាមប្រភេទផលិតផល ដែលសម្របទៅតាមបរិបទសេដ្ឋកិច្ច និងអាទិភាពវិនិយោគរបស់ប្រទេសនីមួយៗ។ ស្តង់ដាថ្នាក់តំបន់ ដូចមានបង្ហាញជូនខ្លះៗនៅក្នុងរបាយការណ៍នេះ គឺជាគន្លឹះ ប៉ុន្តែប្រទេសនីមួយៗចាំបាច់ត្រូវធ្វើការបន្សាំឱ្យសមទៅតាមបរិការណ៍នៃស្ថានភាពជាក់ស្តែងរៀងៗខ្លួន។

switchasia

Funded by
the European Union

www.switch-asia.eu

EU SWITCH-Asia Programme
@EUSWITCHAsia

SWITCH-Asia
@SWITCHAsia

SWITCH-Asia Official
@switch-asia-official